សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics


**សារណាបញ្ចប់ការសិក្សា**

# ការពិចារណាលើ
# បញ្ហាសន្តតិកម្មតាមមតកសាសន៍នៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២២ ដល់ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ឈាង ស្មី**

**ចិន សៅឋរី**

សាស្ត្រាចារ្យណែនាំ

លោក **គាន់ សុទ្ធម៉ូលីន**


បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៧ (អាហារូបករណ៍)

ឆ្នាំចូលរៀន ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **ឈារ រស្មី** និង កញ្ញា **ប៊ិន សៅរី** ជានិស្សិតអាហារូបករណ៍បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី ២៧ នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច សូមធ្វើការថ្លែងអំណរគុណ និងសម្តែងនូវការ គោរព និងដឹងគុណចំពោះ លោកឪពុក អ្នកម្តាយ ជាអ្នកមានគុណ ដែលលោកទាំងពីរបានផ្តល់កំណើត និង ចិញ្ចឹមបីបាច់ថែរក្សាកូនប្រកបដោយព្រហ្មវិហារធម៌រហូតមក ដោយបានខិតខំប្រឹងប្រែងធ្វើការទាំងយប់ថ្ងៃដោយ មិនខ្លាចនឿយហត់ ដើម្បីទំនុកបម្រុងគ្រួសារ និងជាពិសេសសម្រាប់ឧបត្ថម្ភការសិក្សា និងតម្រូវការផ្សេងៗ សម្រាប់កូន។ មិនត្រឹមតែប៉ុណ្ណោះ លោកបានអប់រំប្រៀនប្រដៅផ្តល់ដំបូន្មានឱ្យកូនដើរតាមគន្លងធម៌ ជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អ និងជួយជម្រុញ លើកទឹកចិត្តកូនក្នុងការសិក្សា រហូតទទួលបានបញ្ចប់កម្រិតបរិញ្ញាបត្រ នីតិសាស្ត្រដោយមិនមានឧបសគ្គ ដែលគុណទាំងអស់របស់លោកទាំងពីរពិតជាមានតម្លៃមិនអាចកាត់ថ្លៃបាន ហើយពួកកូននឹងបន្តចងចាំ និងដឹងគុណលោកជានិច្ច។

ទន្ទឹមនឹងនេះ យើងខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលជាថ្នាក់ដឹកនាំសាកលវិទ្យាល័យប្រកប ដោយការអភិវឌ្ឍធ្វើឱ្យយើងខ្ញុំទទួលបាននូវការសិក្សាដែលប្រកបដោយស្តង់ដារ និងគុណភាព។ ម្យ៉ាងទៀត យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ដែលបានផ្តល់ចំណេះដឹង ដំបូន្មាន ដឹកនាំ បំភ្លឺដល់យើងខ្ញុំ ទើបយើងខ្ញុំទាំងពីរអាចបញ្ចប់ការសរសេរសារណានេះប្រកបដោយជោគជ័យ។ មិនត្រឹម តែប៉ុណ្ណោះ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះ លោកគ្រូសាស្ត្រាចារ្យ **កាន់ សុទ្ធប៉ូលីន** ដែលលោក ជាសាស្ត្រាចារ្យណែនាំ ដែលបានជួយដឹកនាំបង្ហាញផ្លូវ ផ្តល់មតិយោបល់ជាច្រើនដើម្បីធ្វើការកែតម្រូវកិច្ចការ សារណានេះរហូតបញ្ចប់ទៅបានដោយជោគជ័យ។

ជាចុងក្រោយ យើងខ្ញុំសូមបួងសួងដល់ទេវតា ព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងឡាយធ្វើការប្រសិទ្ធិពរជ័យដល់ លោកឪពុក អ្នកម្តាយ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់នូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នៅក្នុងសង្គមមនុស្ស ការពិតមួយដែលពុំអាចប្រកែកបាននោះគឺ មនុស្សត្រូវបានបន្តវេនដោយមនុស្សជំនាន់ក្រោយពីមួយជំនាន់ទៅមួយជំនាន់រាប់សិបតំណ។ នៅពេលដែលមនុស្សបានលាចាកលោកនេះទៅ គ្មាននរណាម្នាក់អាចយកទ្រព្យសម្បត្តិដែលខ្លួនបានខិតខំរកបានមកនោះទៅជាមួយខ្លួននោះទេ សូម្បីតែមួយកាក់សេន គឺត្រូវបន្សល់ទុកនូវទ្រព្យសម្បត្តិទាំងនោះឱ្យទៅកូនចៅរបស់ខ្លួនជាអ្នកគ្រប់គ្រងបន្តដែលនៅក្នុងបរិបទច្បាប់របបនៃការទទួលបន្តទ្រព្យសម្បត្តិនៅពេលដែលមនុស្សទទួលមរណភាពនេះ ត្រូវបានគេហៅថាសន្តតិកម្ម ចំណែកឯទ្រព្យសម្បត្តិមត៌កទាំងអស់នោះ អាចត្រូវបានគេហៅថាជា សិទ្ធិ និងករណីយកិច្ច ផងដែរ។

ក៏ប៉ុន្តែ ដោយសារតែមនុស្សមានភាពលោភលន់ ធ្វើឱ្យការទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចទាំងនោះពុំមានភាពងាយស្រួល និងរលូននោះទេ ដែលជារឿយៗ ជម្លោះ វិវាទនៅក្នុងគ្រួសារតែងតែកើតមានឡើង និងបានបន្តអូសបន្លាយអស់រយៈពេលជាច្រើនឆ្នាំ ដូចជាការកាត់ផ្តាច់ទំនាក់ទំនងរវាងគ្នានិងគ្នាដោយសារតែមត៌កទៀតផង។ ហេតុនេះ ដើម្បីគ្រប់គ្រង និងរក្សាសណ្តាប់ធ្នាប់នៅក្នុងសង្គម ច្បាប់បានដើរតួនាទីសំខាន់ជាងគេ ជាពិសេសគឺ ក្រមរដ្ឋប្បវេណី ដែលក្រមនេះបានបញ្ញត្តពាក់ព័ន្ធនឹងសន្តតិកម្មផងដែរ។

ទោះបីជាក្រមរដ្ឋប្បវេណីបានបញ្ញត្តអំពីសន្តតិកម្មក៏ដោយ ក៏ពុំបានន័យថា ជនដែលជាម្ចាស់មត៌កពុំមានសិទ្ធិក្នុងការបែងចែកទៅតាមឆន្ទៈរបស់ខ្លួនឡើយ ពោលគឺ ច្បាប់នេះបានផ្តល់សិទ្ធិយ៉ាងពេញលេញសម្រាប់ម្ចាស់មត៌កផងដែរ ដោយពួកគេអាចធ្វើការបង្ហាញឆន្ទៈចុងក្រោយនេះនៅពេលដែលនៅរស់ តាមរយៈវិធីម្យ៉ាងគឺការធ្វើមតកសាសន៍ តែដោយត្រូវគោរពតាមបញ្ញត្តិនៃច្បាប់។ ក៏ប៉ុន្តែ ទាក់ទងនឹងបទប្បញ្ញត្តិស្តីពីសន្តតិកម្មតាមមតកសាសន៍មានបញ្ហាមួយចំនួនកើតមានឡើង ដែលវាអាចក្លាយជាដើមហេតុធ្វើឱ្យការធ្វើសន្តតិកម្មតាមមតកសាសន៍ពុំអាចប្រព្រឹត្តទៅបានដោយរលូនឡើយ។

ហេតុនេះ ដើម្បីចូលរួមចំណែកដោះស្រាយបញ្ហាច្បាប់ទាំងនោះ ឱ្យការអនុវត្តជាក់ស្តែងទាក់ទងនឹងសន្តតិកម្មតាមមតកសាសន៍កាន់តែមានភាពល្អប្រសើរ សារណានេះនឹងធ្វើការលើកឡើងនូវបញ្ហាទាំងនោះ និងព្រមទាំងធ្វើការសិក្សាស្រាវជ្រាវ និងពិចារណាចំពោះការយល់ឃើញផ្សេងៗទាក់ទងនឹងបញ្ហាទាំងនោះ ពីអ្នកច្បាប់នៅព្រះរាជាណាចក្រកម្ពុជា និងជាពិសេស ពីអ្នកច្បាប់នៅប្រទេសជប៉ុនផងដែរ។

យើងខ្ញុំសង្ឃឹមថា អត្ថបទសារណានេះ នឹងចូលរួមចំណែកជាប្រយោជន៍ដល់អ្នកអាន អ្នកសិក្សាទាំងអស់ ព្រមទាំងសូមអភ័យទោសសម្រាប់កំហុសឆ្គងដោយអចេតនាណាមួយ និងស្វាគមន៍នូវរាល់មតិកែលំអទាំងឡាយ។

សូមអរគុណយ៉ាងជ្រាលជ្រៅ ពីយើងខ្ញុំ។

# មាតិកា

**សេចក្តីផ្តើម** ............ ១

**ជំពូកទី១ បញ្ហានៅក្នុងទិដ្ឋភាពនៃការបង្កើតមតកសាសន៍** ............ ៤

**ផ្នែកទី១ បញ្ហានៃលក្ខខណ្ឌសុពលភាពនៃមតកសាសន៍** ............ ៤

កថាខណ្ឌទី១ បញ្ហានៃលក្ខខណ្ឌសមត្ថភាពក្នុងការធ្វើមតកសាសន៍ ............ ៤

ក. សមត្ថភាពក្នុងការធ្វើមតកសាសន៍ ............ ៤

ខ. គុណភាពនៃឆន្ទៈ ............ ៦

គ. បញ្ហានៃលក្ខខណ្ឌសមត្ថភាពក្នុងការធ្វើមតកសាសន៍ ............ ៦

កថាខណ្ឌទី២ បញ្ហានៃលក្ខខណ្ឌនៃភាពចាំបាច់នៃទម្រង់នៃមតកសាសន៍ ............ ៩

ក. ទម្រង់នៃមតកសាសន៍សម្រាប់ស្ថានភាពធម្មតា ............ ៩

ខ. ទម្រង់នៃមតកសាសន៍សម្រាប់ស្ថានភាពពិសេស ............ ១៦

គ. បញ្ហានៃលក្ខខណ្ឌនៃភាពចាំបាច់នៃទម្រង់មតកសាសន៍ ............ ១៩

**ផ្នែកទី២ បញ្ហានៃខ្លឹមសារមតកសាសន៍** ............ ២១

កថាខណ្ឌទី១ ខ្លឹមសារទាក់ទងនឹងទ្រព្យសម្បត្តិ ............ ២១

ក. ការកំណត់ចំណែកមត៌ក ............ ២១

ខ. ការកំណត់នូវវិធីបែងចែកដោយមតកសាសន៍ជាអាទិ៍ ............ ២២

គ. ការកំណត់អំពីអច្ច័យទាន ............ ២៣

កថាខណ្ឌទី២ ខ្លឹមសារមិនទាក់ទងនឹងទ្រព្យសម្បត្តិ ............ ២៦

ក. ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍ ............ ២៦

ខ. ការកំណត់អំពីដំបូន្មាន និងចំណុចផ្សេងៗទៀតជាអាទិ៍ ............ ២៧

កថាខណ្ឌទី៣ បញ្ហានៃខ្លឹមសារមតកសាសន៍ ............ ២៧

**ជំពូកទី២ បញ្ហានៅក្នុងទិដ្ឋភាពនៃការប្រតិបត្តិមតកសាសន៍** ............ ៣០

**ផ្នែកទី១ បញ្ហានៃការបញ្ជាក់ពីអត្ថិភាពនៃមតកសាសន៍ចុងក្រោយ** ............ ៣០

កថាខណ្ឌទី១ ការពិនិត្យបញ្ជាក់ និង ការបើកមតកសាសន៍ ............ ៣០

កថាខណ្ឌទី២ បញ្ហានៃការបញ្ជាក់ពីអត្ថិភាពនៃមតកសាសន៍ចុងក្រោយ ............ ៣១

**ផ្នែកទី២ បញ្ហាមតកសាសន៍ និងប្រទានកម្មដោយមូលហេតុមរណភាពដែលមានខ្លឹមសារផ្ទុយគ្នា និង បញ្ហានៃការបែងចែកមត៌កខុសពីខ្លឹមសារមតកសាសន៍**..............៣៣
កថាខណ្ឌទី១ បញ្ហាមតកសាសន៍ និងប្រទានកម្មដោយមូលហេតុមរណភាពដែលមានខ្លឹមសារផ្ទុយគ្នា.. ៣៣
ក. ប្រៀបធៀបអានុភាពនៃមតកសាសន៍ និងប្រទានកម្មដោយមូលហេតុមរណភាព...................៣៤
ខ. បញ្ហាមតកសាសន៍ និងប្រទានកម្មដោយមូលហេតុមរណភាពដែលមានខ្លឹមសារផ្ទុយគ្នា.........៣៨
កថាខណ្ឌទី២ បញ្ហានៃការបែងចែកមត៌កខុសពីខ្លឹមសារមតកសាសន៍ ....................................... ៤០
ក. មូលដ្ឋាននៃការបែងចែកមត៌ក........................................................................................ ៤០
ខ. បញ្ហានៃការបែងចែកខុសពីខ្លឹមសារមតកសាសន៍..........................................................៤២
**សេចក្តីសន្និដ្ឋាន** ........................................................................................................................៤៤
**អនុសាសន៍** ...............................................................................................................................៤៥
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## លំនាំបញ្ហា

ប្រទេសកម្ពុជាបានទទួលយកប្រព័ន្ធច្បាប់ស៊ីវិលធ្វើជាប្រព័ន្ធច្បាប់របស់ខ្លួន ដោយបានទទួលឥទ្ធិពលពីប្រទេសបារាំងដែលបានដាក់ទឹកដីកម្ពុជាជាដែនដីអាណានិគមរបស់ខ្លួនចាប់តាំងពី ឆ្នាំ ១៨៦៣ ដល់ ឆ្នាំ ១៩៥៣។ បន្ទាប់មក នៅឆ្នាំ ១៩៦៧ ក្រមរដ្ឋប្បវេណីដំបូងគេរបស់កម្ពុជាបានលេចរូបរាងឡើង ហើយនៅក្នុងនោះសញ្ញាណនៃសន្តតិកម្មតាមមតកសាសន៍ក៏បានលេចឡើងយ៉ាងច្បាស់ផងដែរ នៅក្នុងប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជា។

ក្រោយមក ប្រទេសកម្ពុជាទទួលរងនូវការឈ្លានពាន ក៏ដូចជាសង្គ្រាមយ៉ាងជោគជាំដែលជាហេតុធ្វើឱ្យស្ថិរភាពនៅក្នុងស្រុកស្ទើរតែគ្មានអស់រយៈពេលជាច្រើនឆ្នាំដែលជាហេតុធ្វើឱ្យការអនុវត្តក្រមរដ្ឋប្បវេណីខាងលើនេះ ត្រូវបានខកខាននៅក្នុងសម័យកាលដូចជា សម័យកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ជាដើម។ បន្ទាប់ពីរបបនេះបានដួលរលំ កម្ពុជាបានកសាងប្រទេសរបស់ខ្លួនចាប់ពីចំណុចសូន្យមកវិញរហូតដល់សម័យកាលបច្ចុប្បន្ន ដែលនៅទីបំផុត ក្រមរដ្ឋប្បវេណីថ្មីរបស់ខ្លួនបានលេចជារូបរាងឡើងនៅឆ្នាំ ២០០៧ តាមរយៈជំនួយផ្នែកតាក់តែងច្បាប់ពីប្រទេសជប៉ុន និងត្រូវបានអនុវត្តចាប់តាំងពីចុងឆ្នាំ ២០១១ មកម្ល៉េះ ហើយសញ្ញាណនៃសន្តតិកម្មតាមមតកសាសន៍ក៏បានបន្តមានវត្តមាននៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ របស់កម្ពុជាផងដែរ។

មតកសាសន៍បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងរបបសន្តតិកម្ម ដើម្បីគោរពតាមឆន្ទៈចុងក្រោយរបស់ម្ចាស់បណ្តាំ។ ដោយយោងតាមវចនានុក្រមនៃក្រមរដ្ឋប្បវេណី មតកសាសន៍គឺជាលិខិតបណ្តាំដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ដែលកំណត់ដោយច្បាប់ដើម្បីសម្តែងឆន្ទៈចុងក្រោយ អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព។

ជាគោលការណ៍ នៅក្នុងស្ថានភាពធម្មតា ទម្រង់នៃមតកសាសន៍ត្រូវបានបែងចែកជា ៣ ទម្រង់រួមមាន មតកសាសន៍ដោយលិខិតយថាភូត មតកសាសន៍ដោយលិខិតឯកជន មតកសាសន៍ដោយលិខិតសម្ងាត់។ ចំណែកឯនៅក្នុងស្ថានភាពខ្លះទៀតដែលមតកជនមិនស្ថិតក្នុងទីតាំងសមស្រប ឬស្ថានភាពដែលធម្មតាអាចឱ្យធ្វើមតកសាសន៍បានតាមប្រក្រតីបាននោះ ក្រមរដ្ឋប្បវេណីក៏បានចែងអំពីការធ្វើមតកសាសន៍ក្នុងករណីពិសេសទាំងនោះផងដែរ រួមមានដូចជា មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ មតកសាសន៍នៃជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំងជាអាទិ៍ និងការធ្វើមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍។

ចំណុចពិសេសនៃក្រមរដ្ឋប្បវេណីកម្ពុជាទាក់ទងនឹងការធ្វើមតកសាសន៍នេះគឺ ចំណុចដែលសារការី និងសាក្សីអាចសរសេរតែនាមត្រកូល និងនាមខ្លួន និងផ្តិតស្រាមដៃជាការគ្រប់គ្រាន់ហើយ ក្នុងករណីដែលសារការី និងសាក្សីនោះត្រូវចុះហត្ថលេខា (មាត្រា ១១៨០)។ ចំណុចនេះមានន័យថា បុគ្គលទាំងពីរខាងលើនេះ ពុំចាំបាច់ចុះហត្ថលេខា ក៏ត្រូវបានច្បាប់ទទួលស្គាល់ថាចុះហត្ថលេខាផងដែរ ដរាបណាបានធ្វើដូចខាងលើនេះ។

ការចាត់ចែងទ្រព្យសម្បត្តិដោយធ្វើឡើងតាមរយៈការធ្វើមតកសាសន៍គឺជាការបង្ហាញឆន្ទៈមួយប្រភេទដែលមានលក្ខណៈឯកតោភាគី ដោយមិនត្រូវការស្វ័ការពីភាគីណាមួយផ្សេងទៀតដើម្បីឱ្យការបង្ហាញឆន្ទៈនោះមានសុពលភាពឡើយ។ យ៉ាងណាមិញ ការបង្ហាញឆន្ទៈមួយបែបទៀតដែលបុគ្គលអាចចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនទុកមុនពេលដែលខ្លួនទទួលមរណភាពនោះគឺ ការធ្វើប្រទានកម្មដោយមូលហេតុមរណភាព។ ការបង្ហាញឆន្ទៈប្រភេទចុងក្រោយនេះគឺជាការធ្វើឡើងនូវកិច្ចសន្យាដោយតម្រូវឱ្យមានការយល់ព្រមទទួលពីភាគីថានឹងទទួលនូវទ្រព្យដែលជាកម្មវត្ថុនៃកិច្ចសន្យាប្រទានកម្មដោយមូលហេតុមរណភាពនេះ ទើបអាចមានសុពលភាព។ ការតម្រូវឱ្យមានស្វ័ការនៅក្នុងប្រទានកម្មដោយមូលហេតុមរណភាពនេះគឺជាភាពខុសគ្នារវាងប្រទានកម្មដោយមូលហេតុមរណភាព និង មតកសាសន៍។ ចំណែកឯចំណុចដែលសង្កេតឃើញថា ការបង្ហាញឆន្ទៈពីរប្រភេទនេះមានភាពដូចគ្នានោះគឺ ចំណុចពេលដែលអានុភាពរបស់វាកើតឡើង ពោលគឺ មតកសាសន៍ និងប្រទានកម្មដោយមូលហេតុមរណភាពបង្កើតអានុភាពនៅពេលដែលម្ចាស់បណ្តាំ ឬទាយកទទួលមរណភាព។ ទោះជាយ៉ាងណាក្តី ទាក់ទងនឹងរបបសន្តតិកម្មតាមមតកសាសន៍នេះ ក៏កើតមានបញ្ហាមួយចំនួនផងដែរ។

## ចំណោទបញ្ហា

តើបញ្ហាសន្តតិកម្មតាមមតកសាសន៍មានអ្វីខ្លះ ហើយមានការពិភាក្សាបែបណាខ្លះអំពីបញ្ហាទាំងនោះ?

## គោលបំណងនៃការស្រាវជ្រាវ

ដើម្បីធ្វើការស្រាយបំភ្លឺចំណោទបញ្ហាខាងលើនេះ គោលបំណងនៃសារណានេះ គឺ ធ្វើការសិក្សាអំពីវិធានគតិយុត្តដែលបញ្ញត្តអំពីសន្តតិកម្មតាមមតកសាសន៍នៅកម្ពុជា និងធ្វើការលើកឡើងនូវបញ្ហាមួយចំនួនដែលពាក់ព័ន្ធ ហើយថែមទាំងធ្វើការស្រាវជ្រាវ និងពិចារណាអំពីទស្សនៈយល់ឃើញរបស់អ្នកច្បាប់ និងបញ្ចេញមតិផ្ទាល់ខ្លួនចំពោះបញ្ហាទាំងនោះផងដែរ។

## ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ក្នុងអត្ថបទសារណានេះ យើងខ្ញុំនឹងធ្វើការសិក្សាស្រាវជ្រាវដោយផ្តោតសំខាន់អំពីបញ្ហា សន្តតិកម្មតាមមតកសាសន៍នៅកម្ពុជាតែប៉ុណ្ណោះ។ ក៏ប៉ុន្តែ ដោយហេតុថាចំនួននៃការវិភាគវែកញែកដោយអ្នកច្បាប់នៅកម្ពុជាអំពីបញ្ហាទាំងនោះនៅមានកម្រិត ដូច្នេះ ដើម្បីធ្វើការបំពេញបន្ថែមនូវកង្វះខាតនេះ យើងខ្ញុំក៏នឹងធ្វើការ

សិក្សាស្រាវជ្រាវអំពី ទស្សនៈ ក៏ដូចជាការយល់ឃើញចំពោះបញ្ហាពាក់ព័ន្ធដែលត្រូវបានធ្វើឡើងដោយអ្នកច្បាប់នៅប្រទេសជប៉ុនផងដែរ ចំពោះផ្នែកដែលចាំបាច់។

## សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ នឹងចូលរួមចំណែកជាស្នាដៃស្រាវជ្រាវមួយដែលបន្សល់ទុកនូវលើកឡើងនូវបញ្ហាច្បាប់ស្តីពីសន្តតិកម្មតាមមតកសាសន៍ និងការបញ្ចេញគំនិតទស្សនៈរបស់អ្នកច្បាប់ព្រមទាំងស្នេចំពោះបញ្ហាទាំងនោះ ដែលវាអាចជាចំណុចចាប់ផ្តើមធ្វើឱ្យការវិភាគវែកញែកនឹងត្រូវបានយកទៅបន្តទៀត ដើម្បីអាចរកឃើញនូវដំណោះស្រាយដែលល្អបំផុតសម្រាប់បញ្ហាសន្តតិកម្មតាមមតកសាសន៍ដែលកើតមាននៅកម្ពុជា។

## វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ដើម្បីឱ្យសម្រេចបាននូវការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំធ្វើការស្វែងរកឯកសារជាច្រើនដូចជា ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ឯកសារសមិទ្ធិផលដែលត្រូវបានចងក្រងដោយស្ថាប័នដែលមានជំនាញពាក់ព័ន្ធ ដូចជា ក្រសួងយុត្តិធម៌ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន សៀវភៅច្បាប់ដែលចងក្រងដោយសាស្ត្រាចារ្យជប៉ុន ទិន្នន័យ ពត៌មានដោយការិយាល័យច្បាប់ជាដើម។

បន្ទាប់មក យើងខ្ញុំធ្វើការរៀបរៀង បញ្ហានៃសន្តតិកម្មតាមតមកសាសន៍ ទ្រឹស្តីទាំងឡាយអំពីសន្តតិកម្មតាមមតកសាសន៍ដែលមាននៅក្នុងក្របខណ្ឌក្រមរដ្ឋប្បវេណីនៃព្រះរាជាណាក្រកម្ពុជា និងទស្សនៈ ការយល់ឃើញចំពោះបញ្ហាទាំងនោះ រួចដោយមានបញ្ចេញមតិផ្ទាល់ខ្លួនផងដែរ។

## រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងអត្ថបទសារណានេះ យើងធ្វើការបែងចែកជាពីរជំពូកធំៗ គឺ ជំពូកទី១ និងជំពូកទី២។ ជំពូកទី១នឹងធ្វើការបកស្រាយអំពីបញ្ហានៅក្នុងទិដ្ឋភាពនៃការបង្កើតមតកសាសន៍ និងជំពូកទី២ នឹងធ្វើការបកស្រាយអំពីបញ្ហានៅក្នុងទិដ្ឋភាពនៃការប្រតិបត្តិមតកសាសន៍។

ជំពូកទី១ នឹងត្រូវបានបែងចែកជា ២ ផ្នែកធំៗ ដែលក្នុងនោះ ផ្នែកទី១ នឹងធ្វើការបកស្រាយពី បញ្ហានៃល័ក្ខខ័ណ្ឌសុពលភាពនៃមតកសាសន៍ និង ផ្នែកទី២ នឹងធ្វើការបកស្រាយពី បញ្ហានៃខ្លឹមសារមតកសាសន៍ ។

ជំពូកទី២ នឹងត្រូវបានបែងចែកជា ២ ផ្នែកធំៗ ដែលក្នុងនោះ ផ្នែកទី១ នឹងធ្វើការបកស្រាយពី បញ្ហានៃការបញ្ជាក់ពីអត្ថិភាពនៃមតកសាសន៍ និង ផ្នែកទី២ នឹងធ្វើការបកស្រាយពី បញ្ហានៃអានុភាពរវាងមតកសាសន៍ និងប្រទានកម្មដោយមូលហេតុមរណភាព និង បញ្ហានៃការបែងចែកមត៌ក។

ជាចុងបញ្ចប់ យើងខ្ញុំនឹងធ្វើការសន្និដ្ឋាន បន្ទាប់មកធ្វើការសង្ខេបឡើងវិញនូវបញ្ហាទាំងអស់ និងផ្តល់នូវអនុសាសន៍ចំពោះបញ្ហាទាំងនោះផងដែរ។

# ជំពូកទី១ បញ្ហានៅក្នុងទិដ្ឋភាពនៃការបង្កើតមតកសាសន៍

ការបង្កើតមតកសាសន៍គឺជាសកម្មភាពគតិយុត្តមួយប្រភេទក្នុងចំណោមសកម្មភាពគតិយុត្តផ្សេងទៀត ដែលអាចបង្កើតឱ្យមានអានុភាពគតិយុត្តទៅលើការចាត់ចែងទ្រព្យសម្បត្តិរបស់ម្ចាស់បណ្ដាំបន្ទាប់ពីមរណភាពរបស់ខ្លួន។ ដូច្នេះ ការបង្កើតនូវមតកសាសន៍មួយឱ្យមានអានុភាពតាមផ្លូវច្បាប់គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីបំពេញនូវឆន្ទៈចុងក្រោយរបស់ម្ចាស់បណ្ដាំ។ ក៏ប៉ុន្តែ ទោះបីជាបុគ្គលនោះជាម្ចាស់បណ្ដាំក៏ដោយ ក៏ការបង្កើតមតកសាសន៍អាចមានអានុភាពគតិយុត្តបានជារាបណា មតកសាសន៍នោះត្រូវបានធ្វើឡើងដោយស្របតាមបទប្បញ្ញត្តិដែលត្រូវបានបញ្ញត្តដោយក្រមរដ្ឋប្បវេណីរបស់កម្ពុជា ពោលគឺមិនអាចធ្វើឡើងដោយតាមតែអំពើចិត្តរបស់ម្ចាស់បណ្ដាំទាំងស្រុងឡើយ។

ដើម្បីបកស្រាយឱ្យបានក្បោះក្បាយទាក់ទងនឹងបញ្ហានៅក្នុងទិដ្ឋភាពនៃការបង្កើតមតកសាសន៍ យើងនឹងធ្វើការបែងចែកការបកស្រាយជា ២ ផ្នែក ដោយ ផ្នែកទី១ នឹងបកស្រាយពី បញ្ហានៃល័ក្ខខ័ណ្ឌសុពលភាពនៃមតកសាសន៍ និង ផ្នែកទី២ នឹងបកស្រាយពី បញ្ហានៃខ្លឹមសារមតកសាសន៍។

## ផ្នែកទី១ បញ្ហានៃល័ក្ខខ័ណ្ឌសុពលភាពនៃមតកសាសន៍

ដើម្បីឱ្យមតកសាសន៍មានសុពលភាព ត្រូវគោរពតាមល័ក្ខខ័ណ្ឌ ២ សំខាន់ៗគឺ ទី១ រូបវន្តបុគ្គលត្រូវមានសមត្ថភាពក្នុងការធ្វើមតកសាសន៍នាពេលធ្វើមតកសាសន៍ (សមត្ថភាពក្នុងការធ្វើមតកសាសន៍) និង ទី២ មតកសាសន៍ត្រូវធ្វើដោយផ្អែកលើទម្រង់ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី (ភាពចាំបាច់នៃទម្រង់មតកសាសន៍)។

ដើម្បីបកស្រាយអំពីបញ្ហានៃល័ក្ខខ័ណ្ឌសុពលភាពនៃមតកសាសន៍ឱ្យបានគ្រប់ជ្រុងជ្រោយ នៅផ្នែកទី១ ត្រូវបានបែងចែកជា ២ កថាខណ្ឌគឺ កថាខណ្ឌទី១ នឹងបកស្រាយពី បញ្ហានៃល័ក្ខខ័ណ្ឌសមត្ថភាពក្នុងការធ្វើមតកសាសន៍ និង កថាខណ្ឌទី២ នឹងបកស្រាយពី បញ្ហានៃល័ក្ខខ័ណ្ឌនៃភាពចាំបាច់នៃទម្រង់មតកសាសន៍។

### កថាខណ្ឌទី១ បញ្ហានៃល័ក្ខខ័ណ្ឌសមត្ថភាពក្នុងការធ្វើមតកសាសន៍

#### ក. សមត្ថភាពក្នុងការធ្វើមតកសាសន៍

ល័ក្ខខ័ណ្ឌទី ១ ដែលត្រូវបំពេញដើម្បីឱ្យមតកសាសន៍មានសុពលភាពគឺ ម្ចាស់បណ្ដាំត្រូវមានសមត្ថភាពក្នុងការធ្វើមតកសាសន៍នាពេលធ្វើមតកសាសន៍ ។ ពោលគឺ ម្ចាស់បណ្ដាំត្រូវតែជា **នីតិជន ឬ អនីតិជនដែលទទួលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា** ហើយជននោះថែមទាំងត្រូវ**មានសមត្ថភាពខាងឆន្ទៈនៅពេលធ្វើមតកសាសន៍**ផងដែរ[1]។

[1] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្លឹះទី៨-៩ ទំព័រ. ៣០, ៣១

ជាគោលការណ៍ ដើម្បីធ្វើសកម្មភាពគតិយុត្តណាមួយឱ្យមានអានុភាពតាមផ្លូវច្បាប់ វាចាំបាច់ណាស់ដែលបុគ្គលនោះត្រូវមានសមត្ថភាពខាងឆន្ទៈ។ ក្រមរដ្ឋប្បវេណីកម្ពុជាពុំបានបញ្ញត្តអំពីនិយមន័យនៃសមត្ថភាពខាងឆន្ទៈនោះទេ តែយើងអាចទាញយកនិយមន័យរបស់វាបានតាមរយៈមាត្រា ១៤ (ការខ្វះសមត្ថភាពខាងឆន្ទៈ) បានថា **សមត្ថភាពខាងឆន្ទៈ** គឺជាសមត្ថភាពដែលអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដែលជាភាគី[2] ។ វ៉ៃ និង សមត្ថភាពខាងឆន្ទៈរបស់រូបវន្តបុគ្គលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ដោយច្បាប់បានទទួលស្គាល់ថា រូបវន្តបុគ្គលដែលមានសមត្ថភាពខាងឆន្ទៈពេញលេញ គឺជានីតិជន ជាជនដែលមានអាយុគ្រប់ ១៨ ឆ្នាំឡើងទៅ[3] ឬ ជននោះបានដល់នីតិភាព (តាមរយៈការទទួលបានអត្តាធីនភាពជាដើម) ហើយជនដែលមានសមត្ថភាពខាងឆន្ទៈនេះអាចធ្វើសកម្មភាពគតិយុត្តបាន ដែលក្នុងនោះរួមមាន កិច្ចសន្យា និង សកម្មភាពឯកតោភាគី។ នៅក្នុងនោះ ក្រៅពីអនីតិជន មានជនមួយក្រុមដែលទោះបីជាពួកគេជា នីតិជនហើយក៏ដោយ ក៏ត្រូវបានកម្រិតសមត្ថភាពធ្វើសកម្មភាពផងដែរ ដោយសារតែជនទាំងនេះខ្វះសមត្ថភាពខាងឆន្ទៈ ដូចជា ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ[4] ។ របបនេះគឺត្រូវបានបង្កើតឡើងដើម្បីការពារកុំឱ្យមានការទទួលរងនូវការខូចខាតដែលកើតមានឡើងដោយសារកិច្ចការជួញដូររបស់ជនដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យ[5]។

នៅក្នុងទិដ្ឋភាពនៃការបង្កើតមតកសាសន៍វិញ ក្រៅពីនីតិជនដែលមានសមត្ថភាពខាងឆន្ទៈពេញលេញធម្មតា ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ក៏អាចធ្វើមតកសាសន៍បានផងដែរ[6]។ ការដែលអនុញ្ញាតឱ្យជនទាំងនេះធ្វើមតកសាសន៍គឺដោយសារអានុភាពនៃមតកសាសន៍នោះនឹងពុំមានឥទ្ធិពលដល់ជីវិភាពរស់នៅរបស់ពួកគេនោះទេ ពីព្រោះមតកសាសន៍នោះនឹងមានអានុភាពនៅក្រោយពេលដែលជនទាំងនោះ បានទទួលមរណភាពទៅហើយ[7] ។ នេះបានបញ្ជាក់ឱ្យឃើញថា នីតិករបានធ្វើឱ្យមានសង្គតិភាពជាមួយនឹងគោលបំណងសំខាន់នៃរបបនៃការកម្រិតសមត្ថភាពធ្វើសកម្មភាពដែរ។ ក៏ប៉ុន្តែ ការធ្វើមតកសាសន៍ដោយជនដែលត្រូវបានកម្រិតសមត្ថភាពធ្វើសកម្មភាពទាំងពីរប្រភេទនេះ ត្រូវតែបំពេញតាមល័ក្ខខ័ណ្ឌមួយ

---

[2] ក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា ១៤

[3] វចនានុក្រមនៃក្រមរដ្ឋប្បវេណី ទំព័រ. ១០

[4] ក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា ១៦

[5] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ១ គន្លឹទី១-ទី៣ ទំព័រ ១១

[6] ក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា មាត្រា ១១៦៨ កថាខណ្ឌទី២,
ក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា ១១៦៩ កថាខណ្ឌទី២

[7] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្លឹទី ៨-ទី៩ ទំព័រ. ៣០,៣១

ចំនួនដែលត្រូវបានកំណត់ត្រង់មាត្រា ១១៧៦ ស្តីពីមតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ ដូចជា ត្រូវជាសះស្បើយមួយរយៈពេលឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនជាដើម។ ចំណុចនេះស្តែងឱ្យឃើញថា ទោះបីជាជនទាំងនេះអាចធ្វើបានមតកសាសន៍បានក៏ដោយ ក៏សមត្ថភាពខាងឆន្ទៈនៅក្នុងពេលធ្វើមតកសាសន៍ នៅតែជាល័ក្ខខ័ណ្ឌមួយដ៏ចាំបាច់ដដែល។

ម្យ៉ាងទៀត ទោះបីជាជននោះពុំមែនជាជនដែលត្រូវបានកម្រិតសមត្ថភាពធ្វើសកម្មភាពក៏ដោយ ក្នុងករណីដែលនៅពេលធ្វើមតកសាសន៍ ម្ចាស់បណ្តាំមានសភាពស្រវឹងស្រាខ្លាំង ឬ ជំងឺវង្វេងវង្វាន់ជាដើម នោះនឹងធ្វើឱ្យមតកសាសន៍ត្រូវចាត់ទុកថាជាមោឃៈ[8]។

ហេតុដូចបានបង្ហាញខាងលើនេះ សមត្ថភាពខាងឆន្ទៈ របស់ម្ចាស់បណ្តាំ គឺជាល័ក្ខខ័ណ្ឌមួយដ៏សំខាន់ដើម្បីឱ្យមតកសាសន៍របស់ម្ចាស់បណ្តាំនោះមានសុពលភាពទៅបាន។

**ខ. គុណភាពនៃឆន្ទៈ**

ដោយហេតុថា មតកសាសន៍គឺជាការបង្ហាញឆន្ទៈចុងក្រោយដោយឯកតោភាគីរបស់មតកជន ហេតុនេះ **គុណភាពនៃឆន្ទៈ** ដែលបានបង្ហាញនោះក៏មានសារៈសំខាន់ជាខ្លាំងផងដែរ ដែលវាត្រូវបានស្តែងឡើងតាមរយៈ **គោលគំនិតនៃការផ្តល់ការគោរពដល់ឆន្ទៈចុងក្រោយរបស់មតកកជន** ដូចជា ឆន្ទៈនោះត្រូវជាឆន្ទៈពិតប្រាកដ និងឆន្ទៈចុងក្រោយរបស់មតកជន។ តាមរយៈគោលគំនិតនេះហើយ ដែលនាំឱ្យមានការទទួលស្គាល់តែចំពោះសុពលភាពនៃមតកសាសន៍ដែលត្រូវបានធ្វើជាលើកចុងក្រោយដោយមតកជនដូចគ្នា។ លើសពីនេះ ដូចនេះពាក់ព័ន្ធនឹងវិការៈ ដោយសារតែឆន្ទៈត្រូវតែជាឆន្ទៈពិតប្រាកដរបស់មតកជន ដូចនេះ ដើម្បីការពារក្នុងករណីមតកជនត្រូវបានជនណាម្នាក់ឆបោក ឬ គម្រាមកំហែងឱ្យសរសេរមតកសាសន៍ដែលមានខ្លឹមសារផ្តល់ផលប្រយោជន៍ដល់ជននោះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តអំពីអភ័ព្វបុគ្គលនៃសន្តតិកម្មផងដែរ ត្រង់ចំណុច គ ដល់ ង នៃមាត្រា ១១៥០ នៃក្រមរដ្ឋប្បវេណីកម្ពុជា។

ទោះជាយ៉ាងណាក្តី ការធ្វើមតកសាសន៍គឺជាសកម្មភាពគតិយុត្តមួយដែរ ដូច្នេះ ក្នុងករណីដែលឆន្ទៈនោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ឆន្ទៈដែលបង្ហាញតាមមតកសាសន៍នេះ ក៏ត្រូវចាត់ទុកជាកម្មវត្ថុនៃមោឃភាពផងដែរ ដោយផ្អែកលើបទប្បញ្ញត្តិស្តីពីមោឃភាពនៃកិច្ចសន្យាក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីនេះ[9]។

**គ. បញ្ហានៃល័ក្ខខ័ណ្ឌសមត្ថភាពក្នុងការធ្វើមតកសាសន៍**

ពាក់ព័ន្ធនឹងល័ក្ខខ័ណ្ឌខាងលើនេះ ឃើញថាមានបញ្ហាចំនួន ២ កើតឡើង។

[8] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្លីទី ៨-៩ ទំព័រ. ៣១

[9] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២ គន្លីទី៤ ទំព័រ.៦៥

បញ្ហាទី១ គឺ បញ្ហាអំពីការពិនិត្យទៅលើអត្ថិភាព និងនត្ថិភាពនៃសមត្ថភាពខាងឆន្ទៈរបស់មតកជនពោលគឺថា តើត្រូវពិនិត្យយ៉ាងដូចម្តេច ដើម្បីឱ្យដឹងថាមតកជនមានសមត្ថភាពខាងឆន្ទៈនាពេលដែលបានធ្វើមតកសាសន៍។

ជុំវិញបញ្ហានេះ ប្រសិនបើយើងធ្វើការពិនិត្យមើលទៅលើបទពិសោធន៍នៃប្រទេសជប៉ុនឃើញថា ការកំណត់អំពីអត្ថិភាព និងនត្ថិភាពនៃសមត្ថភាពនេះនឹងត្រូវបានសម្រេចដោយការវិនិច្ឆ័យតាមលក្ខណៈច្បាប់ដោយគោរពទៅលើការវិនិច្ឆ័យតាមលក្ខណៈវេជ្ជសាស្ត្ររបស់វេជ្ជបណ្ឌិតផងដែរ។ នោះមានន័យថា សមត្ថភាពក្នុងការធ្វើមតកសាសន៍ពុំតែងតែត្រូវបានបដិសេធគ្រប់ពេលនោះទេ ទោះបីជាវេជ្ជបណ្ឌិតបានធ្វើការវិនិច្ឆ័យថាមតកជនមានជំងឺវង្វេងក៏ដោយ។ តាមរយៈយុត្តិសាស្ត្រកន្លងមកនៃប្រទេសជប៉ុន ដើម្បីកំណត់ពីអត្ថិភាព និងនត្ថិភាពនៃសមត្ថភាពនេះ ភាគច្រើនគេតែងតែធ្វើការពិចារណាទៅលើធាតុ ៣ សំខាន់ៗគឺ ទិដ្ឋភាពវេជ្ជសាស្ត្រទាក់ទងនឹងសតិ ភាពស្មុគ្រស្មាញនៃខ្លឹមសារមតកសាសន៍ និង បុព្វហេតុ មូលហេតុនៃការធ្វើមតកសាសន៍ ទំនាក់ទំនងរវាងមតកជន និងសន្តតិជន អច្ច័យលាភីជាដើម។ ទី១ ទិដ្ឋភាពវេជ្ជសាស្ត្រទាក់ទងនឹងសតិ គឺត្រូវពិនិត្យមើលថាតើនៅពេលដែលធ្វើមតកសាសន៍ មតកជនមានស្ថានភាពបែបណា ហើយប្រសិនបើមានលិខិតបញ្ជាក់ពីវេជ្ជបណ្ឌិតអំពីជំងឺផ្នែកសតិ ឬ ពិន្ទុនៃតេស្តវាស់ពីកម្រិតនៃជំងឺវង្វេងជាដើម គេនឹងពិនិត្យលិខិតទាំងនោះ។ ទី២ ភាពស្មុគ្រស្មាញនៃខ្លឹមសារមតកសាសន៍ ក៏ជាចំណុចដែលអាចត្រូវបានគេយកមកធ្វើការពិចារណាផងដែរ ដែលនៅក្នុងនោះ មានទំនោរមួយគឺ មតកសាសន៍ណាដែលមានខ្លឹមសារងាយស្រួលយល់នឹងងាយត្រូវបានគេវិនិច្ឆ័យថាមតកជនមានសមត្ថភាពខាងឆន្ទៈ។ ទី៣ ទាក់ទងនឹង បុព្វហេតុ មូលហេតុនៃការធ្វើមតកសាសន៍ ទំនាក់ទំនងរវាងមតកជន និងសន្តតិជន អច្ច័យលាភីជាដើម ត្រង់ចំណុចនេះ គេមិនពិចារណាទៅលើមតកសាសន៍នោះទេ គឺ គេពិចារណាទៅលើចំណុចថា តើអាចវិនិច្ឆ័យមតកសាសន៍នោះ ថាមានហេតុផលសមរម្យដែរឬទេ អំពីការដែលមតកជនបានបង្ហាញឆន្ទៈដូចមានក្នុងមតកសាសន៍នោះ ដូចជាឧទាហរណ៍ថាមតកជនពុំមានសហព័ទ្ធ និងកូននោះទេ តែមានបងប្អូនបង្កើត ហើយមតកជនបានទទួលការមើលថែយ៉ាងល្អពីបងប្រុស ចំណែកប្អូនប្រុសវិញពុំដែលទាក់ទងមកគាត់នោះទេ ដូច្នេះ ប្រសិនបើខ្លឹមសារនៃមតកសាសន៍បានកំណត់ឱ្យបងប្រុសនោះទទួលមត៌ក នោះឃើញថាវាជាការសមស្របហើយ។[10]

---

[10] ការិយាល័យច្បាប់ Horizon Partners, មេធាវី ថាជិម៉ះ ណាអុគិ, *តើអ្វីទៅជាសមត្ថភាពក្នុងការធ្វើមតកសាសន៍ដើម្បីសរសេរមតកសាសន៍? ៣ ចំណុចដើម្បីវិនិច្ឆ័យពីអត្ថិភាព និងនត្ថិភាពនៃសមត្ថភាពក្នុងការធ្វើមតកសាសន៍*
(https://www.korei-support.net/article/igon-nouryoku)

ពាក់ព័ន្ធនឹងធាតុទី២ ដែលត្រូវបានគេយកមកពិចារណាខាងលើនេះ ឃើញថាមិនសូវមានភាពសមហេតុផលនោះទេ។ មតកជនអាចបង្ហាញឆន្ទៈយ៉ាងណាក៏បានចំពោះការចាត់ចែងអំពីទ្រព្យសម្បត្តិរបស់ខ្លួន ដូច្នេះការដែលមតកជនងាយត្រូវបានវិនិច្ឆ័យថា គ្មានសមត្ថភាពក្នុងការមតកសាសន៍ដោយសារតែមតកសាសន៍មានខ្លឹមសារស្មុគស្មាញនោះ ហាក់ដូចជាមានទំនោរទៅរកការមិនផ្តល់សិទ្ធិសេរីភាពដល់មតកជន ក៏ដូចជាគោរពឆន្ទៈដែលជាឆន្ទៈចុងក្រោយរបស់មតកជននោះទេ។

បញ្ហាទី២ គឺ បញ្ហាអំពីស្តង់ដារនៃការវិនិច្ឆ័យថាតើឆន្ទៈនៃមតកជនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈដែរឬយ៉ាងណា។

ជាគោលការណ៍ យោងតាមមាត្រា ៣៥៤ នៃក្រមរដ្ឋប្បវេណីកម្ពុជា សកម្មភាពគតិយុត្តទាំងឡាយដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ នឹងត្រូវបានចាត់ទុកថាជា មោឃៈ ក៏ប៉ុន្តែចំពោះការធ្វើអច្ច័យទាន ក្នុងករណីដែលអច្ច័យលាភីជាជនដែលមានទំនាក់ទំនងក្រៅអាពាហ៍ពិពាហ៍ជាមួយមតកជននៅពេលរស់នោះ តើសកម្មភាពនេះត្រូវបានចាត់ទុកថាជាសកម្មភាពដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អដែរ ឬទេ?

ដោយលើកឧទាហរណ៍ចំពោះករណីនេះពីប្រទេសជប៉ុន លោក ក មាន ខ ជាសហព័ទ្ធ ហើយ គ ឃ និង ង ជាកូន។ លោក ក បានមានទំនាក់ទំនងក្រៅអាពាហ៍ពិពាហ៍ជាមួយ ច ដោយមិនឱ្យគ្រួសាររបស់ខ្លួនបានដឹងអស់រយៈពេល ១០ ឆ្នាំ។ លោក ក បានកំណត់នៅក្នុងមតកសាសន៍របស់ខ្លួនថា នៅក្នុងទ្រព្យសម្បត្តិរបស់ខ្លួនធ្វើអច្ច័យទានឱ្យទៅ ច ចំនួន ១០០០ ម៉ឺនយ៉េន (ប្រហែល ៧៥០០០ ដុល្លារ)[11]។

ចំពោះករណីនេះ វាគឺជាបញ្ហានៃការធ្វើអច្ច័យទានក្នុងករណីដែលអច្ច័យលាភីជាជនដែលមានទំនាក់ទំនងក្រៅអាពាហ៍ពិពាហ៍ជាមួយមតកជននៅពេលរស់នោះ ដែលសកម្មភាពនេះត្រូវបានចាត់ទុកថាជាសកម្មភាពដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ហើយតើអច្ច័យទាននោះនឹងត្រូវបានធ្វើមោឃភាព ឬ យ៉ាងណា។

ពាក់ព័ន្ធនឹងបញ្ហាខាងលើនេះ នៅឯប្រទេសជប៉ុនបានធ្វើការបកស្រាយថាតើអច្ច័យទាននេះ ត្រូវចាត់ទុកជាជាសកម្មភាពដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ដែរ ឬ យ៉ាងណានោះ គឺដោយធ្វើការពិចារណាលើ ២ ចំណុចសំខាន់ៗ[12]៖

[11] ស៊ិអូមិ យ៉ូស៊ីអូ *ការពន្យល់លម្អិត ច្បាប់សន្តតិកម្ម* (កូប៊ឹងដូ , បោះពុម្ពឆ្នាំ ២០១៨) ទំព័រ ៥១១, 潮見佳男『詳解　相続法』（弘文堂、2018 年）

[12] ការិយាល័យប្រឹក្សាសន្តតិកម្មសាប់ប៉ូរ៉ូ, *ប្រទានកម្មទៅឱ្យដៃគូក្រៅអាពាហ៍ពិពាហ៍នឹងក្លាយជាមោឃៈ?* (https://www.sapporo-yuigon.jp/15052140701090)

**១.** គោលបំណងនៃអច្ច័យទាននោះ មានន័យថា តើការធ្វើអច្ច័យទាននេះ ធ្វើឡើងដើម្បីគោលបំណងអ្វី? តើការធ្វើអច្ច័យទាននេះធ្វើឡើងក្នុងគោលបំណងដើម្បីបន្តរក្សានូវទំនាក់ទំនងនោះដែរ ឬ ទេ?

**២.** ឥទ្ធិពលនៃអច្ច័យទាននោះ មានន័យថា តើការធ្វើអច្ច័យទាននេះ មានផលប៉ះពាល់ ឬ ផ្តល់ការគម្រាមកំហែងដល់ការរស់នៅរបស់សន្តតិជនរបស់មតកជននោះដែរ ឬ ទេ?

តាមរយៈឧទាហរណ៍ខាងលើ ដោយតុលាការយល់ឃើញថា ការធ្វើអច្ច័យទាននេះគឺធ្វើឡើងដើម្បីក្នុងការរក្សា និង ចិញ្ចឹមជីវិតរបស់ ច ដែលការរស់នៅរបស់ ច គឺអាស្រ័យទៅលើលោក ក ហេតុនេះហើយការធ្វើអច្ច័យទាននេះគឺមិនមានបំណងក្នុងដើម្បីរក្សា និង បន្តទំនាក់ទំនងក្រៅអាពាហ៍ពិពាហ៍រវាងលោក ក និង ច ឡើយ។ លើសពីនេះទៅទៀត ការកំណត់អច្ច័យទាននៅក្នុងមតកសាសន៍នោះ មិនមានការប៉ះពាល់ ឬ គម្រាមកំហែងដល់មូលដ្ឋាននៃការរស់នៅរបស់សន្តតិជនរបស់លោក ក ឡើយ។ ដូចនេះ តុលាការកំពូលក៏បានសម្រេចថា ការធ្វើអច្ច័យទានក្នុងករណីនេះមិនមែនជាសកម្មភាពដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អឡើយ ហើយក៏មិនត្រូវបានមោឃភាពដែរ[13]។

ជាសន្និដ្ឋាន ដោយសារតែករណីដែលអច្ច័យទាន និង ទំនាក់ទំនងក្រៅអាពាហ៍ពិពាហ៍នេះ វាអាចមានភាពខុសៗគ្នាអាស្រ័យទៅតាមប្រភេទនៃករណី និង អង្គហេតុនីមួយៗ[14] ហេតុនេះហើយមិនមែនអច្ច័យទានដែលអច្ច័យលាភីជាជនដែលមានទំនាក់ទំនងក្រៅអាពាហ៍ពិពាហ៍ជាមួយមតកជននៅពេលរស់នោះ សុទ្ធតែមិនត្រូវបានមោឃភាព ឬ ត្រូវបានមោឃភាពទាំងអស់នោះដែរ គឺវាអាស្រ័យទៅតាមការពិចារណាតាមករណីនីមួយៗរៀងៗខ្លួន។ ក៏ប៉ុន្តែស្តង់ដារនៃការពិចារណានេះ គឺដោយយកចំណុចសំខាន់ចំនួន ២ ខាងលើយកមកពិចារណា រួចសម្រេចថាករណីនោះត្រូវចាត់ទុកជាសកម្មភាពដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ឬ យ៉ាងណា។

## កថាខណ្ឌទី២ បញ្ហានៃល័ក្ខខ័ណ្ឌនៃភាពចាំបាច់នៃទម្រង់នៃមតកសាសន៍

### ក. ទម្រង់នៃមតកសាសន៍សម្រាប់ស្ថានភាពធម្មតា

- មតកសាសន៍ដោយលិខិតយថាភូត

មតកសាសន៍ដោយលិខិតយថាភូតគឺជាទម្រង់មតកសាសន៍មួយប្រភេទដែលតម្រូវឱ្យមានការចូលរួមពីសារការី និងសាក្សីនៅពេលធ្វើ។ ទាក់ទងនឹងទម្រង់មតកសាសន៍នេះ មាត្រា ១១៧៣ នៃក្រមរដ្ឋប្បវេណីបានចែងថា៖

---

[13] ស៊ុអ៊ូមិ យ៉ូស៊ីអូ *ការពន្យល់លម្អិត ច្បាប់សន្តតិកម្ម* (កូប៊ឹងដូ , បោះពុម្ពឆ្នាំ ២០១៨) ទំព័រ ៤១១, 潮見佳男『詳解　相続法』（弘文堂、2018 年）

[14] http://orangelaw.jp/pdf/benkyokai/2018/08/180629_benkyokai.pdf

"១-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសារការី តាមទម្រង់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ខាងក្រោមនេះ។

២-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ

ក-ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច២(ពីរ)នាក់។

ខ-ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី។

គ-សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និងសាក្សីនោះស្តាប់។

ឃ-បន្ទាប់ពីម្ចាស់បណ្តាំ និងសាក្សី បានទទួលស្គាល់ថាកំណត់ជាលាយលក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និង លំនៅឋាន ហើយត្រូវចុះហត្ថលេខា រៀងៗខ្លួន។ ប៉ុន្តែបើម្ចាស់បណ្តាំ មិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និងហត្ថលេខាដូចកំណត់ខាងលើនេះ ដោយ សរសេរឈ្មោះ អាយុ និងលំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង។

ង-សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា។"

ដោយផ្អែកតាមបទប្បញ្ញត្តិនៃមាត្រាខាងលើនេះ ឃើញថា កាលណាបើម្ចាស់បណ្តាំធ្វើមតកសាសន៍ដែលមានទម្រង់ប្រភេទនេះ គឺជាគោលការណ៍តម្រូវឱ្យមានល័ក្ខខ័ណ្ឌមួយចំនួនដូចខាងក្រោមនេះ៖

- ម្ចាស់បណ្តាំត្រូវធ្វើឡើងនៅចំពោះមុខសារការី (មាត្រា ១១៧៣.១)
- មតកសាសន៍ត្រូវធ្វើឡើងដោយមានវត្តមានសាក្សីយ៉ាងតិច ២ (ពីរ) នាក់ (មាត្រា ១១៧៣.២.ក)
- ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍ចំពោះសារការី (មាត្រា ១១៧៣.២.ខ)
- សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និងសាក្សីនោះស្តាប់ (មាត្រា ១១៧៣.២.គ)។
- ម្ចាស់បណ្តាំ និងសាក្សី ត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និងលំនៅឋាន ហើយត្រូវចុះហត្ថលេខារៀងៗខ្លួន បន្ទាប់ពីបានទទួលស្គាល់ថាកំណត់ជាលាយលក្ខណ៍អក្សរដែលសារការីបានសរសេរនោះត្រឹមត្រូវហើយ។ ក៏ប៉ុន្តែ ករណីដែលម្ចាស់បណ្តាំ មិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និងហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និងលំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង(មាត្រា ១១៧៣.២.ឃ)។
- សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា(មាត្រា ១១៧៣.២.ង) ។ ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះ។

- គុណសម្បត្តិ

មតកសាសន៍ដោយលិខិតយថាភូតត្រូវបានគេចាត់ទុកថាមានគុណសម្បត្តិ២ធំៗគឺ គុណសម្បត្តិដែលទទួលបានដូចមតកសាសន៍ដទៃទៀត និង គុណសម្បត្តិដែលទទួលបានដោយសារតែវាជាមតកសាសន៍ដោយលិខិតយថាភូត[15]។

ទី១ គុណសម្បត្តិដែលទទួលបានដូចមតកសាសន៍ដទៃទៀត គឺសំដៅលើការដែលអាចបន្សល់ទុកនូវឆន្ទៈចុងក្រោយរបស់មតកជនដល់គ្រួសាររបស់គាត់ដូចមតកសាសន៍ទម្រង់ផ្សេងៗទៀតដែរ។ ចំណែកឯគុណសម្បត្តិទី២ គុណសម្បត្តិដែលទទួលបានដោយសារតែវាជាមតកសាសន៍ដោយលិខិតយថាភូត គឺសំដៅលើការបង្កើតបាននូវមតកសាសន៍ដែលមានការជឿជាក់ខ្ពស់។ ដូច្នេះ ខ្លឹមសារនៃមតកសាសន៍ដោយលិខិតយថាភូតមានភាគរយតិចតួចណាស់ ឬ ស្ទើរតែមិនអាចនឹងក្លាយទៅជាកម្មវត្ថុនៃមោឃភាពដោយសារតែភាពមិនច្បាស់លាស់តាមផ្លូវច្បាប់បាននោះទេ។

ម្យ៉ាងវិញទៀត ដោយសារតែនៅពេលដែលត្រូវអនុវត្តមតកសាសន៍ នោះមតកសាសន៍ដោយលិខិតយថាភូតនឹងដើរតួជាបន្ទាល់ដ៏រឹងមាំដែលអាចជឿទុកចិត្តបានចំពោះគ្រប់ភាគីទាំងអស់ រួមទាំងតុលាការផង ក្នុងករណីដែលវិវាទកើតឡើង។ គុណសម្បត្តិមួយចំនួនទៀតនៃទម្រង់មតកសាសន៍នេះគឺ ឆន្ទៈរបស់មតកជនមិនអាចត្រូវបានជំទាស់ប្រឆាំងបានឡើយដោយសារតែសារការីមានតួនាទីក្នុងការពិនិត្យសមត្ថភាពរបស់ម្ចាស់បណ្តាំក្នុងការធ្វើមតកសាសន៍ ឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ និង អនុលោមភាពនៃទម្រង់ និងខ្លឹមសារនៃមតកសាសន៍ទៅតាមច្បាប់ផងដែរ។ ជាចុងក្រោយ គុណសម្បត្តិនៃមតកសាសន៍ដោយលិខិតយថាភូត អាចត្រូវបានបើកនៅក្រៅតុលាការផងដែរ ដែលមតកសាសន៍ដែលមានទម្រង់ផ្សេងពីនេះពុំអាចបើកនៅក្រៅតុលាការបាននោះទេ (មាត្រា ១២១៣ កថាខណ្ឌទី២) ។

- គុណវិបត្តិ

ទោះបីជាមតកសាសន៍ដោយលិខិតយថាភូតមានគុណសម្បត្តិយ៉ាងណាក៏ដោយ ក៏វាអាចនឹងមានចំណុចមួយចំនួនដែលអាចចាត់ទុកបានថាជាគុណវិបត្តិ ដូចជា ការចំណាយទៅលើការបង់ថ្លៃធ្វើមតកសាសន៍ចំពោះការិយាល័យសារការី ដែលវាជាចំណាយច្រើនជាងការធ្វើមតកសាសន៍ទម្រង់ផ្សេងទៀត។ លើសពីនេះទៅទៀត ល័ក្ខខ័ណ្ឌតម្រូវឱ្យត្រូវមានសាក្សីដល់ទៅ២នាក់នៅក្នុងការធ្វើមតកសាសន៍ដោយលិខិតយថាភូតនេះ

[15] មជ្ឈមណ្ឌលជំនួយសន្តតិកម្ម, *តើមតកសាសន៍ដោយលិខិតយថាភូតជាអ្វី?*
(https://www.asahi.com/ads/sozoku_vs/column/will/01/)

ក៏ត្រូវបានគេចាត់ទុកថាជាគុណវិបត្តិផងដែរ ពីព្រោះថា គ្រួសារ (ជនដែលត្រូវបានសន្មតថាជាសន្តិជន អច្ច័យលាភី សហព័ទ្ធជាដើម) ពុំត្រូវបានអនុញ្ញាតឱ្យធ្វើជាសាក្សីនោះទេ[16] (មាត្រា ១១៧២)។

អ្វីដែលហាក់ដូចជាមានភាពមិនច្បាស់លាស់គឺត្រង់ចំណុចដែល មតកសាសន៍ដោយលិខិតយថាភូតត្រូវធ្វើឡើងដោយម្ចាស់បណ្តាំនៅចំពោះមុខសារការី ពោលគឺ ក្រមរដ្ឋប្បវេណីពុំបានបញ្ញត្តច្បាស់លាស់ពីចំនួនសារការី ថាតើតម្រូវឱ្យមានសារការីចំនួនប៉ុន្មានរូបដែលត្រូវមានវត្តមាននៅក្នុងពេលធ្វើមតកសាសន៍ទម្រង់នេះនោះទេ ខណៈពេលដែលចំនួនសាក្សីដែលត្រូវមានវត្តមានត្រូវបានកំណត់យ៉ាងច្បាស់។ នៅត្រង់ចំណុចនេះ ទោះបីជាបកស្រាយថាចំនួននៃសារការីដែលត្រូវមានវត្តមានគឺមិនត្រូវបានកំណត់នោះទេ ក៏មិនមានជាបញ្ហាអ្វីនោះដែរ ។

- មតកសាសន៍ដោយលិខិតឯកជន

មតកសាសន៍ទម្រង់ទីពីរ គឺ មតកសាសន៍ដោយលិខិតឯកជន ដែលមតកសាសន៍ទម្រង់នេះមិនមានការចូលរួមពីសារការីនោះទេ។ មាត្រា ១១៧៤ បានបញ្ញត្តអំពីមតកសាសន៍ដោយលិខិតឯកជនដូចខាងក្រោមៈ

> "១ - មតកសាសន៍ដោយលិខិតឯកជន ត្រូវធ្វើឡើង ដោយម្ចាស់បណ្តាំសរសេរពាក្យទាំងអស់ និង ចុះថ្ងៃខែឆ្នាំដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ។ មតកសាសន៍ដោយលិខិតឯកជនដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ ដែលត្រូវបានសរសេរដោយប្រើម៉ាស៊ីនដូចជាអង្គុលីលេខ ជាអាទិ៍ នឹងត្រូវចាត់ទុកជាមោឃៈ។
>
> ២ - ការបន្ថែម ការលុប ឬ ការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំមិនបានបង្ហាញនូវកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ ជាពិសេសបើមិនបានចុះហត្ថលេខាទេ។"

តាមរយៈបទប្បញ្ញត្តិខាងលើនេះ ឃើញថា កាលណាបើម្ចាស់បណ្តាំធ្វើមតកសាសន៍ដែលមានទម្រង់ប្រភេទនេះ គឺជាគោលការណ៍តម្រូវឱ្យមានល័ក្ខខ័ណ្ឌមួយចំនួនដូចជា ក.ម្ចាស់បណ្តាំសរសេរពាក្យទាំងអស់ និងចុះថ្ងៃខែឆ្នាំ និងហត្ថលេខាដោយខ្លួនឯង ខ. ល័ក្ខខ័ណ្ឌ ក ត្រូវធ្វើឡើងដោយមិនមានជំនួយពីអ្នកដទៃ ឬម៉ាស៊ីន ដូចជាអង្គុលីលេខជាអាទិ៍ និង គ. ម្ចាស់បណ្តាំត្រូវបង្ហាញនូវកន្លែង និងសរសេរបន្ថែមនូវហេតុ និងចុះហត្ថលេខានៃការកែប្រែ ប្រសិនបើមាន។

- គុណសម្បត្តិ

មតកសាសន៍ដោយលិខិតឯកជនត្រូវបានគេចាត់ទុកថាមានគុណសម្បត្តិ ចំនួន ៤។

---

[16] មជ្ឈមណ្ឌលជំនួយសន្តតិកម្ម, *តើមតកសាសន៍ដោយលិខិតយថាភូតជាអ្វី?* (https://www.asahi.com/ads/sozoku_vs/column/will/01/)

គុណសម្បត្តិទី១ គឺម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ទម្រង់នេះដោយពុំចាំបាច់មានវត្តមានសាក្សី ហើយអាចធ្វើនៅទីណាក៏បានដោយខ្លួនឯង។ ពិតណាស់ ដោយសារតែលក្ខខ័ណ្ឌនៃការធ្វើមតកសាសន៍ទម្រង់នេះពុំតម្រូវឱ្យមានវត្តមានសាក្សី និងសារការីឡើយ។

ចំណែកឯគុណសម្បត្តិទី២ គឺ ម្ចាស់បណ្តាំពុំចាំបាច់ចំណាយប្រាក់ដើម្បីធ្វើមតកសាសន៍ប្រភេទនេះនោះទេ ដោយសារតែម្ចាស់បណ្តាំជាអ្នកសរសេរដោយដៃខ្លួនឯងផ្ទាល់ ដូច្នេះ ពុំចាំបាច់ចំណាយថ្លៃពឹងពាក់សាក្សី ឬសារការីនោះទេ។ ចំពោះគុណសម្បត្តិទី៣ គឺ ទម្រង់នៃមតកសាសន៍មានភាពងាយស្រួល ពោលគឺគ្រាន់តែមានបញ្ជាក់ចំណុចដែលចាំបាច់គឺមានសុពលភាពរួចទៅហើយ។

ជាចុងក្រោយ គុណសម្បត្តិទី៤ គឺម្ចាស់បណ្តាំអាចលាក់ការសម្ងាត់នូវអត្ថិភាព និងអត្ថន័យនៃមតកសាសន៍របស់ខ្លួនបាន[17]។

- គុណវិបត្តិ

ទោះជាយ៉ាងណាក៏ដោយ មតកសាសន៍ទម្រង់នេះក៏មានគុណវិបត្តិច្រើនផងដែរ ហើយគុណវិបត្តិរបស់វាត្រូវបានគេសំដៅទៅលើ ៤ ចំណុច។

គុណវិបត្តិទី១ គឺវាអាចមានហានិភ័យថា មតកសាសន៍នេះពុំត្រូវបានគេរកឃើញ។ ជាការពិតណាស់ ដោយសារតែករណីខ្លះ ម្ចាស់បណ្តាំមិនបានឱ្យអ្នកដទៃដឹងអំពីអត្ថិភាពនៃមតកសាសន៍ ព្រមទាំងលាក់ជាការសម្ងាត់នៅទីណាមួយដែលមានតែខ្លួនដឹង ក៏ប៉ុន្តែមានហេតុកើតឡើងជាយថាហេតុ ធ្វើឱ្យខ្លួនទទួលមរណភាព ហេតុដូច្នេះ មតកសាសន៍នោះអាចពុំត្រូវបានគេប្រទះឃើញបានដោយងាយៗឡើយ ដែលជាហេតុនាំទៅរកការសន្និដ្ឋានថាគ្មានមតកសាសន៍បន្សល់ទុកនៅពេលដែលសន្តតិកម្មចាប់ផ្តើម។

ចំណែកឯគុណវិបត្តិទី២ គឺ មានហានិភ័យនៃការបោកបញ្ឆោត ការគំរាមកំហែងឱ្យសរសេរមតកសាសន៍ និង ហានិភ័យនៃការបាត់បង់ បន្លំ និងកែប្រែមតកសាសន៍ ជាដើម។

លើសពីនេះ គុណវិបត្តិទី៣ គឺ មតកសាសន៍នេះអាចនឹងប្រឈមនឹងហានិភ័យនៃមោឃភាព ដោយសារតែម្ចាស់បណ្តាំ ក្នុងករណីខ្លះពុំមានចំណេះដឹងគ្រប់គ្រាន់ក្នុងការធ្វើមតកសាសន៍ឱ្យស្របតាមទម្រង់ឡើយ។ ជាចុងក្រោយ គុណវិបត្តិទី៤ គឺ ត្រូវការការពិនិត្យពីតុលាការ (មាត្រា ១២១៣ កថាខណ្ឌទី២)[18]។

[17] ការិយាល័យច្បាប់ High Field (https://yuigon-guide.com/kuwasiku/zihitumeritto.html)

[18] ការិយាល័យច្បាប់ High Field (https://yuigon-guide.com/kuwasiku/zihitumeritto.html)

❖ មតកសាសន៍ដោយលិខិតសម្ងាត់

ជាចុងក្រោយ ទម្រង់មតកសាសន៍ដោយលិខិតសម្ងាត់ត្រូវបានបញ្ញត្តដោយមាត្រា ១១៧៥ ថា៖

"មតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ៖

ក - ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ។

ខ - ម្ចាស់បណ្តាំត្រូវដាក់លិខិតនោះនៅក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬសរសេរសញ្ញាសំគាល់ ឬ មធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬមិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ។

គ - ម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និង សាក្សី ២ (ពីរ) នាក់ និង ធ្វើសេចក្តីថ្លែងការណ៍ថា លិខិតនេះជាមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និងលំនៅឋានរបស់ជនដែលបានសរសេរនោះ។

ឃ - សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និង សរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំនៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ជាមួយគ្នានឹងសាក្សី និងម្ចាស់បណ្តាំ ។"

តាមរយៈបទប្បញ្ញត្តិខាងលើនេះ ឃើញថា មតកសាសន៍ដោយលិខិតសម្ងាត់ មានល័ក្ខខ័ណ្ឌមួយចំនួនដូចជា ១.ការចុះហត្ថលេខារបស់ម្ចាស់បណ្តាំលើលិខិតសម្ងាត់ ២. ការដាក់លិខិតនោះនៅក្នុងស្រោមបិទជិត និងមានសញ្ញាសំគាល់ពីការបិទបើកនៅមាត់ស្រោមលិខិតនោះ ៣. ការដាក់លិខិតបិទជិត និងការធ្វើសេចក្តីថ្លែងការណ៍ដោយម្ចាស់បណ្តាំអំពីភាពជាម្ចាស់នៃមតកសាសន៍ និងអំពីឈ្មោះ និងលំនៅឋានរបស់ជនដែលបានសរសេរជំនួសម្ចាស់បណ្តាំប្រសិនបើមាន នៅចំពោះមុខសារការីម្នាក់ និងសាក្សី ២ (ពីរ) នាក់ ៤. ការចុះថ្ងៃខែឆ្នាំដែលម្ចាស់បណ្តាំបានដាក់លិខិត និងសរសេរនូវសេចក្តីថ្លែងការណ៍ម្ចាស់បណ្តាំដោយសារការីលើលិខិតបិទជិតនោះ និង ៥. ការចុះហត្ថលេខារបស់សារការី សាក្សី និងម្ចាស់បណ្តាំ។

ទម្រង់ខាងលើនេះមានល័ក្ខខ័ណ្ឌស្រដៀងគ្នាទៅនឹងមតកសាសន៍ដោយលិខិតយថាភូតត្រង់ចំណុចនៃការតម្រូវឱ្យមានវត្តមាន និងការចុះហត្ថលេខារបស់សាក្សី និងសារការី។ ចំណែកឯចំណុចដែលមានលក្ខណៈខុសគ្នានោះគឺ ចំនួននៃសារការីដែលត្រូវចូលរួមពុំត្រូវបានបញ្ជាក់ ឬកំណត់ច្បាស់លាស់ឡើយនៅក្នុងល័ក្ខខ័ណ្ឌទម្រង់នៃមតកសាសន៍ដោយលិខិតយថាភូត តែចំនួននៃសារការីនេះត្រូវបានកំណត់ត្រឹមម្នាក់ ចំពោះល័ក្ខខ័ណ្ឌទម្រង់នៃមតកសាសន៍ដោយលិខិតសម្ងាត់។

លើសពីនេះ ចំណែកឯលក្ខណៈខុសគ្នានឹងល័ក្ខខ័ណ្ឌទម្រង់នៃមតកសាសន៍ដោយលិខិតឯកជនគឺ ការដែលពឹងពាក់ឱ្យអ្នកដទៃសរសេរជំនួសម្ចាស់បណ្តាំ ឬ ការប្រើអង្គុលីលេខនោះត្រូវបានអនុញ្ញាតនៅក្នុងករណីធ្វើមតកសាសន៍ដោយលិខិតសម្ងាត់។

នៅក្នុងការបង្កើតមតកសាសន៍ដោយលិខិតសម្ងាត់នេះ ហាក់ពុំមានចំណុចដែលអាចចោទជាចម្ងល់ឡើយ ក្នុងករណីដែលម្ចាស់បណ្ដាំជាអ្នកសរសេរ ឬបង្កើតដោយខ្លួនឯងដោយប្រើម៉ាស៊ីនអង្គុលីលេខ។ ក៏ប៉ុន្តែចំណុចដែលចោទជាចម្ងល់នោះបានលេចឡើងនៅក្នុងករណីដែលមានជនសរសេរជំនួសម្ចាស់បណ្ដាំ ដោយសារតែពុំមានបញ្ញត្តិដែលបញ្ញត្តទៅលើទំហំនៃជនដែលអាចសរសេរជំនួសម្ចាស់បណ្ដាំឡើយ ពោលគឺ តើជនដែលសរសេរលិខិតបណ្ដាំជំនួសម្ចាស់បណ្ដាំនោះ អាចជាបុគ្គលដូចគ្នានឹងជនដែលនឹងក្លាយជាសាក្សីដែរឬទេ? ការដែលចោទសួរដោយសំដៅតែសាក្សីគឺពីព្រោះថា ពាក់ព័ន្ធនឹងចំណុចនេះ ប្រសិនបើសារការីជាអ្នកសរសេរជំនួសម្ចាស់បណ្ដាំ យើងអាចពិចារណាបានថា មតកសាសន៍នេះ នឹងក្លាយទៅជា មតកសាសន៍ដែលមានទម្រង់ផ្សេងមួយទៀត គឺ មតកសាសន៍ដោយលិខិតយថាភូត។ ប្រសិនបើបុគ្គលដែលសរសេរជំនួស និងបុគ្គលដែលនឹងក្លាយជាសាក្សីជាមនុស្សតែម្នាក់ តើវានឹងមានឥទ្ធិពលដល់សុពលភាពនៃមតកសាសន៍ដែរ ឬយ៉ាងណា។ ពាក់ព័ន្ធនឹងចំណុចនេះ ដោយយោងតាមសេចក្ដីកំណត់នៃមាត្រា ១១៧៥ ដដែលនេះ យើងអាចរកឃើញនូវល័ក្ខខ័ណ្ឌនៃជនដែលអាចសរសេរជំនួសម្ចាស់បណ្ដាំបាន តាមរយៈការលើកឡើងថា "ម្ចាស់បណ្ដាំមិនចាំបាច់សរសេរនូវខ្លឹមសារនៃមតកសាសន៍ដោយខ្លួនឯងទេ គឺអាចពឹងឱ្យ អ្នកផ្សេងដែលខ្លួនជឿទុកចិត្ត សរសេរជំនួស [...]" ដែលត្រង់ចំណុចនេះ យើងអាចសន្និដ្ឋានបានថា ជននោះជានរណាក៏បានឱ្យតែម្ចាស់បណ្ដាំ ***ទុកចិត្ត*** ទោះបីជាជននោះពុំអាចក្លាយជាសាក្សីតាមមាត្រា ១១៧២ ដែលបញ្ញត្តអំពី "បុគ្គលដែលមិនអាចក្លាយជាសាក្សី ជាអាទិ៍" ក៏ដោយ ។ ម្យ៉ាងវិញទៀត ប្រសិនបើយើងពិនិត្យទៅលើល័ក្ខខ័ណ្ឌនៃជនដែលក្លាយជាសាក្សីក៏ពុំត្រូវបានកម្រិតចំពោះជនដែលបានសរសេរបណ្ដាំជំនួសម្ចាស់បណ្ដាំនោះដែរ។

សរុបសេចក្ដីមក ត្រង់ចម្ងល់នេះ អាចសន្និដ្ឋានបានថា សាក្សី និងជនដែលអាចសរសេរបណ្ដាំជំនួសម្ចាស់បណ្ដាំ អាចជាមនុស្សតែម្នាក់ ក៏ពុំមានបញ្ហាអ្វីដែរ។

- គុណសម្បត្តិ

មតកសាសន៍ដោយលិខិតសម្ងាត់ ក៏មានគុណសម្បត្តិមួយចំនួនផងដែរ។ គុណសម្បត្តិទី១ គឺគ្មាននរណាអាចដឹងពីខ្លឹមសារនៃមតកសាស៍នោះទេ សូម្បីតែសារការី និងសាក្សីក៏ពុំអាចដឹងបានដែរ ក្នុងករណីម្ចាស់បណ្ដាំជាអ្នកសរសេរដោយខ្លួនឯងដោយពុំមានការពឹងឱ្យមានអ្នកជួយសរសេរឱ្យ។ គុណសម្បត្តិទី២ គឺម្ចាស់បណ្ដាំអាចសរសេរដោយពឹងពាក់ឱ្យអ្នកដែលខ្លួនទុកចិត្តឱ្យសរសេរជំនួស ឬ ប្រើម៉ាស៊ីនដូចជាអង្គុលីលេខជាដើម។ គុណសម្បត្តិទី៣ ត្រូវបានគេចាត់ទុកថា ចំណាយតិចជាង បើប្រៀបធៀបនឹងការធ្វើមតកសាសន៍ដោយលិខិតយថាភូត[19]។

[19] ក្រុមហ៊ុន អាសាហ៊ី ស៊្មឹមប៊ឹង, *តើមតកសាសន៍ដោយលិខិតសម្ងាត់ជាអ្វី?* (https://souzoku.asahi.com/article/14343859)

- គុណវិបត្តិ

ទោះជាយ៉ាងណាក៏ដោយ មតកសាសន៍ដោយលិខិតសម្ងាត់ ក៏ដូចមតកសាសន៍ទម្រង់ផ្សេងៗទៀតដែរ គឺមានគុណវិបត្តិដូចគ្នា ដែលគុណវិបត្តិទី១ នោះគឺស្រដៀងទៅនឹងគុណវិបត្តិរបស់មតកសាសន៍ដោយលិខិតយថាភូតផងដែរ ត្រង់ថា តម្រូវឱ្យមានសាក្សីចំនួនពីររូប នេះគឺជាគុណវិបត្តិមួយបើប្រៀបធៀបទៅនឹងមតកសាសន៍ដោយលិខិតឯកជន។ ចំណែកឯគុណវិបត្តិទី២វិញ ក៏មានភាពប្រហាក់ប្រហែលនឹងគុណវិបត្តិរបស់មតកសាសន៍ដោយលិខិតឯកជននោះគឺ វាអាចជួបប្រទះនឹងហានិភ័យនៃការពុំត្រូវបានគេរកឃើញ ឬ ត្រូវបានជនដែលរកឃើញដែលពុំពេញចិត្តនឹងខ្លឹមសារនៃមតកសាសន៍នោះយកទៅបោះចោល នោះខ្លឹមសារនៃមតកសាសន៍នឹងត្រូវធ្លាក់ក្នុងស្ថានភាពដែលមិនអាចត្រូវបានគេដឹងរហូត[20]។

លើសពីនេះទៅទៀត ក្នុងករណីដែលមតកសាសន៍នៃជនជាតិខ្មែរដែលរស់នៅបរទេសវិញ ប្រជាជនខ្មែរដែលរស់នៅបរទេសអាចធ្វើមតកសាសន៍បាន ក៏ប៉ុន្តែ ក្នុងករណីដែលធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬ មតកសាសន៍ដោយលិខិតសម្ងាត់នោះ ត្រូវធ្វើនៅកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាដែលប្រចាំនៅប្រទេសដែលម្ចាស់បណ្តាំស្នាក់នៅនោះ ហើយកុងស៊ុលនោះត្រូវអនុវត្តមុខនាទីរបស់សារការី (មាត្រា ១១៨១)។

សរុបសេចក្តីមក ដើម្បីឱ្យមតកសាសន៍មានសុពលភាពម្ចាស់បណ្តាំមិនត្រឹមតែត្រូវមានសមត្ថភាពក្នុងការធ្វើមតកសាសន៍នាពេលធ្វើមតកសាសន៍នោះទេ គឺថែមទាំងត្រូវធ្វើមតកសាសន៍នោះដោយគោរពតាមទម្រង់ណាមួយក្នុងចំណោមទម្រង់ទាំងបីដែលក្រមរដ្ឋប្បវេណីបានកំណត់ខាងលើផងដែរ។

**ខ. ទម្រង់នៃមតកសាសន៍សម្រាប់ស្ថានភាពពិសេស**

នៅក្នុងករណីខ្លះ បុគ្គលមួយចំនួនអាចស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ ឬ ស្ថានភាពនោះពុំអនុញ្ញាតឱ្យម្ចាស់បណ្តាំមានសមត្ថភាព ឬ លទ្ធភាពអាចធ្វើមតកសាសន៍ដោយបំពេញតាមល័ក្ខខ័ណ្ឌទម្រង់ដែលបានបញ្ញត្តនៅក្នុងទម្រង់នៃមតកសាសន៍នៅក្នុងស្ថានភាពធម្មតាដូចខាងលើបានឡើយ ។ ដូច្នេះ ក្រមរដ្ឋប្បវេណីក៏បានបញ្ញត្តដោយគិតគូរទៅដល់បុគ្គលដែលស្ថិតនៅក្នុងស្ថានភាពពិសេសទាំងនោះផងដែរ ដែលក្រមនេះបានរៀបចំបទប្បញ្ញត្តិចំពោះស្ថានភាពពិសេសៗចំនួនបួន ដូចជា មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍ មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបានជាអាទិ៍។

ទម្រង់នៃមតកសាសន៍សម្រាប់ស្ថានភាពពិសេសទី១ គឺ **មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ** ។ ជននៅក្រោមអាណាព្យាបាលទូទៅដែលធ្វើមតកសាសន៍ត្រូវគោរពល័ក្ខខ័ណ្ឌពិសេសដែលត្រូវបាន

[20] ក្រុមហ៊ុន អាសាហ៊ី ស៊្រឹមប៊ឹង, *តើមតកសាសន៍ដោយលិខិតសម្ងាត់ជាអ្វី?* (https://souzoku.asahi.com/article/14343859)

កំណត់នៅត្រង់មាត្រា ១១៧៦ ដូចជា ល័ក្ខខ័ណ្ឌទី១ ពេលវេលាដែលអាចធ្វើមតកសាសន៍បានត្រូវតែជាពេលដែល "ជននៅក្រោមអាណាព្យាបាលទូទៅ បានសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន" និង ល័ក្ខខ័ណ្ឌទី២ ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិត យ៉ាងតិច ២ (ពីរ) នាក់ និង ល័ក្ខខ័ណ្ឌទី៣ វេជ្ជបណ្ឌិតដែលមានវត្តមាននោះ ត្រូវសរសេរបញ្ជាក់បន្ថែមនៅលើមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្ដាំបានធ្វើមតកសាសន៍នោះ ម្ចាស់បណ្ដាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថាខ្លួនជាវេជ្ជបណ្ឌិតផងដែរ។

ម្យ៉ាងទៀត ប្រសិនបើជននៅក្រោមអាណាព្យាបាលទូទៅធ្វើមតកសាសន៍ដោយលិខិតយថាភូត នោះក៏ត្រូវតែបំពេញល័ក្ខខ័ណ្ឌនៃវត្តមានរបស់សាក្សីផងដែរ។ ចំណែកឯករណីមតកសាសន៍ដោយលិខិតឯកជន ឬ មតកសាសន៍ដោយលិខិតសម្ងាត់ នៅក្នុងករណីនីមួយៗ ចាំបាច់ត្រូវមានវត្តមានរបស់គ្រូពេទ្យដែលមានចែងក្នុងកថាខណ្ឌទី១ នៅពេលជននោះសរសេរមតកសាសន៍ដោយផ្ទាល់ ឬ នៅពេលជននោះបង្ហាញខ្លឹមសារនៃមតកសាសន៍ទៅឱ្យសារការី[21]។

ទម្រង់ទី២គឺ **មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត**។ ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតដែលធ្វើមតកសាសន៍ត្រូវបំពេញល័ក្ខខ័ណ្ឌពិសេសដែលត្រូវបានបញ្ញត្តត្រង់មាត្រា ១១៧៧ ដូចជា ល័ក្ខខ័ណ្ឌទី ១ នៅពេលដែលធ្វើមតកសាសន៍ ត្រូវមានវត្តមានសាក្សីយ៉ាងតិច ៣ (បី) នាក់។ ចំណែកឯ ល័ក្ខខ័ណ្ឌទី ២ គឺម្ចាស់បណ្ដាំត្រូវប្រកាសខ្លឹមសារនៃមតកសាសន៍នោះដោយផ្ទាល់មាត់ចំពោះសាក្សីម្នាក់ក្នុងចំណោមសាក្សីនោះ ។ ល័ក្ខខ័ណ្ឌទី ៣ គឺ សាក្សីនោះត្រូវសរសេរខ្លឹមសារនោះជាលាយល័ក្ខណ៍អក្សរ រួចអានឱ្យសាក្សីនីមួយៗស្ដាប់ ឬ ឱ្យមើល ។ ល័ក្ខខ័ណ្ឌទី៤ គឺ សាក្សីទាំងអស់ត្រូវចុះហត្ថលេខាលើលិខិតនោះ បន្ទាប់ពីបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ។ ជាចុងក្រោយ ល័ក្ខខ័ណ្ឌទី ៥ គឺសាក្សីណាម្នាក់ ឬ បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ត្រូវដាក់ពាក្យសុំបញ្ជាក់ទៅតុលាការក្នុងអំឡុងពេល ១ ខែ គិតចាប់ពីថ្ងៃធ្វើបណ្ដាំ និងទទួលបានការបញ្ជាក់។ ម្យ៉ាងវិញទៀត នៅក្នុងករណីនេះក៏ដោយ ក៏ជនដែលត្រូវបានសន្មតថាជាសន្តតិជនជាអាទិ៍ មិនអាចធ្វើជាសាក្សី ឬ អ្នកសង្កេតការណ៍បានឡើយ។ គួរបញ្ជាក់ផងដែរថា ជនដែលស្ថិតនៅក្នុងស្ថានភាពនេះ អាចធ្វើមតកសាសន៍ដោយលិខិតឯកជន ឬ មតកសាសន៍ដោយលិខិតយថាភូតបានផងដែរ ប្រសិនបើមានសមត្ថភាព ឬ មានពេលវេលាគ្រប់គ្រាន់។ ក្នុង

[21] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦៖ គន្លឹះទី៨-៩,ទំព័រ.៣៩

ករណីដែលគ្មានសមត្ថភាព ឬ គ្មានពេលវេលា នោះជនខាងលើនេះក៏អាចធ្វើមតកសាសន៍ចំពោះមុខអ្នកមានវត្តមានបានផងដែរ ដោយត្រូវអនុវត្តទៅតាមល័ក្ខខ័ណ្ឌដែលមាត្រា ១១៧៧ បានកំណត់[22]។

ទម្រង់ទី ៣ គឺ **មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំងជាអាទិ៍** ។ ចំពោះករណីនេះត្រូវបែងចែកជាពីរករណី គឺជនដែលត្រូវបានឃុំឃាំងនៅទីកន្លែងដោយឡែក និង ជនដែលនៅក្នុងនាវា ឬ យន្តហោះ។ ការធ្វើមតកសាសន៍នេះត្រូវបំពេញល័ក្ខខ័ណ្ឌមួយចំនួនដែលត្រូវបានកំណត់ដោយមាត្រា ១១៧៨ ដូចជា ល័ក្ខខ័ណ្ឌទី ១ គឺត្រូវមានវត្តមានរបស់នគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំង ម្នាក់ និងសាក្សី យ៉ាងតិច ២ នាក់ (មាត្រា ១១៧៨ កថាខណ្ឌទី១) ក្នុងករណីបុគ្គលនោះនៅទីកន្លែងដាច់ដោយឡែក។ រីឯក្នុងករណីដែលបុគ្គលនោះនៅលើយន្តហោះ ឬ នាវាវិញ ត្រូវមានវត្តមាន មេបញ្ជាការ បរិបាល ឬបុគ្គលិកនាវា ឬ យន្តហោះ និងសាក្សីយ៉ាងតិច ២ នាក់។ម្យ៉ាងវិញទៀត ម្ចាស់បណ្តាំក៏អាចធ្វើដោយផ្ទាល់មតកសាសន៍នេះដោយផ្ទាល់មាត់ផងដែរ (មាត្រា ១១៧៨ កថាខណ្ឌទី៣)។ ចំពោះករណីនេះ ត្រូវគោរពតាមបញ្ញត្តិពីចំណុច ខ ដល់ចំណុច ង កថាខណ្ឌទី២ នៃមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) ត្រង់ចំណុចនេះ ពាក្យថា "សារការី" ត្រូវបានបកស្រាយថាជា នគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះ (មាត្រា ១១៧៨ កថាខណ្ឌទី៤)។

ជាក់ស្តែង ជនដែលស្ថិតនៅក្នុងស្ថានភាពខាងលើនេះ ក៏អាចធ្វើមតកសាសន៍ដោយលិខិតឯកជនដោយយោងតាមមាត្រា ១១៧៤ បានផងដែរ ក៏ប៉ុន្តែមាត្រានេះត្រូវបានចែងឡើងទុកសម្រាប់ករណីដែលជននោះពុំអាចមានធ្វើមតកសាសន៍ដោយខ្លួនឯង ដូចជាករណីដែលជននោះជាអនក្ខរជន ឬ មានរបួសដៃជាដើម[23]។

ចំពោះសុពលភាពវិញ ទម្រង់នៃមតកសាសន៍នេះមានសុពលភាពត្រឹមតែ ៦ ខែប៉ុណ្ណោះ ក្រោយពេលដែលម្ចាស់បណ្តាំអាចធ្វើបណ្តាំតាមទម្រង់ធម្មតាបាន (មាត្រា ១១៧៨ កថាខណ្ឌទី ៤) ។ ដូច្នេះ មតកសាសន៍ដែលត្រូវបានធ្វើក្នុងករណីខាងលើ នេះ គឺជាមតកសាសន៍ដែលមានលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ[24]។

ទម្រង់ទី ៤ គឺ **មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍** ។ ដើម្បីឱ្យមតកសាសន៍របស់ខ្លួនមានសុពលភាព បុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍ត្រូវបំពេញល័ក្ខខ័ណ្ឌមួយចំនួនដែលមាត្រា ១១៧៩ បានបញ្ញត្ត ដូចជា ល័ក្ខខ័ណ្ឌទី១ គឺ ម្ចាស់បណ្តាំនោះអាចធ្វើសេចក្តីថ្លែងការណ៍ដែលខ្លួនបានតាមរយៈ

---

[22] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦៖ គន្ថីទី៨-៩,ទំព័រ.៤០,៤១

[23] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦៖ គន្ថីទី៨-៩,ទំព័រ.៤២

[24] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦៖ គន្ថីទី៨-៩,ទំព័រ.៤២

ការបកប្រែរបស់អ្នកបកប្រែ ឬសរសេរដោយដៃខ្លួនផ្ទាល់ នៅចំពោះមុខសារការី ឬសាក្សី (មាត្រា ១១៧៩ កថាខណ្ឌទី១)។ ស្រដៀងគ្នានេះដែរ សម្រាប់ករណីម្ចាស់បណ្ដាំ ឬ សាក្សី បែរជាមនុស្សថ្លង់មិនអាចស្ដាប់បានវិញនោះ ហើយសារការី ឬបុគ្គលផ្សេងទៀតដែលត្រូវបានកំណត់នៅក្នុងក្រមនេះដែលមានកាតព្វកិច្ចត្រូវអាននូវអត្ថន័យនៃមតកសាសន៍ ក្រោយពេលបានសរសេរជាលាយល័ក្ខណ៍អក្សរហើយនោះ អាចជំនួសការអាននោះដោយប្រាប់អំពីអត្ថន័យដែលខ្លួនបានសរសេរនោះ តាមការបកប្រែរបស់អ្នកបកប្រែ ទៅម្ចាស់បណ្ដាំ ឬសាក្សីនោះ (មាត្រា ១១៧៩ កថាខណ្ឌទី២)។ ចំពោះល័ក្ខខ័ណ្ឌទី២ គឺ រាល់ការប្រតិបត្តិដែលបានធ្វើដោយអនុលោមតាមកថាខណ្ឌទី១ និងទី២ នៃមាត្រា ១១៧៩នេះ សារការី ឬបុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះត្រូវសរសេរអំពីហេតុនោះចូលទៅក្នុងមតកសាសន៍នោះផងដែរ (មាត្រា ១១៧៩ កថាខណ្ឌទី៣)។

**គ. បញ្ហានៃល័ក្ខខ័ណ្ឌនៃភាពចាំបាច់នៃទម្រង់មតកសាសន៍**

ដូចដែលបានបង្ហាញខាងលើរួចមកហើយ ភាពចាំបាច់នៃទម្រង់មតកសាសន៍គឺជាល័ក្ខខ័ណ្ឌដើម្បីឱ្យមតកសាសន៍មួយមានសុពលភាពបាន។ ពាក់ព័ន្ធនឹងល័ក្ខខ័ណ្ឌនេះ មានបញ្ហាចំនួន ២ នឹងត្រូវលើកយកមកពិចារណា។

បញ្ហាទី១ គឺជាបញ្ហាអំពីខ្លឹមសារនៃមតកសាសន៍ដែលគ្មានកាលបរិច្ឆេទ និងខ្លឹមសារនៃមតកសាសន៍ដែលមានកាលបរិច្ឆេទ។ ដោយមាត្រា ១១៧០ កថាខណ្ឌទី២ បានចែងថា មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ នឹងត្រូវចាត់ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្ដាំដូចគ្នា។ ដូច្នេះ ដោយផ្អែកតាមរយៈការបញ្ញត្តិដូចខាងលើនេះ មានសំណួរ ២ ដែលលេចឡើង។ សំណួរទី១ គឺ តើខ្លឹមសារទាំងមូលនៃមតកសាសន៍ដែលមិនមានកាលបរិច្ឆេទនោះ ត្រូវចាត់ទុកជាមោឃៈ ដោយសារមាត្រា ១១៧០ កថាខណ្ឌទី២ ដែរឬទេ ទោះបីជាមានតែខ្លឹមសារមួយផ្នែកប៉ុណ្ណោះដែលផ្ទុយនឹងមតកសាសន៍ដែលមានកាលបរិច្ឆេទ? ប្រសិនបើចម្លើយទៅកាន់សំណួរទី១គឺបដិសេធ នោះមានន័យថាសុពលភាពនៃមតកសាសន៍នឹងត្រូវបានវិនិច្ឆ័យដោយផ្អែកលើចំណុចនីមួយៗ។ សំណួរទី២ គឺ តើចំណុចអំពីទ្រព្យសម្បត្តិជាក់លាក់ណាមួយនៅក្នុងមតកសាសន៍ដែលមិនមានកាលបរិច្ឆេទត្រូវចាត់ទុកថាផ្ទុយនឹងមតកសាសន៍ដែលមានកាលបរិច្ឆេទដែរ ឬទេ ប្រសិនបើចំណុចនោះពុំមាននៅក្នុងមតកសាសន៍ដែលមានកាលបរិច្ឆេទ?

ជុំវិញបញ្ហាខាងលើនេះ ត្រូវបានលើកយកមកពិភាក្សានៅកម្ពុជាផងដែរ។ ពាក់ព័ន្ធនឹងសំណួរទី១ មានការវិភាគថា មាត្រា ១១៧០ កថាខណ្ឌទី២ នេះមិនបានកំណត់អំពីចំណុចនៃសំណួរទី១នេះទេ ម្យ៉ាងទៀតប្រសិនបើធ្វើការពិនិត្យទៅលើមាត្រា ១១៨៩ កថាខណ្ឌទី២ ដែលបានបញ្ញត្តថា បើមតកសាសន៍ដែលបានធ្វើក្រោយនេះ មានភាពផ្ទុយគ្នានឹងមតកសាសន៍ដែលបានធ្វើមុន ត្រូវចាត់ទុកថាមតកសាសន៍ដែលបានធ្វើក្រោយ

នេះ បានលុបចោលមតកសាសន៍ដែលបានធ្វើមុន ចំពោះផ្នែកដែលផ្ទុយនោះ ។ ដោយផ្អែកតាម រយៈលំនាំនៃការបញ្ញត្តបែបនេះ អាចឱ្យយល់បានថា ខ្លឹមសារនៃមតកសាសន៍ទាំងមូលមិនត្រូវបានចាត់ទុកថាជាមោឃៈនោះទេ នៅពេលដែលមតកសាសន៍ពីរ ដែលមានកាលបរិច្ឆេទនោះផ្ទុយគ្នាដោយផ្នែក។ គេក៏បានធ្វើការលើកឡើងអំពីគំនិតគ្រឹះនៃមាត្រា ១១៨៩ នេះផងដែរថា ត្រូវតែគោរពឆន្ទៈរបស់មតកជនក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួននៅក្នុងមតកសាសន៍ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ហើយគំនិតនេះ អាចត្រូវបានគេយកមកអនុវត្តផងដែរចំពោះសុពលភាពនៃមតកសាសន៍ដែលមិនមានកាលបរិច្ឆេទ។ ដូច្នេះ ផ្អែកតាមរយៈការពិភាក្សាដែលគេបានធ្វើខាងលើនេះអាចសរុបបានថា មានតែផ្នែកដែលផ្ទុយគ្នាតែប៉ុណ្ណោះដែលត្រូវចាត់ទុកថាជាមោឃៈ។

ចំណែកឯសំណួរទី២ វិញ មានគំនិតចំនួនពីរត្រូវបានលើកឡើង។ ក្នុងនោះ គំនិតទី១ បានលើកឡើងថា មតកសាសន៍ទាំងពីរនេះមិនផ្ទុយគ្នាទេ នៅពេលដែលមតកសាសន៍មិនមានកាលបរិច្ឆេទចាត់ចែងទ្រព្យសម្បត្តិប៉ុន្តែមតកសាសន៍ដែលមានកាលបរិច្ឆេទស្មៀមស្ងាត់។ ចំណែកឯគំនិតទី២ វិញ បានលើកឡើងថា ភាពស្ងៀមស្ងាត់ទាក់ទងនឹងទ្រព្យសម្បត្តិមួយចំនួន មានន័យថាមតកជនមានបំណងចង់ចាត់ចែងទ្រព្យសម្បត្តិនោះតាមបញ្ញត្តិនៃសន្តតិកម្មតាមច្បាប់។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺសមាជិកទាំងអស់ដែលបានចូលរួមក្នុងការពិភាក្សាខាងលើនេះ បានគាំទ្រគំនិតទី១។

ជាការពិតណាស់ ប្រសិនបើឈរលើគោលការណ៍ដែលត្រូវគោរពឆន្ទៈមតកជនឱ្យបានច្រើនកាន់តែអាចធ្វើបាននោះ ឃើញថា គំនិតទី១ មានភាពសមហេតុផលជាង ដោយហេតុថា ឆន្ទៈនោះបានត្រូវបានមតកជនបង្ហាញយ៉ាងច្បាស់លាស់នៅក្នុងមតកសាសន៍របស់ខ្លួន ហើយពុំបានលុបមតកសាសន៍ត្រង់ផ្នែកនោះដោយទម្រង់ណាមួយឡើយ។

បញ្ហាទី២ គឺបញ្ហាពាក់ព័ន្ធនឹងការអនុវត្តជាក់ស្តែង ដូចជា ការដែលមតកជនធ្វើមតកសាសន៍រួចយកលិខិតបណ្តាំទាំងនោះទៅឱ្យមេឃុំបោះត្រា ឬ ពឹងឱ្យមេធាវីជាអ្នករៀបចំលិខិតនោះ ហើយមានការវាយត្រាដោយមេធាវីជាដើម។ ចំពោះករណីបែបនេះ លិខិតបណ្តាំទាំងនោះអាចនឹងមានសុពលភាព ហើយក៏មានករណីដែលគ្មានសុពលភាពផងដែរ។

ប្រសិនបើលិខិតបណ្តាំនោះ ម្ចាស់បណ្តាំនោះជាសមត្ថជននាពេលដែលបានសរសេរដោយខ្លួនឯងដោយផ្ទាល់ដៃនូវលិខិតបណ្តាំនោះ អាចនិយាយបានថាមតកសាសន៍នេះគឺជាមតកសាសន៍ដោយលិខិតឯកជន។ មតកសាសន៍នេះនឹងមានសុពលភាព ដរាបណាបានបំពេញតាមល័ក្ខខ័ណ្ឌផ្សេងៗទៀតដែលបានចែងដោយមាត្រា ១១៧៤ ដូចជា ចុះថ្ងៃខែឆ្នាំ និងចុះហត្ថលេខាដោយខ្លួនឯងជាដើម។ ចំណែកឯករណីដែលមេធាវីជាអ្នក

រៀបចំ វិញពុំមានសុពលភាពនោះទេ ពីព្រោះលិខិតបែបនេះត្រូវបានធ្វើឡើងដោយពុំគោរពទៅតាមល័ក្ខខ័ណ្ឌនៃភាពចាំបាច់នៃទម្រង់នៃមតកសាសន៍ដែលកំណត់ដោយក្រមរដ្ឋប្បវេណី។

## ផ្នែកទី២ បញ្ហានៃខ្លឹមសារមតកសាសន៍

នៅក្នុងផ្នែកនេះ ដើម្បីបកស្រាយអំពីបញ្ហានៃខ្លឹមសារមតកសាសន៍ឱ្យបានគ្រប់ជ្រុងជ្រោយ យើងនឹងបែងចែកជា ៣ កថាខណ្ឌគឺ កថាខណ្ឌទី១ នឹងបកស្រាយពី ខ្លឹមសារទាក់ទងនឹងទ្រព្យសម្បត្តិ និង កថាខណ្ឌទី២ នឹងបកស្រាយពី ខ្លឹមសារមិនទាក់ទងនឹងទ្រព្យសម្បត្តិ និង កថាខណ្ឌទី៣ នឹងបកស្រាយពី បញ្ហានៃខ្លឹមសារមតកសាសន៍។

### កថាខណ្ឌទី១ ខ្លឹមសារទាក់ទងនឹងទ្រព្យសម្បត្តិ

#### ក. ការកំណត់ចំណែកមត៌ក

ចំណុចទី១ ដែលម្ចាស់បណ្តាំអាចកំណត់នៅក្នុងមតកសាសន៍របស់ខ្លួនបាននោះគឺ ការកំណត់ចំណែកមត៌ករបស់សហសន្តតិជនជាអាទិ៍បាន ឬ បង្ហាញឆន្ទៈផ្ទុយពីមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ ចំពោះចំណែកមត៌ករបស់បុគ្គលដែលបានទទួលផលប្រយោជន៍ពិសេសបាន។

ចំពោះចំណែកមត៌កនៃសន្តតិជនដែលមតកជនបានកំណត់តាមរយៈមតកសាសន៍នេះ អាចហៅថា "ចំណែកមត៌កតាមការកំណត់" ហើយអាចធ្វើដោយវិធីកំណត់នូវសមាមាត្រ ដូចជា ១ ភាគ ២ ជាដើម ឬ ដោយវិធីកំណត់នូវទ្រព្យសម្បត្តិជាក់ស្តែងណាមួយ[25] ឧទាហរណ៍ ការកំណត់ឱ្យសន្តតិជន ក ទទួលបានដីមួយកន្លែងដែលមានតម្លៃ ប្រាំម៉ឺនដុល្លារ និង ឡានដែលមានតម្លៃ ពីរម៉ឺនដុល្លារ ជាដើម។

ម្យ៉ាងទៀត យោងតាមមាត្រា ១១៦៣ ជាគោលការណ៍ ប្រសិនបើសន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសមុនពេលសន្តតិកម្មចាប់ផ្តើមរួចទៅហើយដូចជា ប្រទានកម្មនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត ឬ ដើម្បីមូលធននៃជីវភាពរស់នៅ ឬ បានទទួលអច្ច័យទានពីមតកជន នោះនៅពេលដែលសន្តតិកម្មចាប់ផ្តើម ចំណែកមត៌កដែលជននោះត្រូវទទួលបានត្រូវយកមកកាត់កងនឹងផលប្រយោជន៍ពិសេសនោះសិន ទើបរកឃើញតម្លៃពិតប្រាកដនៃចំណែកមត៌ករបស់ខ្លួន។ ក៏ប៉ុន្តែ ចំពោះការកំណត់នូវចំណែកមត៌កខាងលើនេះ ម្ចាស់បណ្តាំក៏អាចកំណត់ផ្ទុយពីមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) បានដែរ មានន័យថា បើសន្តតិជនធ្លាប់បានទទួលបានប្រទានកម្មដែលមានតម្លៃស្មើនឹងចំណែកមត៌ករបស់ខ្លួនហើយក៏ដោយ ក៏មតកជនអាចកំណត់ឱ្យសន្តតិជននោះទទួលបាននូវចំណែកបន្ថែម

[25] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦៖ គន្លឹទី៨-៩,ទំព័រ.៨៥

ទៀតផងដែរ។ ថ្វីត្បិតតែម្ចាស់បណ្តាំអាចបង្ហាញឆន្ទៈផ្ទុយនឹងគោលការណ៍សម្រួលចំណែកមត៌កដែលមានចែង នៅក្នុងមាត្រា ១១៦៣ ក៏ដោយ ក៏ការកំណត់ចំណែកមត៌កនោះ ក៏មិនអាចធ្វើឱ្យផ្ទុយនឹងបញ្ញត្តិនៃភាគបម្រុង បានដែរ (មាត្រា ១១៨២ កថាខណ្ឌទី១)។ ពោលគឺ នៅក្នុងករណីដែលមតកជនបានកំណត់ចំណែកមត៌ក ដោយបំពាននឹងភាគបម្រុងរបស់សន្តតិជនណាមួយ សន្តតិជនដែលមានសិទ្ធិទៅលើភាគបម្រុងនោះអាចទាម ទារឱ្យកាត់បន្ថយទ្រព្យដែលត្រូវបានកំណត់ឱ្យទៅសន្តតិជនផ្សេងនោះដើម្បីបង្គ្រប់នូវទ្រព្យដែលភាគបម្រុងរបស់ ខ្លួនដោយយោងតាមបទប្បញ្ញត្តិនៃភាគបម្រុងបាន[26]។

ម្យ៉ាងទៀត ចំពោះករណីដែលមតកជនពុំបានកំណត់ចំណែកមត៌ករបស់សហសន្តតិជនគ្រប់ទាំងអស់ ទេនោះ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀតដែលពុំត្រូវបានកំណត់នៅក្នុងមតកសាសន៍នោះ ត្រូវ កំណត់ដោយយោងតាមបញ្ញត្តិនៃផ្នែកទី៣ (ការសម្រួលចំណែកមត៌ក) ជំពូកទី២។ លើសពីនេះ សន្តតិជនដែល ចំណែកមត៌កត្រូវបានកំណត់នៅក្នុងមតកសាសន៍នៅតែមានអាទិភាពក្នុងការទទួលយកនូវចំណែករបស់ខ្លួន ជាងសន្តតិជនដែលចំណែកមត៌កពុំត្រូវបានកំណត់នៅក្នុងមតកសាសន៍[27]។

**ខ. ការកំណត់នូវវិធីបែងចែកដោយមតកសាសន៍ជាអាទិ៍**

ចំណុចទី២ ដែលមតកជនអាចកំណត់នៅក្នុងមតកសាសន៍គឺ ការកំណត់នូវវិធីបែងចែក និងចំណុច ផ្សេងៗមួយចំនួនដែលពាក់ព័ន្ធផងដែរ។ ទាក់ទងនឹងចំណុចនេះ មាត្រា ១១៨៣ នៃក្រមរដ្ឋប្បវេណីបានចែងថា មតកជនអាចកំណត់នូវវិធីបែងចែកតាមមតកសាសន៍ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់វិធីនោះ ឬ អាចហាមឃាត់មិនឱ្យបែងចែកនៅក្នុងអំឡុងពេលដែលមិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើម សន្តតិកម្មនោះបាន។ ដោយយោងតាមបញ្ញត្តិនៃមាត្រានេះ យើងអាចធ្វើការបែងចែកជា ៣ ផ្នែកទៅតាមចំណុច នីមួយៗ។

ចំណុចដំបូងគឺ មតកជនអាចធ្វើការកំណត់នូវវិធីបែងចែកមត៌កបាន ដូចជាតាមរយៈការកំណត់ថា សហ សន្តតិជនណាទទួលបានទ្រព្យជាក់លាក់ណាមួយស្របទៅតាមឆន្ទៈមតកជនជាដើម។ ម្យ៉ាងទៀត មតកជនក៏ អាចធ្វើការកំណត់នូវវិធីបែងចែកមត៌ក និង កំណត់នូវចំណែកមត៌ក ព្រមគ្នាផងដែរ[28] ដោយអាចកំណត់ថា សហសន្តតិជន ក ទទួលសន្តតិកម្មដី ដែលមានតម្លៃស្មើនឹង ៩០០០ ដុល្លារ ចំណែកឯសហសន្តតិជន ខ ទទួល សន្តតិកម្មផ្ទះ មានតម្លៃស្មើនឹង ១១០០០ ដុល្លារជាដើម ដោយហេតុថា ឆន្ទៈរបស់មតកជនត្រូវបានគេចាត់

[26] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦៖ គន្ថីទី៨-៩,ទំព័រ.៤៦

[27] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦៖ គន្ថីទី៨-៩,ទំព័រ.៤៦

[28] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦៖ គន្ថីទី៨-៩,ទំព័រ.៤៧

ទុកជាអាទិភាព។ ដូច្នេះ ទោះបីជាសហសន្តតិជនទទួលបានចំណែក ១ ភាគ ២ ក៏ដោយ ក៏មតកជនអាចកំណត់ផ្សេងពីចំណែកនោះផងដែរ តែមិនត្រូវឱ្យបំពានភាគបម្រុងដែលកំណត់ដោយច្បាប់នោះទេ។

ចំណុចបន្ទាប់គឺ មាត្រានេះបានទទួលស្គាល់ឱ្យមតកជនពុំបាច់ធ្វើការកំណត់នូវវិធីបែងចែកនោះដោយខ្លួនឯងនោះទេ ពោលគឺ មតកជនអាចប្រគល់កិច្ចការនេះឱ្យទៅតតិយជនជាអ្នកធ្វើការកំណត់នូវវិធីនៃការបែងចែកមត៌កនេះបានផងដែរ។ ចំណុចដែលគួរកត់សម្គាល់ពាក់ព័ន្ធនឹងចំណុចនេះគឺ អ្នកដែលអាចធ្វើកិច្ចការនេះជំនួសមតកជនបានគឺជា តតិយជន ដែលមានន័យថា ជននោះពុំអាចជាសន្តតិជនបាននោះទេ ។

ចំណុចចុងក្រោយគឺ មតកជនអាចហាមឃាត់មិនឱ្យបែងចែកមត៌កក្នុងអំឡុងពេលមួយ ដែលមិនលើសពី ៥ ឆ្នាំចាប់ពីពេលដែលសន្តតិកម្មចាប់ផ្ដើមបាន។ ឧទាហរណ៍ដូចជា មតកជនហាមមិនឱ្យបែងចែកព្រោះសន្តតិជនមួយចំនួនមិនទាន់គ្រប់អាយុជាដើម។ ម្យ៉ាងទៀត ដោយហេតុថា ដើម្បីតម្រូវឱ្យស្របជាមួយនឹងការបែងចែកវត្ថុកម្មសិទ្ធិអវិភាគ នៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ នៃមាត្រា ២១១ ដូច្នេះទើបអំឡុងពេលនៃការហាមឃាត់នេះត្រូវបានកំណត់ចំនួន ៥ (ប្រាំ) ឆ្នាំ[29]។

**គ. ការកំណត់អំពីអច្ច័យទាន**

ចំណុចទី៣ គឺ មតកជនអាចធ្វើអនុប្បទានទ្រព្យសម្បត្តិតាមមតកសាសន៍ (អច្ច័យទាន) បាន ហើយអត្ថន័យតាមផ្លូវច្បាប់នៃអនុប្បទានទ្រព្យសម្បត្តិនេះ ថាជាអច្ច័យទាន ឬយ៉ាងណា ដោយផ្អែកតាមល័ក្ខខ័ណ្ឌយ៉ាងណាខ្លះ ដែលវាអាចនឹងមានឥទ្ធិពលទៅដល់ចំណែក មត៌កនៃសហសន្តិជននីមួយៗ ដោយយោងតាមមាត្រា ១១៨៤ និង មាត្រា ១១៨៥ នៃក្រមរដ្ឋប្បវេណី។

មាត្រា ១១៨៤ បានចែងថា "ម្ចាស់បណ្ដាំអាចធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែក ឬ អាចធ្វើប្រទានកម្មដោយមតកសាសន៍តាមវិធីដែលបានកំណត់នៅក្នុងមាត្រា ១១៩៩ (និយមន័យនៃអច្ច័យទាន) នៃក្រមនេះ បាននៅក្នុងល័ក្ខខ័ណ្ឌដែលអនុលោមតាមបញ្ញត្តិស្ដីពីភាគបម្រុង" ។

មាត្រានេះបានចែងអំពីការទទួលស្គាល់នូវការដែលម្ចាស់បណ្ដាំអាចធ្វើប្រទានកម្មទ្រព្យសម្បត្តិរបស់ខ្លួនឱ្យទៅជនដែលត្រូវបានសន្មតថាជាសន្តតិជន ឬ តតិយជនដែលមិនមែនជាសន្តតិជនតាមរយៈមតកសាសន៍។

- អនុប្បទានចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជន

ការធ្វើអនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន នឹងត្រូវបែងចែកជាពីរផ្នែកធំៗគឺសម្រាប់ករណីដែលមតកជនបានធ្វើមតកសាសន៍ចំពោះមត៌កទាំងអស់ និង ករណីទី២ គឺ ករណីដែលមតកជនបានធ្វើមតក

[29] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦៖ គន្ថីទី៨-៩,ទំព័រ.៤៧

សាសន៍ចំពោះទ្រព្យសម្បត្តិមួយភាគនៅក្នុងចំណោមមត៌កដែលត្រូវបានបញ្ញត្តដោយមាត្រា ១១៨៥ ដូចខាងក្រោម៖

*"១ - បើមតកជនបានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើការអនុប្បទានទ្រព្យសម្បត្តិ ជាក់លាក់ណាមួយ ឬ ច្រើន ឱ្យទៅសហសន្តិជនតែម្នាក់ ឬ ច្រើននាក់ មតកសាសន៍នោះត្រូវបានសន្មតថាបានកំណត់នូវវិធីបែងចែកមត៌ក លើកលែងតែនៅក្នុងករណីដែលមតកសាសន៍នោះមានអត្ថន័យជាអច្ច័យទានយ៉ាងច្បាស់លាស់ ដូចជាអច្ច័យទានដែលភ្ជាប់ជាមួយនឹងបន្ទុក ជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់នោះមានចំនួនលើសពីចំណែកមត៌ករបស់សន្តតិជន នោះត្រូវសន្មតថាបានកំណត់ចំណែកមត៌កផងដែរ។*

*២- ក្នុងករណីដែលមតកជនបានធ្វើមតកសាសន៍ ចំពោះទ្រព្យសម្បត្តិតែមួយនៅក្នុងចំណោមមត៌ក បើតម្លៃនៃទ្រព្យសម្បត្តិនោះ មានចំនួនតិចជាងចំណែកមត៌ក ដែលសន្តតិជននោះត្រូវទទួល លុះត្រាតែពុំមានការបង្ហាញឆន្ទៈផ្សេងទៀតនៅក្នុងមតកសាសន៍នោះ ត្រូវសន្មតថាបានកំណត់ត្រឹមតែវិធីបែងចែកមត៌កដែលត្រូវធ្លាក់ទៅលើសន្តតិជនតែប៉ុណ្ណោះ។"*

- ករណីមតកជនបានធ្វើមតកសាសន៍ចំពោះមត៌កទាំងអស់

ដោយហេតុថា ជាគោលការណ៍ ទោះបីជាមានមតកសាសន៍ ឬ គ្មានមតកសាសន៍ សន្តតិជនជាអ្នកដែលមានសិទ្ធិធ្វើសន្តតិកម្មទៅលើមត៌ករបស់មតកជន ដូច្នេះ ទើបគេត្រូវកំណត់ឱ្យបានច្បាស់លាស់ពីអត្ថន័យនៃអនុប្បទានទ្រព្យសម្បត្តិរបស់មតកជនចំពោះសន្តតិជនថាតើអនុប្បទាននោះមានអត្ថន័យជាអច្ច័យទាន ឬជាវិធីបែងចែកមត៌កជាអាទិ៍។

កថាខណ្ឌទី១ នៃមាត្រាខាងលើនេះ បានធ្វើការកំណត់នូវអត្ថន័យតាមផ្លូវច្បាប់អំពីការធ្វើអនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជនតាមរយៈមតកសាសន៍ថាជា **អច្ច័យទាន** ដោយបានផ្អែកលើល័ក្ខខ័ណ្ឌមួយចំនួនដូចខាងក្រោម។

ល័ក្ខខ័ណ្ឌទី១គឺ ការដែលមតកជនបានកំណត់យ៉ាងច្បាស់ថា អនុប្បទានទ្រព្យសម្បត្តិនោះគឺជាអច្ច័យទានតែម្តងនៅក្នុងមតកសាសន៍របស់ខ្លួន ដូចជា អច្ច័យទានដែលភ្ជាប់ជាមួយនឹងបន្ទុក ជាដើម (មាត្រា ១១៨៥ កថាខណ្ឌទី១)។ ល័ក្ខខ័ណ្ឌទី២គឺ តម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់ជាកម្មវត្ថុនៃអច្ច័យទាននោះមានតម្លៃតិចជាងចំណែកមត៌ករបស់សន្តតិជន(មាត្រា ១១៨៥ កថាខណ្ឌទី១)។ ប្រសិនបើល័ក្ខខ័ណ្ឌទាំងពីរនេះត្រូវបានបំពេញ នោះអនុប្បទានទ្រព្យសម្បត្តិនោះនឹងត្រូវបានចាត់ទុកថាជា អច្ច័យទាន។

ផ្ទុយទៅវិញ ក្នុងករណីដែលល័ក្ខខ័ណ្ឌទាំងពីរខាងលើនេះពុំត្រូវបានបំពេញ នោះនឹងត្រូវបែងចែកជា ២ ករណី គឺ ទី១ នៅក្នុងករណីដែលមតកសាសន៍ពុំបានបញ្ជាក់ច្បាស់លាស់ថាជាអច្ច័យទានឡើយ នោះមានន័យថាអនុប្បទានទ្រព្យសម្បត្តិនេះនឹងត្រូវបានចាត់ទុកថាជាការកំណត់នូវ **វិធីបែងចែកមត៌ក** និងទី២ នៅក្នុង

ករណីដែលតម្លៃនៃទ្រព្យសម្បត្តិដែលត្រូវបានធ្វើអនុប្បទាននោះមានចំនួនលើសពីចំណែកមត៌ករបស់សន្តតិជននោះនឹងត្រូវបានចាត់ទុកថាជា **ការកំណត់នូវចំណែកមត៌ក** ដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះ (មាត្រា ១១៨៥ កថាខណ្ឌទី១) ។

ដូចដែលបានបញ្ជាក់ខាងលើរួចមកហើយថា ការកំណត់នូវអត្ថន័យតាមផ្លូវច្បាប់នៃអនុប្បទានទ្រព្យសម្បត្តិនេះ មានសារៈសំខាន់ ពីព្រោះវានឹងជះឥទ្ធិពលដល់ចំនួននៃមត៌កដែលសន្តតិជនម្នាក់ៗត្រូវទទួល។ ជាក់ស្តែងគឺ ប្រសិនបើអនុប្បទាននេះត្រូវបានចាត់ទុកថាជា អច្ច័យទាន នោះទ្រព្យសម្បត្តិដែលត្រូវបានកំណត់នោះ នឹងក្លាយជាទ្រព្យបន្ថែមពីចំណែកមត៌កដែលសន្តតិជននោះត្រូវទទួលបាន។

សរុបមក ដើម្បីអាចសន្មតថាអនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជននោះ ជាអច្ច័យទាន ឬ ជាការវិធីបែងចែកមត៌ក ឬ ការកំណត់ចំណែកមត៌កដោយមតកជនបាន ត្រូវបំពេញនូវល័ក្ខខ័ណ្ឌពីរគឺ អនុប្បទានត្រូវមានអត្ថន័យច្បាស់លាស់ថាជាអច្ច័យទាន និង តម្លៃនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃអច្ច័យទាននោះមិនមានចំនួនលើសពីចំណែកមត៌ករបស់សន្តតិជននោះត្រូវទទួល (មាត្រា ១១៨៥ កថាខណ្ឌទី១)។

- ករណីមតកជនបានធ្វើមតកសាសន៍ចំពោះទ្រព្យសម្បត្តិមួយភាគនៅក្នុងចំណោមមត៌ក

នៅក្នុងករណីខ្លះ មតកជនអាចពុំបានធ្វើមតកសាសន៍ចំពោះទ្រព្យសម្បត្តិទាំងអស់ដែលជាមត៌កនោះទេ ហេតុនេះហើយទើប កថាខណ្ឌទី២ នៃមាត្រា ១១៨៥ ដដែលនេះ បានកំណត់ថា អនុប្បទានទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមតកសាសន៍នោះនឹងត្រូវបានសន្មតថា មតកជនបានកំណត់ត្រឹមតែវិធីបែងចែកមត៌កដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះដោយបានផ្អែកលើល័ក្ខខ័ណ្ឌមួយចំនួនដើម្បីជាជំនួយដល់ការសន្មតនេះ(មាត្រា ១១៨៥ កថាខណ្ឌទី២)។

ល័ក្ខខ័ណ្ឌទី១គឺ មតកជនបានធ្វើមតកសាសន៍ចំពោះទ្រព្យសម្បត្តិតែមួយភាគនៅក្នុងចំណោមមត៌កដូចដែលបានបង្ហាញនៅត្រង់ចំណងជើងនៃចំណុចខាងលើនេះ។ ចំណែក ល័ក្ខខ័ណ្ឌទី២គឺ តម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់នោះ មានចំនួនតិចជាងចំណែកមត៌កដែលសន្តតិជននោះត្រូវទទួល និងល័ក្ខខ័ណ្ឌទី៣គឺ ពុំមានការបង្ហាញឆន្ទៈផ្សេងទៀតរបស់មតកជននៅក្នុងមតកសាសន៍ឡើយ (មាត្រា ១១៨៥ កថាខណ្ឌទី២)។

ប្រសិនបើល័ក្ខខ័ណ្ឌទាំង ៣ ខាងលើនេះត្រូវបានបំពេញ នោះត្រូវសន្មតថាអនុប្បទានទ្រព្យសម្បត្តិចំពោះសនត្តិជនដែលមតកជនបានកំណត់នោះគឺ ត្រឹមតែជា **វិធីបែងចែកមត៌ក** ដែលត្រូវធ្លាក់ទៅលើសន្និជននោះតែប៉ុណ្ណោះ ពោលគឺ នឹងមានការបែងចែកចំណែកមត៌កនៅពុំទាន់ចប់សព្វគ្រប់នៅឡើយទេ។

មិនត្រឹមតែប៉ុណ្ណោះ ការកំណត់ខាងលើនេះ ក៏អាចនឹងមានទំនាក់ទំនងជាមួយនឹងការធ្វើសន្តតិកម្មជំនួសនៃសន្តតិជននោះផងដែរ (មាត្រា ១១៩៦) ចំពោះករណីដែលមតកសាសន៍ខាងលើត្រូវបានចាត់ទុកថាជាការកំណត់នូវវិធីបែងចែកមត៌ក ហើយសន្តតិជនដែលទទួលចំណែកនោះបានទទួលមរណភាព[30]។

- អនុប្បទានចំពោះតតិយជន

រីឯការធ្វើអនុប្បទានទ្រព្យសម្បត្តិឱ្យទៅតតិយជនវិញគឺជា អច្ច័យទាន (មាត្រា ១១៩៩) ហើយត្រូវអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង។ ទន្ទឹមនឹងនេះដែរ ប្រទានកម្មដោយមូលហេតុមរណភាព ក៏ត្រូវអនុវត្តតាមបញ្ញត្តិស្តីពីភាគបម្រុងនេះផងដែរ ពីព្រោះដូចដែលបានបង្ហាញនៅក្នុងជំពូកទី១ ផ្នែកទី១ កថាខណ្ឌទី៣ "ទំនាក់ទំនងមតកសាសន៍ និង ប្រទានកម្មដោយមូលហេតុមរណភាព" រួចមកហើយគឺ ប្រទានកម្មដោយមូលហេតុមរណភាព និង អច្ច័យទានមានចំណុចរួមគ្នាមួយគឺ អានុភាពរបស់វាកើតមានឡើងនៅពេលមរណភាពរបស់មតកជន។

ម្យ៉ាងទៀត ទាក់ទងនឹងការធ្វើអនុប្បទានទ្រព្យសម្បត្តិរបស់ម្ចាស់បណ្តាំខាងលើនេះ ត្រូវបានកម្រិតដោយត្រូវអនុលោមតាមបញ្ញត្តិនៃភាគបម្រុង ហេតុដូច្នេះ ទោះបីជាមតកជនត្រូវបានច្បាប់អនុញ្ញាតឱ្យធ្វើអនុប្បទានទ្រព្យសម្បត្តិក៏ដោយ ក៏ចំណែកនៃទ្រព្យសម្បត្តិដែលត្រូវបានធ្វើអនុប្បទានទាំងនោះនឹងត្រូវបានកាត់បន្ថយទាំងអស់ ឬ មួយផ្នែក ដើម្បីបង្គ្រប់ភាគបម្រុងតាមការទាមទារ ក្នុងករណីដែលចំណែកនោះបំពានភាគបម្រុង[31]។

លើសពីនេះទៅទៀត មតកជនក៏អាចធ្វើការកំណត់អំពីការធ្វើវិភាគទាននូវទ្រព្យសម្បត្តិរបស់ខ្លួនដើម្បីធ្វើការបង្កើតនូវនីតិបុគ្គលមូលនិធិផងដែរ ហើយដោយហេតុថាវាគឺជាសកម្មភាពដែលមិនយកតម្លៃតបស្នង ដូច្នេះបញ្ញត្តិនៃប្រទានកម្ម និងអច្ច័យទាន (មាត្រា ១១៣)។

## កថាខណ្ឌទី២ ខ្លឹមសារមិនទាក់ទងនឹងទ្រព្យសម្បត្តិ

### ក. ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍

ម្ចាស់បណ្តាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះ តាមមតកសាសន៍បាន(មាត្រា ១១៨៦)។

ក្នុងករណីនៃការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍នេះ ជនដែលអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍នេះពុំកម្រិតត្រឹមតែតតិយជននោះទេ តែក៏អាចកំណត់ឱ្យសហសន្តតិជនណាម្នាក់ជាអ្នកអនុវត្តមុខងារនេះផងដែរ។ ក៏ប៉ុន្តែចំណុចដែលគួរឱ្យកត់សម្គាល់នោះគឺ មតកជនពុំអាចចាត់តាំងឱ្យសហសន្តតិជនណាម្នាក់

[30] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦៖ គន្លីទី៨-៩,ទំព័រ.៤៩

[31] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦៖ គន្លីទី៨-៩,ទំព័រ.៤៨

ធ្វើជាអ្នកកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍ជំនួសខ្លួនបាននោះទេ ត្រង់ចំណុចនេះ គឺមានតែតតិយជនប៉ុណ្ណោះដែលអាចទទួលអាណត្តិនេះពីមតកជនបាន។ ឧទាហរណ៍ដូចជា នីតិបុគ្គលជាដើម[32]។

**ខ. ការកំណត់អំពីដំបូន្មាន និងចំណុចផ្សេងៗទៀតជាអាទិ៍**

• ការកំណត់អំពីដំបូន្មាន ឬ យោបល់ដើម្បីសុខដុមរមនាសម្រាប់គ្រួសារជាអាទិ៍

ក្រៅពីចំណុចដែលបានធ្វើការរៀបរាប់ខាងលើ បន្ថែមពីនោះ ចំណុចចុងក្រោយបង្អស់ដែលមតកជនអាចកំណត់បន្ថែមបាននៅក្នុងមតកសាសន៍របស់ខ្លួននោះគឺ មានចំណុចមួយចំនួនទៀតដែលកំណត់ដោយមាត្រា ១១៨៧ ដូចជា ការផ្តល់ដំបូន្មាន ឬ យោបល់ ដើម្បីឱ្យគ្រួសារមានភាពសុខដុមរមនា និងចំណុចផ្សេងៗទៀតដូចជា ការទទួលស្គាល់កូន ទំនៀមទម្លាប់ក្នុងសង្គម ជាដើម ហើយសន្តតិជនជាដើមនោះ ត្រូវតែគោរពទៅតាមមតកសាសន៍នោះ។

• ការកំណត់អំពីការទទួលស្គាល់កូន

មតកជនអាចកំណត់អំពីការទទួលស្គាល់កូនរបស់ខ្លួនបានតាមរយៈការកំណត់នៅក្នុងមតកសាសន៍របស់ខ្លួន ហើយនីតិវិធីនៅក្នុងការទទួលស្គាល់កូនដោយផ្អែកលើមតកសាសន៍នេះ ត្រូវអនុវត្តដោយអ្នកប្រតិបត្តិមតកសាសន៍ (មាត្រា ៩៩៧)។

• ការកំណត់អំពីអ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលនោះ

ក្នុងករណីដែលម្ចាស់បណ្តាំគឺជាអ្នកអនុវត្តអំណាចមេបាចុងក្រោយបង្អស់ចំពោះអនីតិជន នោះម្ចាស់បណ្តាំអាចកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានផងដែរ (មាត្រា ១០៦៨)។

ម្យ៉ាងទៀត អ្នកមានអំណាចមេបាដែលអាចកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជនក៏អាចកំណត់អំពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនតាមមតកសាសន៍បានផងដែរ (មាត្រា ១០៧៥)។

• ការកំណត់អំពីឆន្ទៈផ្តាច់មត៌ក

មតកជនក៏អាចបង្ហាញឆន្ទៈដោយផ្តាច់មត៌កពីសន្តតិជនណាមួយបានដែរតាមរយៈមតកសាសន៍របស់ខ្លួន (មាត្រា ១១៥១)។

**កថាខណ្ឌទី៣ បញ្ហានៃខ្លឹមសារមតកសាសន៍**

ពាក់ព័ន្ធនឹងខ្លឹមសារមតកសាសន៍ មានបញ្ហាចំនួន ២ នឹងត្រូវយកមកពិចារណា។

បញ្ហាទី១ គឺ បញ្ហានៃភាពមិនច្បាស់លាស់នៃខ្លឹមសារមតកសាសន៍។ នៅក្នុងករណីខ្លះ មតកសាសន៍អាចមានភាពមិនច្បាស់លាស់ត្រង់ចំណុចណាមួយ ហើយករណីដែលបញ្ហានេះកើតមានឡើង នោះវានឹងធ្វើឱ្យមាន

[32] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦៖ គន្លឹទី៨-៩,ទំព័រ.៥០

ការលំបាកក្នុងការបកស្រាយនូវខ្លឹមសារទាំងនោះ ដែលគេមិនអាចបកស្រាយឱ្យបានច្បាស់លាស់នូវខ្លឹមសាររបស់មតកសាសន៍បាន និង មិនអាចធានាបានថានៅក្រោយពេលដែលសន្តតិកម្មបានចាប់ផ្តើម ការចាត់ចែងមតកសាសន៍នោះពិតជាស្របទៅតាមគោលបំណងរបស់មតកជនពិតមែន ឬ យ៉ាងណា។

ឧទាហរណ៍ នៅក្នុងករណី លោក ក មានអាយុ ៨៥ ឆ្នាំ លោកមានកូន ខ និង គ។ ប៉ុន្តែបានកាត់កាល់ជាមួយ ខ និង គ តាំងពី ៤០ ឆ្នាំមុនម្ល៉េះ។ លោក ក បានធ្វើមតកសាសន៍តាមទម្រង់លិខិតឯកជន និង កំណត់ថា ទ្រព្យសម្បត្តិទាំងអស់របស់ខ្លួននឹងត្រូវយកទៅបម្រើសាធារណៈ។ តាមរយៈករណីនេះ សាលដីកាតុលាការកំពូលរបស់ប្រទេសជប៉ុន បានបកស្រាយថា មតកជនមិនបានបញ្ជាក់ឱ្យច្បាស់លាស់ថាត្រូវធ្វើយ៉ាងណាលើទ្រព្យសម្បត្តិខ្លួនត្រង់ឃ្លានេះក៏ពិតមែន ប៉ុន្តែដោយធ្វើការពិចារណាពីគោលបំណងនៃពាក្យពេចន៍របស់មតកជន និង ស្ថានភាពនាពេលដែលមតកជនបានធ្វើមតកសាសន៍នេះ បង្ហាញឱ្យឃើញថា លិខិតនោះមានគោលបំណងចង់ឱ្យទ្រព្យសម្បត្តិនេះទៅឱ្យស្ថាប័ន ឬ អង្គការនានាដែលបម្រើជូនដល់ផលប្រយោជន៍សាធារណៈ ហើយតុលាការជាអ្នកចាត់ចែងទៅតាមគោលបំណងនោះ[33]។ ចំពោះបញ្ហានេះ ការបកស្រាយបែបនេះគឺដោយឈរលើគោលការណ៍នៃការគោរពឆន្ទៈចុងក្រោយរបស់មតកជន ពោលគឺចៀសវាងបកស្រាយឱ្យមតកសាសន៍ត្រូវបាត់បង់អានុភាពដោយមូលហេតុដូចជា ការប្រើប្រាស់ពាក្យពេចន៍ ការបង្ហាញឆន្ទៈរបស់មតកជនមិនមានភាពច្បាស់លាស់នានា ហើយព្យាយាមបកស្រាយឱ្យលិខិតនេះឱ្យមានអានុភាពយកមកអនុវត្តតាមកម្រិតដែលអាចធ្វើបាន[34]។

លើសពីនេះ ក្នុងករណីស្រដៀងគ្នានេះដែរដូចជា មតកជនបានកំណត់ថា "ប្រាក់នៅសល់ ១៩០០ ដុល្លារទុកធ្វើបុណ្យសពឱ្យខ្លួន" ជាដើម ក៏ប្រហែលជានឹងត្រូវបានបកស្រាយដូចសាលក្រមរបស់តុលាការជប៉ុនផងដែរ គឺ ប្រាក់ដែលនៅសល់នោះនឹងពុំត្រូវធ្លាក់ទៅលើសន្តតិជនរបស់មតកជននោះទេ។

បញ្ហាទី២ គឺ បញ្ហាវិសាលភាពនៃអច្ច័យលាភី។ បញ្ហាគឺត្រង់ថា តើអច្ច័យលាភីត្រូវតែជារូបវន្តបុគ្គលដែរឬយ៉ាងណា។ តាមរយៈមាត្រា ១១៩៩ និង មាត្រា ១២០០ ដែលជាបទប្បញ្ញត្តិស្តីអំពីនិយមន័យនៃអច្ច័យទាន និង មរណភាពរបស់អច្ច័យលាភី បានរំលេចនូវសញ្ញាណនៃអច្ច័យលាភី ដោយការប្រើប្រាស់ពាក្យថា "មនុស្សម្នាក់ ឬច្រើននាក់" "មរណភាពរបស់អច្ច័យលាភី" និង ការផ្តល់សិទ្ធិទៅឱ្យសន្តតិជននៃអច្ច័យលាភីធ្វើការបោះបង់ឬទទួលស្គាល់អច្ច័យទាន (មាត្រា ១២០៣) ជាដើម។ តាមន័យនេះ មាត្រាទាំងនេះហាក់ដូចជាចង់

[33] ស៊ិអូមិ យ៉ូស៊ីអូ *ការពន្យល់លម្អិត ច្បាប់សន្តតិកម្ម* (កូប៊ឹងដូ , បោះពុម្ពឆ្នាំ ២០១៨) ទំព័រ ៣៦២, 潮見佳男『詳解　相続法』（弘文堂、2018 年）

[34] ស៊ិអូមិ យ៉ូស៊ីអូ *ការពន្យល់លម្អិត ច្បាប់សន្តតិកម្ម* (កូប៊ឹងដូ , បោះពុម្ពឆ្នាំ ២០១៨) ទំព័រ ៣៦៣, 潮見佳男『詳解　相続法』（弘文堂、2018 年）

កំណត់ថា អច្ច័យលាភីគឺជារូបវន្តបុគ្គល ហើយពុំបានបញ្ញត្តច្បាស់លាស់អំពីអច្ច័យលាភីដែលជានីតិបុគ្គលនោះទេ ។ ក៏ប៉ុន្តែ នីតិបុគ្គលក៏ត្រូវបានទទួលស្គាល់ថាជាប្រធាននៃសិទ្ធិ និងករណីយកិច្ចផងដែរ ប្រសិនបើពុំទទួលស្គាល់អច្ច័យទានចំពោះនីតិបុគ្គល ហាក់បីដូចជាកម្រិតសិទ្ធិរបស់មតកជន និង នីតិបុគ្គលជ្រុលពេក។

ពាក់ព័ន្ធនឹងបញ្ហានេះ ដោយផ្អែកតាមមាត្រា ៣០ នៃច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋបានចែងថា "លទ្ធកម្មនៃកម្មសិទ្ធិមកជាទ្រព្យសម្បត្តិរដ្ឋ អាចត្រូវបានធ្វើឡើងតាមរយៈកិច្ចសន្យាលក់ទិញ កិច្ចសន្យាដូរ ប្រទានកម្ម អច្ច័យទាន [...]" ។ ផ្អែកតាមបញ្ញត្តិនេះ អាចសន្និដ្ឋានបានថា នីតិបុគ្គលក៏អាចទទួលបានអច្ច័យទានដែរ ពីព្រោះរដ្ឋក៏ជានីតិបុគ្គលផងដែរ។

លើសពីនេះ ប្រសិនបើក្រឡេកទៅមើលបញ្ញត្តិដែលពាក់ព័ន្ធនឹងអច្ច័យទាន ប្រទេសជប៉ុន ឃើញថា នីតិបុគ្គល ក៏អាចក្លាយជាអច្ច័យលាភីបាន ដូចរូបវន្តបុគ្គលផងដែរដោយមាត្រា ៩៨៨ នៃក្រមរដ្ឋប្បវេណីជប៉ុនបានបញ្ញត្តថា "ម្ចាស់បណ្តាំអាចចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនទាំងអស់ ឬ មួយផ្នែកតាមរយៈអច្ច័យទានសកល ឬ អច្ច័យទានមានកំណត់បាន" ។ ផ្អែកតាមបញ្ញត្តិនេះ អាចសន្និដ្ឋានបានថា ម្ចាស់បណ្តាំអាចធ្វើអច្ច័យទានទៅកាន់រូបវន្តបុគ្គល ឬ នីតិបុគ្គល ក៏ពុំមានបញ្ហាអ្វីដែរ។ លើសពីនេះទៅទៀត តាមច្បាប់ស្តីពីពន្ធលើប្រាក់ចំណូលជប៉ុន មាត្រា ៥៩ បានកំណត់ថា ក្នុងករណីដែលអច្ច័យទានចំពោះនីតិបុគ្គលត្រូវបានធ្វើឡើង នោះនឹងត្រូវបានចាត់ទុកថាជាការធ្វើអនុប្បទានក្នុងតម្លៃទីផ្សារ [...] ។ ដូច្នេះ បញ្ញត្តិនេះកាន់តែបំភ្លឺយ៉ាងច្បាស់ថា នីតិបុគ្គលក៏អាចទទួលអច្ច័យទានពីមតកជនបានដូចរូបវន្តបុគ្គលផងដែរ។

សរុបសេចក្តីមក ដោយសង្កេតឃើញថា ទី១ ដូចដែលបានបង្ហាញរួចមកហើយ មតកជនអាចកំណត់អំពីវិភាគទានដើម្បីបង្កើតនីតិបុគ្គលមូលនិធិនៅក្នុងមតកសាសន៍របស់ខ្លួនបាន ទី២ នីតិបុគ្គលក៏ត្រូវបានទទួលស្គាល់ថាជាប្រធាននៃសិទ្ធិ និងករណីយកិច្ច និងទី៣ ដោយឈរលើគោលការណ៍ "ភាពដាច់ខាតនៃកម្មសិទ្ធិឯកជន" ដែលកម្មសិទ្ធិករអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យរបស់ខ្លួនបានដោយសេរី ព្រមទាំងធ្វើការសិក្សាពីប្រព័ន្ធច្បាប់នៃប្រទេសជប៉ុន ដែលបានបង្ហាញយ៉ាងច្បាស់ពីការដែលនីតិបុគ្គលអាចទទួលអច្ច័យទានបានផងដែរនោះ ជាទស្សនៈផ្ទាល់ខ្លួនឃើញថា ក្រមរដ្ឋប្បវេណីខ្មែរក៏ពុំមានហេតុផលមិនណាមួយដែលមិនអាចទទួលស្គាល់ នីតិបុគ្គលឱ្យទទួលអច្ច័យទានបាននោះដែរ។

# ជំពូកទី២ បញ្ហានៅក្នុងទិដ្ឋភាពនៃការប្រតិបត្តិមតកសាសន៍

## ផ្នែកទី១ បញ្ហានៃការបញ្ជាក់ពីអត្ថិភាពនៃមតកសាសន៍ចុងក្រោយ

ដោយមតកសាសន៍មានអានុភាពនៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ហើយនៅពេលដែលមតកជននៅរស់ និងបានធ្វើមតកសាសន៍នោះ គឺមានតែជនដែលពាក់ព័ន្ធដែលអាចជាម្ចាស់បណ្តាំសាមីខ្លួនផ្ទាល់ សាក្សី សារការីជាដើមអាស្រ័យទៅតាមទម្រង់នៃមតកសាសន៍ ហេតុនេះហើយដើម្បីអាចអនុវត្តមតកសាសន៍ ឬ ដើម្បីបញ្ជាក់ឱ្យដឹងច្បាស់ថា ពិតជាមានមតកសាសន៍មែន ឬ មិនមែននោះ គឺលុះត្រាតែត្រូវមានការពិនិត្យ និងបញ្ជាក់ពីអត្ថិភាពនៃមតកសាសន៍នោះ។

ដោយការពិនិត្យនេះ គឺត្រូវធ្វើឡើងនៅក្រោយពេលដែលមតកជនបានទទួលមរណភាព ក្នុងការពិនិត្យបញ្ជាក់នូវខ្លឹមសារដែលបានសរសេរ និង កំណត់ដោយមតកជន ក៏ដូចជាតួនាទីនៃអ្នកប្រតិបត្តិមតកសាសន៍ចាប់ផ្តើមកើតមានឡើងជាដើម។

### កថាខណ្ឌទី១ ការពិនិត្យបញ្ជាក់ និង ការបើកមតកសាសន៍

រាល់ប្រភេទនៃមតកសាសន៍ដែលធ្វើឡើងទាំងអស់ ក្រៅពីទម្រង់នៃលិខិតយថាភូត ត្រូវតែមានការពិនិត្យ និងបញ្ជាក់។ ការពិនិត្យ និងបញ្ជាក់នេះ គឺត្រូវធ្វើឡើងសម្រាប់ជនដែលមានផលប្រយោជន៍បានដឹងឮ និងដើម្បីកំណត់នូវខ្លឹមសារនៃមតកសាសន៍នោះ។ ហេតុនេះ អ្នកថែរក្សា គ្រប់គ្រងមតកសាសន៍ត្រូវដាក់ពាក្យសុំឱ្យមានការពិនិត្យទៅតុលាការនៅពេលដែលចាប់ផ្តើមអនុវត្តសន្តតិកម្ម។ ក្នុងករណីដែលរកឃើញមតកសាសន៍ ក្រោយមរណភាពរបស់របស់មតកជន គឺត្រូវតែធ្វើការដាក់ពាក្យសុំទៅតុលាការដោយគ្មានការយឺតយ៉ាវជាដាច់ខាត។

ចំពោះមតកសាសន៍ដែលប្រថាប់ត្រា ត្រូវដាក់ពាក្យសុំទៅតុលាការក្នុងការបើក ដើម្បីចៀសវាងការកែប្រែនៃមតកសាសន៍នោះ ដោយក្នុងពេលបើកមតកសាសន៍នេះ គឺត្រូវមានវត្តមានអ្នកសង្កេតការណ៍ជាសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ អ្នកតំណាងរបស់ជននោះ។ ប្រសិនបើមានការបើកលិខិត មតកសាសន៍នេះនៅក្រៅតុលាការ ថ្វីត្បិតតែអានុភាពរបស់មតកសាសន៍នៅរក្សាឱ្យមានដដែល តែការបើកមតកសាសន៍បែបនេះ គឺ នឹងត្រូវមានការពិន័យជាប្រាក់មិនលើសពី ១លានរៀល។ ការពិនិត្យបញ្ជាក់លិខិត មតកសាសន៍ គឺមានគោលបំណងក្នុងការបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃមតកសាសន៍ ដើម្បីមានភាពច្បាស់លាស់ចំពោះឆន្ទៈពិតប្រាកដរបស់មតកជន និងទម្រង់នៃមតកសាសន៍នោះ[35]។

[35] JICA, មេធាវី អ៊ីវ ប៉ូលី "ការបែងចែកមត៌ក" ១៥ មករា ២០១៨, ទំព័រ.១៧

**កថាខណ្ឌទី២ បញ្ហានៃការបញ្ជាក់ពីអត្ថិភាពនៃមតកសាសន៍ចុងក្រោយ**

ក្រោយពីមតកជនបានទទួលមរណភាព នោះនឹងត្រូវមានការពិនិត្យ និង បញ្ជាក់នូវខ្លឹមសារដែលបានសរសេរ និង កំណត់ដោយមតកជននោះដើម្បីអនុវត្តសន្តតិកម្មបាន។ ប៉ុន្តែ ដើម្បីពិនិត្យ និង បញ្ជាក់ពីខ្លឹមសារនៃមតកសាសន៍បាន លុះត្រាតែត្រូវដឹងពីអត្ថិភាពនៃមតកសាសន៍ជាមុនសិនថាពិតជាមានមតកសាសន៍មែន ឬមិនមែន ក្រោយពីដឹងថាពីអត្ថិភាពនៃមតកសាសន៍នោះហើយត្រូវកំណត់ឱ្យបានច្បាស់ថាតើមតកសាសន៍នោះពិតជាមតកសាសន៍ចុងក្រោយរបស់មតកជនដែរ ឬ យ៉ាងណា។ ហេតុនេះ តើនឹងត្រូវធ្វើដូចម្ដេចដើម្បីកំណត់នូវចំណុចទាំង ២ ខាងលើនេះបាន។

ពាក់ព័ន្ធនឹងបញ្ហានេះដោយប្រទេសកម្ពុជាពុំមានការពិភាក្សាណាមួយលើចំណុចទាំងនេះឡើយ ដូចនេះហើយការបកស្រាយបង្ហាញពីបទពិសោធន៍នៃប្រទេសជប៉ុននឹងត្រូវបានយកមកបង្ហាញដូចខាងក្រោយ។

ជុំវិញការកំណត់ឱ្យដឹងថាតើមតកសាសន៍ពិតជាមានមែន ឬ មិនមែន និង បញ្ជាក់ឱ្យដឹងថាតើមតកសាសន៍នោះគឺជាលិខិតចុងក្រោយដែរ ឬ យ៉ាងណា គឺនៅឯប្រទេសជប៉ុនបានប្រើប្រាស់ប្រព័ន្ធ ២ ដែលប្រព័ន្ធនោះគឺសម្រាប់ត្រួតពិនិត្យ ក៏ដូចជាស្រាវជ្រាវក្នុងការរកឱ្យឃើញថាកាលមតកជននៅរស់ បានបន្សល់នូវមតកសាសន៍ដែរ ឬ ទេ។ និងតាមរយៈការប្រើប្រាស់ប្រព័ន្ធទាំង ២ នេះក្រៅពីការស្រាវជ្រាវនេះ គេក៏អាចដឹងដែរថាតើមតកសាសន៍នោះជាលិខិតចុងក្រោយដែរ ឬ យ៉ាងណា។ ប្រព័ន្ធទាំង ២ នោះ គឺ**ប្រព័ន្ធស្វែងរកមតកសាសន៍** ដែលត្រូវបានប្រើប្រាស់សម្រាប់មតកសាសន៍ជាលិខិតយថាភូត[36] និង **ប្រព័ន្ធរក្សាទុក ឬ តម្កល់មតកសាសន៍** ដែលត្រូវបានប្រើប្រាស់សម្រាប់មតកសាសន៍ជាលិខិតឯកជន[37]។

ដោយ**ប្រព័ន្ធស្វែងរកមតកសាសន៍** នេះត្រូវបានប្រើប្រាស់គ្រប់មន្ទីរសារការីទូទាំងប្រទេសជប៉ុនក្នុងការស្វែងរកពីអត្ថិភាពនៃមតកសាសន៍ជាលិខិតយថាភូត ដោយសារតែនៅមន្ទីរសារការីមានការធ្វើមតកសាសន៍ជាមានការគ្រប់គ្រង និង រក្សាទុកនូវរាល់ទិន្នន័យទាំងអស់ទាក់ទងនឹងមតកសាសន៍ជាលិខិតយថាភូត នោះគេអាចធ្វើការស្វែងរក និង បញ្ជាក់ពីអត្ថិភាពនៃមតកសាសន៍ទម្រង់នេះបានយ៉ាងងាយស្រួល។ ចំពោះទិន្នន័យដែលពាក់ព័ន្ធនឹងមតកសាសន៍ក្នុងករណីនេះរួមមាន ឈ្មោះមន្ទីរសារការី ឈ្មោះរបស់សារការី ឈ្មោះមតកជន កាលបរិច្ឆេទនៃការធ្វើមតកសាសន៍ និង ព័ត៌មានផ្សេងទៀតត្រូវបានរក្សាទុក និង គ្រប់គ្រង ហេតុនេះហើយ នៅពេលដែលមតកជនបានទទួលមរណភាព សន្តតិជនអាចដឹងពីអត្ថិភាពនៃមតកសាសន៍បានតាមរយៈប្រព័ន្ធ

[36] មន្ទីរសារការីនៅទីក្រុងខូបេ ប្រទេសជប៉ុន, *ប្រព័ន្ធស្វែងរកមតកសាសន៍*
(http://kobe-koushou-center.jp/igonkensaku.html)

[37] ក្រសួងយុត្តិធម៌ជប៉ុន, *ប្រព័ន្ធរក្សាទុក និង តម្កល់មតកសាសន៍ជាលិខិតឯកជន*
(https://www.moj.go.jp/MINJI/minji03_00051.html)

ស្វែងរកមតកសាសន៍នេះ។ ម៉្យាងវិញទៀត ការប្រើប្រាស់ប្រព័ន្ធនេះគឺមិនមានការចំណាយសោហ៊ុយអ្វីឡើយ[38] ហើយអាចប្រើប្រាស់បានសម្រាប់គ្រប់មន្ទីរសារការីទាំងអស់ មិនចាំបាច់ត្រូវតែធ្វើនៅមន្ទីរសារការីជាក់លាក់ណាមួយទេ ដូចនេះវាក៏អាចផ្តល់ជាការសម្រួលដល់ការធ្វើដំណើរ និង ការចំណាយនានាផងដែរ។ លើសពីនេះដោយសារនៅក្នុងទិន្នន័យនៃប្រព័ន្ធនេះមានរក្សាទុកនូវកាលបរិច្ឆេទច្បាស់លាស់នោះ ការកំណត់ឱ្យដឹងថាតើមតកសាសន៍នោះពិតជាលិខិតចុងក្រោយដែរ ឬ យ៉ាងណាក៏លែងជាបញ្ហាអ្វីដែរ។

រីឯចំពោះមតកសាសន៍ជាលិខិតឯកជនវិញ ដើម្បីអាចបញ្ជាក់ពីអត្ថិភាព និង កំណត់ថាលិខិតនោះពិតជាលិខិតចុងក្រោយ ឬ យ៉ាងណានោះ គឺគេប្រើប្រាស់**ប្រព័ន្ធរក្សាទុក និង តម្កល់មតកសាសន៍**វិញ ដែលប្រព័ន្ធនេះគឺប្រើសម្រាប់តែមតកសាសន៍ទម្រង់នេះទេ ដោយនៅពេលមតកជននៅរស់បានដាក់ពាក្យសុំសម្រាប់ការរក្សាទុកនូវមតកសាសន៍របស់ខ្លួនទៅកាន់ការិយាល័យច្បាប់នៃក្រសួងយុត្តិធម៌ ដូចនេះរាល់ទិន្នន័យនានានៃលិខិតនេះនឹងត្រូវបានរក្សាទុក ហើយប្រសិនបើមានការផ្លាស់ប្តូរ ឬ ការលុបចោលនានានោះ មតកជននឹងធ្វើការស្នើទៅកាន់ការិយាល័យម្តងទៀតសម្រាប់ការរក្សាទុកនោះរហូតដល់មតកជនបានទទួលមរណភាព។ ហេតុនេះហើយ ប្រសិនបើមតកជនបានទទួលមរណភាព ដើម្បីអាចដឹងថាមានមតកសាសន៍ទម្រង់នេះដែរ ឬ យ៉ាងណាសន្តតិជនអាចធ្វើការជូនដំណឹងពីការទទួលមរណភាពរបស់មតកជន និង ដាក់ពាក្យស្នើសុំឱ្យមានការពិនិត្យមតកសាសន៍នោះបានដោយឥតគិតថ្លៃ ដោយសារបន្ទុកនៃការចំណាយក្នុងការប្រើប្រាស់ប្រព័ន្ធនេះត្រូវបានធ្វើដោយមតកជនកាលនៅរស់រួចហើយ ហេតុនេះសន្តតិជននឹងមិនមានបន្ទុកក្នុងការចំណាយសម្រាប់ប្រព័ន្ធនេះម្តងទៀតឡើយ។ រីឯចំពោះការបញ្ជាក់ថាមតកសាសន៍នោះពិតជាមតកសាសន៍ចុងក្រោយមែន ឬ មិនមែន ក៏មិនមានជាបញ្ហាដែរ ដោយសារតែនៅពេលដែលមតកជនបានដាក់ពាក្យសុំសម្រាប់ការរក្សាមតកសាសន៍របស់ខ្លួននោះ មានការកំណត់នូវកាលបរិច្ឆេទច្បាស់លាស់ ទោះជាមានការផ្លាស់ប្តូរណាមួយក៏ដោយ។

សរុបមក ការប្រើប្រាស់នូវប្រព័ន្ធទាំង ២ នេះ គឺជាមធ្យោបាយងាយស្រួលទាំងការកំណត់ពីអត្ថិភាព និង បញ្ជាក់ពីភាពចុងក្រោយនៃមតកសាសន៍បាន។ ថ្វីត្បិតតែប្រព័ន្ធទាំង ២ នេះអាចប្រើប្រាស់បានតែលើទម្រង់មតកសាសន៍ជាលិខិតឯកជន និង មតកសាសន៍ជាលិខិតយថាភូតក៏ពិតមែន ក៏ប៉ុន្តែការប្រើប្រាស់នៃ

---

[38] មន្ទីរសារការីនៅទីក្រុងខូបេ ប្រទេសជប៉ុន, *ប្រព័ន្ធស្វែងរកមតកសាសន៍*
(http://kobe-koushou-center.jp/igonkensaku.html)
ក្រុមហ៊ុន អាសាហ៊ី ស៊្រីមប៊ឹង, មេធាវី ខាស៊ូម៉ូតូ ខូតាក់, *ការមិនដឹងថាឪពុកម្តាយបានបន្សល់ទុកមតកសាសន៍ ឬ ទេ របៀបប្រើប្រាស់ "ប្រព័ន្ធស្វែងរកមតកសាសន៍"*
(https://bit.ly/3p8YhKF)

មតកសាសន៍ទាំង ២ ប្រភេទនេះ ក៏ឃើញមានច្រើន[39] ហើយ បញ្ហាប្រឈមលើលិខិតទាំង ២ ទម្រង់នេះ ជាពិសេសគឺមតកសាសន៍ជាលិខិតឯកជនក៏មានច្រើនដែរ [40] ។ ហេតុនេះហើយ ការដែលមានប្រព័ន្ធសម្រាប់ដោះស្រាយនូវបញ្ហារបស់មតកសាសន៍ទាំង ២ ប្រភេទនេះ ពិតជាមានសារៈសំខាន់ រីឯមតកសាសន៍ដោយលិខិតសម្ងាត់វិញ តើមានប្រព័ន្ធណាមួយសម្រាប់មតកសាសន៍ប្រភេទនេះដែរ ឬ យ៉ាងណា ហើយមានការពិចារណាយ៉ាងដូចម្តេចនោះនឹងត្រូវបន្សល់ទុកជាចំណុចសម្រាប់ការស្រាវជ្រាវបន្តទៀត។

## ផ្នែកទី២ បញ្ហាមតកសាសន៍ និងប្រទានកម្មដោយមូលហេតុមរណភាពដែលមានខ្លឹមសារផ្ទុយគ្នា និង បញ្ហានៃការបែងចែកមត៌កខុសពីខ្លឹមសារមតកសាសន៍

នៅក្នុងដំណាក់កាលក្រោយពីមតកសាសន៍ចុងក្រោយត្រូវបានពិនិត្យ និងបញ្ជាក់ឱ្យដឹងច្បាស់ពីអត្ថិភាពរួច មានបញ្ហា ២ អាចនឹងកើតឡើង។

ក្នុងនោះ ប្រសិនបើមតកជនបានធ្វើប្រទានកម្មដោយមូលហេតុមរណភាពផ្ទុយពីខ្លឹមសារដែលមានក្នុងមតកសាសន៍ នោះនឹងបណ្តាលឱ្យមានបញ្ហាថា ត្រូវផ្តល់អាទិភាពដល់ខ្លឹមសាររបស់មតកសាសន៍ ឬ ខ្លឹមសាររបស់ប្រទានកម្មដោយមូលហេតុមរណភាព ។ បញ្ហានេះនឹងត្រូវបកស្រាយនៅក្នុង កថាខណ្ឌទី១ (បញ្ហាមតកសាសន៍ និងប្រទានកម្មដោយមូលហេតុមរណភាពដែលមានខ្លឹមសារផ្ទុយគ្នា) ។

ចំណែកឯបញ្ហាមួយទៀតគឺ មិនពាក់ព័ន្ធនឹងប្រទានកម្មដោយមូលហេតុមរណភាពទេ តែបែរជាពាក់ព័ន្ធនឹងការពិភាក្សារបស់សហសន្តតិជនជាអាទិ៍ ដែលមានបំណងចង់បែងចែកមត៌កខុសពីខ្លឹមសារដែលមាននៅក្នុងមតកសាសន៍ទៅវិញ នៅក្នុងករណីនេះតើត្រូវពិចារណាយ៉ាងណា ដែលបញ្ហានេះនឹងត្រូវយកមកបង្ហាញនៅកថាខណ្ឌទី២ (បញ្ហានៃការបែងចែកមត៌កខុសពីខ្លឹមសារមតកសាសន៍)។

### កថាខណ្ឌទី១ បញ្ហាមតកសាសន៍ និងប្រទានកម្មដោយមូលហេតុមរណភាពដែលមានខ្លឹមសារផ្ទុយគ្នា

ដើម្បីបកស្រាយអំពីបញ្ហាមតកសាសន៍ និងប្រទានកម្មដោយមូលហេតុមរណភាពដែលមានខ្លឹមសារផ្ទុយគ្នា (ខ.បញ្ហាមតកសាសន៍ និងប្រទានកម្មដោយមូលហេតុមរណភាពដែលមានខ្លឹមសារផ្ទុយគ្នា) ឱ្យបាន

[39] ក្រុមហ៊ុន អាសាហ៊ី ស៊ីមប៊ឹង, មេធាវី ខាស៊ូម៉ូតូ ខូតាក់, *ការមិនដឹងថាឪពុកម្តាយបានបន្សល់ទុកមតកសាសន៍ ឬ ទេ របៀបប្រើប្រាស់ "ប្រព័ន្ធស្វែងរកមតកសាសន៍"*
(https://bit.ly/3p8YhKF)

[40] លេខាធិការដ្ឋានទីស្តីការគណៈរដ្ឋមន្ត្រី, ការិយាល័យទំនាក់ទំនងសាធារណៈ, *ប្រព័ន្ធរក្សាទុក និង តម្កល់មតកសាសន៍ជាលិខិតឯកជនដើម្បីការពារពីការបាត់បង់ និង ការក្លែងបន្លំ*
(https://www.gov-online.go.jp/useful/article/202009/1.html#a2)

ក្បោះក្បាយ យើងនឹងធ្វើការសិក្សាប្រៀបធៀបពីអានុភាពនៃមតកសាសន៍ និងប្រទានកម្មដោយមូលហេតុមរណភាព (ក. ប្រៀបធៀបអានុភាពនៃមតកសាសន៍ និងប្រទានកម្មដោយមូលហេតុមរណភាព) ជាមុនសិន។

**ក. ប្រៀបធៀបអានុភាពនៃមតកសាសន៍ និងប្រទានកម្មដោយមូលហេតុមរណភាព**

នៅពេលដែលមតកសាសន៍មានអានុភាព អានុភាពនានាដែលទាក់ទងនឹងមតកសាសន៍នឹងត្រូវបានចាប់ផ្តើមឡើង ហើយអានុភាពទាំងនោះរួមមាន អានុភាពនៃការកំណត់ចំណែកមត៌ក អានុភាពនៃអច្ច័យទាន និង ប្រទានកម្មដោយមូលហេតុមរណភាពផ្សេងៗជាដើម។

❖ អានុភាពនៃការកំណត់ចំណែកមត៌ក

នៅករណីដែលមតកសាសន៍មានភ្ជាប់នូវល័ក្ខខ័ណ្ឌបង្អង់នេះ គឺគេអាចសន្មតថា ម្ចាស់បណ្តាំមានបំណងធ្វើមតកសាសន៍នេះ សម្រាប់សន្តតិជនណាម្នាក់សម្រាប់ពេលអនាគតក្នុងចំណោមសហសន្តតិជនដែលល័ក្ខខ័ណ្ឌបង្អង់ត្រូវបានសម្រេចក្រោយពេលម្ចាស់បណ្តាំបានទទួលមរណភាព[41] ។ ហើយនៅពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅពេលក្រោយដែលម្ចាស់បណ្តាំបានទទួលមរណភាពនោះ ទ្រព្យសម្បត្តិដែលបានកំណត់នោះនឹងត្រូវបានទៅលើសន្តតិជនដែលត្រូវនឹងទទួលនូវទ្រព្យសម្បត្តិនោះ ដោយស្វ័យប្រវត្តិ។

ក្នុងករណីដែលមានការកំណត់នូវវិធីបែងចែកមត៌ក តាមមតកសាសន៍ នោះគឺមានន័យថា មត៌កគឺត្រូវបានបែងចែកតាមវិធីកំណត់នោះ ដោយមិនចាំបាច់មានការឆ្លងកាត់ការពិភាក្សាដោយសន្តតិជនពីការបែងចែកមត៌កនោះឡើយ។ ហេតុនេះហើយ កាលណាដែលម្ចាស់បណ្តាំបានកំណត់នូវការកំណត់ចំណែកមត៌ក ឬ វិធីបែងចែកមត៌កដោយការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តាមមតកសាសន៍រួចហើយនោះ នៅពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ទ្រព្យសម្បត្តិជាក់លាក់នោះ នឹងត្រូវធ្លាក់ទៅលើសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះដោយស្វ័យប្រវត្តិ នៅពេលព្រមគ្នាជាមួយនឹងមតកសាសន៍នោះមានអានុភាព។ ចំណែកឯការបែងចែកកម្មសិទ្ធិជាអចលនវត្ថុវិញ គឺសន្តតិជនធ្វើលទ្ធកម្មលើកម្មសិទ្ធិនោះ ស្របពេលដែលមតកសាសន៍នោះមានអានុភាពកើតឡើង ក៏ប៉ុន្តែសម្រាប់ការអនុវត្តជាក់ស្តែងដើម្បីទទួលបានល័ក្ខខ័ណ្ឌតតាំង ឬ ធ្វើការចាត់ចែងលើអចលនវត្ថុនោះបាន ត្រូវមានការចុះបញ្ជីផ្ទេរកម្មសិទ្ធិពីមតកជនទៅសន្តតិជនដែលត្រូវទទួលមត៌កនោះ[42]។

---

[41] សមិទ្ធផលរបស់JICA "ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១" ឆ្នាំ ២០១៥ "សន្តតិកម្មតាមមតកសាសន៍ "តចប់"", ទំព័រ.៦៤

[42] សមិទ្ធផលរបស់JICA "ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១" ឆ្នាំ ២០១៥ "សន្តតិកម្មតាមមតកសាសន៍ "តចប់"", ទំព័រ.៦៤

ម្យ៉ាងវិញទៀតសន្តតិជនត្រូវធ្វើ**ការយល់ព្រមទទួលទ្រព្យ ឬ ដោយយល់ព្រមដោយកម្រិត ឬ បោះបង់សន្តតិកម្មទាំងស្រុងលើសន្តតិកម្ម** នៅក្នុងអំឡុងពេល ៣ ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មបានចាប់ផ្តើមថាខ្លួនព្រមទទួល ឬ យ៉ាងណា។ ជាគោលការណ៍ការយល់ព្រម ឬ ការបោះបង់មិនអាចលុបចោលបានទេ ដោយហេតុថាការយល់ព្រម ឬ ការបោះបង់មានឥទ្ធិពលទៅលើផលប្រយោជន៍របស់បុគ្គលពាក់ព័ន្ធដូចជាម្ចាស់បំណុលរបស់មតកជនជាដើម។ ដូចនេះក្នុងអំឡុងពេល ៣ ខែនេះ សន្តតិជនអាចពន្យារពេលបានតាមរយៈការដាក់ពាក្យសុំទៅតុលាការដើម្បីទុកពេលក្នុងការស្រាវជ្រាវមត៌កនៅមុនពេលដែលបង្ហាញឆន្ទៈយល់ព្រម ឬ បោះបង់។

**ការយល់ព្រម** អាចមានការយល់ព្រមទាំងស្រុង និង ការយល់ព្រមមានកម្រិត។ ដោយការយល់ព្រមទាំងស្រុងគឺ សន្តតិជនត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជននោះ (មាត្រា ១២៥៤) រីឯតើការបង្ហាញឆន្ទៈនៃការយល់ព្រមនេះត្រូវធ្វើចំពោះនរណានោះគឺមិនមានចែងនៅក្នុងបញ្ញត្តិណាឡើយ ក៏ប៉ុន្តែដោយយោងតាមយុត្តិសាស្ត្រ និង ទស្សនៈទូទៅនៅក្នុងប្រទេសជប៉ុន បានបកស្រាយថា ការយល់ព្រមប្រភេទនេះ គឺអាចយល់ព្រមតាមការបង្ហាញឆន្ទៈដោយមិនចាំបាច់ដាក់ពាក្យសុំទៅតុលាការទេ[43] ។ រីឯការយល់ព្រមដោយមានកម្រិតវិញ គឺសន្តតិជនអាចកម្រិតការទទួលខុសត្រូវនូវកាតព្វកិច្ចរបស់មតកជនត្រឹមកម្រិតនៃចំណែកមត៌កដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម (មាត្រា ១២៥៦) ដោយការដាក់ពាក្យសុំទៅតុលាការក្នុងរយៈពេល ៣ ខែ គិតចាប់ពីពេលដែលដឹងថាសន្តតិកម្មបានចាប់ផ្តើម (មាត្រា ១២៥៨)។

ម្យ៉ាងវិញទៀតចំពោះ**ការបោះបង់**សន្តតិកម្មវិញ គឺដូចជាការយល់ព្រមមានកម្រិតដែរដោយបុគ្គលដែលធ្វើការបោះបង់នេះត្រូវដាក់ពាក្យសុំទៅតុលាការក្នុងអំឡុងពេល ៣ ខែ គិតចាប់ពីពេលដែលបានដឹងថាសន្តតិកម្មបានចាប់ផ្តើម (មាត្រា ១២៦០) ហើយនៅក្រោយពេលដែលបុគ្គលដែលបានបោះបង់សន្តតិកម្មរួចនឹងត្រូវចាត់ទុកថាបុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក (មាត្រា ១២៦១) ។

ដោយក្នុងទិដ្ឋភាពនៃដំណាក់កាលនេះ អាចនឹងមាន **មរណភាពនៃសន្តិតជន** កើតមានឡើង ហេតុនេះហើយ (មាត្រា ១១៩៦ នៃក្រមរដ្ឋប្បវេណីកម្ពុជាបានចែងពីមរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជនជាអាទិ៍ ដោយនៅក្នុងករណីដែលមតកសាសន៍បានធ្វើការកំណត់នូវការកំណត់ចំណែកមត៌ករបស់សន្តតិជន ឬ ការកំណត់នូវវិធីបែងចែកមត៌កដោយមតកសាសន៍) បើជនដែលត្រូវបានសន្មតថាជាសន្តតិជនបានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ឬ ការកាត់កាល់សន្តតិជន ការកំណត់នោះត្រូវបានចាត់ទុកថា បានធ្វើចំពោះអ្នកទទួលសន្តតិម្មជំនួសរបស់ជនដែលត្រូវបានសន្មតថាជា

[43] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ គន្ថីទី៨ -ទី៩ ឆ្នាំ ២០១០, ទំព័រ.១១៥

សន្តតិជននោះ។ ក្នុងករណីនេះ គេអាចយល់ឃើញថា មតកជនមានឆន្ទៈចង់ឱ្យអ្នកធ្វើសន្តតិកម្មជំនួសជនដែលត្រូវបានសន្មតថាជាសន្តតិជននោះទទួលនូវចំណែកមត៌កដែលបានកំណត់នោះ ដែលហេតុនេះទើបមានការចែងកំណត់ចំពោះអ្នកទទួលសន្តតិកម្មជំនួសនោះ ដែលវាមានន័យថា កាលណាជនដែលត្រូវបានសន្មតថាជាសន្តតិជន ប៉ុន្តែបានទទួលមរណភាពមុនពេលចាប់ផ្ដើមនៃសន្តតិកម្ម នោះអ្នកទទួលសន្តតិកម្មជំនួសរបស់ជននោះនឹងមានសិទ្ធិក្នុងការទទួលសន្តតិកម្មនេះ។ ម៉្យាងទៀត អ្នកទទួលសន្តតិកម្មជំនួសត្រូវតែជាបច្ឆាញាតិផ្ទាល់របស់មតកជនដែលអាចនិយាយបានថា អ្នកទទួលសន្តតិកម្មជំនួសគឺជាចៅរបស់មតកជន ឬ ជាកូនរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជន (មាត្រា ១១៥៧)។

❖ អានុភាពនៃអច្ច័យទាន និង ប្រទានកម្មដោយមូលហេតុមរណភាព

អច្ច័យទាននឹងមានអានុភាពកើតមានឡើងនៅពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព។ ពោលគឺនៅក្រោយពេលមរណភាពរបស់ម្ចាស់បណ្ដាំ អានុភាពប្រតិសកម្មរបស់អច្ច័យទាន **អច្ច័យទានមានភ្ជាប់បន្ទុក** នឹងកើតមាន ហើយការបោះបង់ ឬ ការទទួលស្គាល់របស់អច្ច័យលាភី ក៏ដូចជាការដាស់តឿនអំពីអច្ច័យទានពីបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធអច្ច័យទាន និង អ្នកមានផលប្រយោជន៍ ក៏អាចត្រូវបានអនុវត្តផងដែរ។ ដោយការទទួលស្គាល់ ឬ ការបោះបង់នេះ មានដូចជា**ការទទួលស្គាល់ ឬ បោះបង់ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន និង ក្នុងករណីជាតតិយជន។**

ក្នុងករណីដែលបុគ្គលដែលបានទទួល**អច្ច័យទានដែលភ្ជាប់បន្ទុក**នោះ ការអនុវត្តករណីយកិច្ចដែលតម្រូវឱ្យធ្វើទេនោះ ក៏ត្រូវបានទាមទារឱ្យអនុវត្តផងដែរ (មាត្រា ១២១១) ។ ហេតុនេះហើយទើបមានការទទួលស្គាល់ ឬ ការបោះបង់អច្ច័យទានកើតមានឡើង។

**ចំពោះការទទួលស្គាល់ ឬ បោះបង់អច្ច័យទានករណីដែលអច្ច័យលាភីជាសន្តតិជន** ក្នុងករណីដែលមតកជនមានកាតព្វកិច្ច តែបានធ្វើអច្ច័យទានដោយបញ្ជាក់ថា "ធ្វើអច្ច័យទាន" ឱ្យសន្តតិជននូវទ្រព្យជាក់លាក់ណាមួយ ប្រសិនបើសន្តតិជននោះទទួលស្គាល់ទទួលយកតែអច្ច័យទាន ដោយបោះបង់នូវសន្តតិកម្មនោះ ជននោះនឹងមិនមានបន្ទុកនូវកាតព្វកិច្ច តែគឺទទួលយកតែផលប្រយោជន៍តែប៉ុណ្ណោះ ដែលជាហេតុធ្វើឱ្យមានភាពមិនយុត្តិធម៌សម្រាប់សន្តតិជនដទៃទៀតជាដើម ហេតុនេះហើយទើបកាលណាដែលអច្ច័យលាភីជាសន្តតិជន បើបានបោះបង់សន្តតិកម្ម នោះជននោះក៏ត្រូវចាត់ទុកថាបានបោះបង់នូវអច្ច័យទានផងដែរ។

**ចំពោះករណីដែលអច្ច័យលាភីជាតតិយជន** វិញ គឺអាចធ្វើឡើងនៅពេលណាក៏បាន តែគឺអាចធ្វើឡើងនៅក្រោយដែលមតកជនបានទទួលមរណភាពប៉ុណ្ណោះ លើកលែងតែចំពោះករណីការបោះបង់អច្ច័យលាភីសកលគឺត្រូវអនុវត្តតាមបញ្ញត្តិស្ដីពីការបោះបង់សន្តតិកម្ម។ នៅក្នុងករណីដែលអច្ច័យទានមានភ្ជាប់នូវល័ក្ខខ័ណ្ឌបង្អង់ណាមួយ នោះទោះបីជាម្ចាស់បណ្ដាំបានទទួលមរណភាពក៏ដោយ ប្រសិនបើល័ក្ខខ័ណ្ឌនោះមិនបានបំពេញទេ

ឬ ក្រោយមកអច្ច័យលាភីបានទទួលមរណភាពនៅមុនពេលដែលខ្លួនបានបំពេញនូវល័ក្ខខ័ណ្ឌនោះ អច្ច័យទានពុំបង្កើតអានុភាពឡើយ។

ក្រៅពីការទទួលស្គាល់ និង ការបោះបង់អច្ច័យទាន **មរណភាពនៃអច្ច័យលាភី** ដោយមិនទាន់មានការបង្ហាញថាខ្លួនទទួលស្គាល់ ឬ បោះបង់អច្ច័យទាននៅឡើយក៏អាចកើតមានផងដែរ។ ដោយក្នុងករណីនេះចំពោះមរណភាពនៃអច្ច័យលាភីដែលជាសន្តតិជននោះវានឹងមិនមានបញ្ហាអ្វីទេ ដោយសារតែមានសន្តតិជនជំនួសរបស់សន្តតិជននោះ អាចនឹងមានសិទ្ធិបន្តថានឹងត្រូវធ្វើការទទួលស្គាល់ ឬ បោះបង់អច្ច័យទាននោះ។ ប៉ុន្តែចំពោះមរណភាពអច្ច័យលាភីដែលជាតតិយជនវិញនឹងត្រូវពិចារណាយ៉ាងណា។ ក្នុងករណីនេះប្រសិនបើអច្ច័យលាភីបានទទួលមរណភាពមុន ឬ អំឡុងពេលសន្តតិកម្មចាប់ផ្តើម នោះអច្ច័យទាននឹងមិនមានអានុភាពនោះទេ ដែលគេហៅថាអច្ច័យទានមោឃៈ នោះក៏មិនអាចមានការទទួលស្គាល់ ឬ ការបោះបង់អច្ច័យទានបានដែរ។ រីឯក្នុងករណីដែលអច្ច័យលាភីបានទទួលមរណភាពក្រោយសន្តតិកម្មចាប់ផ្តើមនោះ សន្តតិជនរបស់អច្ច័យលាភី នឹងទទួលសន្តតិកម្មនូវអច្ច័យលាភីនោះ។ ក៏ប៉ុន្តែ នៅពេលដែលអច្ច័យលាភីបានទទួលមរណភាពដោយមិនបានទទួលស្គាល់ ឬ មិនបានបោះបង់អច្ច័យទាននោះ សន្តតិជនរបស់អច្ច័យទាននេះ អាចទទួលស្គាល់ ឬ បោះបង់អច្ច័យទានបានត្រឹមទំហំនៃសន្តតិកម្មរបស់ខ្លួន។

ដើម្បីការពារដល់បុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ក្រៅពីនេះជាគោលការណ៍អច្ច័យលាភីដែលបានទទួលស្គាល់ ឬ បោះបង់អច្ច័យទានម្តងហើយ គឺមិនអាចលុបចោលនូវការទទួលស្គាល់ ឬ ការបោះបង់ដែលបានធ្វើនោះទេ (លើកលែងអច្ច័យលាភីបាន ធ្វើការទទួលស្គាល់ ឬ បោះបង់នូវអច្ច័យទាន ដោយសារតែមានវិការៈ ដូចជាក្នុងករណីដែលមានការគម្រាមកំហែងឱ្យបោះបង់អច្ច័យទានពីបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន) ។

លើសពីការទទួលស្គាល់ ឬ បោះបង់នានា ក៏មាន**ការការដាស់តឿនរបស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍សម្រាប់ករណីដែលមានអច្ច័យទាន** (មាត្រា ១២០២) ផងដែរ ។ បុគ្គលដែលអាចធ្វើការដាស់តឿនគឺជាជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន ដែលក្នុងនោះអាចរួមមានដូចជា សន្តតិជន អច្ច័យលាភីសកល ឬ នីតិបុគ្គលមត៌កជាដើម និង ក្រៅពីនេះ ជនដែលអាចធ្វើការដាស់តឿននោះ មានដូចជាជនដែលមានទំនាក់ទំនងនឹងផលប្រយោជន៍។ ដោយសារក្នុងករណីខ្លះ អច្ច័យលាភីពុំបានបង្ហាញថាខ្លួន ធ្វើការបោះបង់ ឬ ទទួលស្គាល់អច្ច័យទានទេ ដែលវាធ្វើឱ្យមានការប៉ះពាល់ដល់ផលប្រយោជន៍ជនដទៃទៀត [44] ហេតុនេះហើយជនដែលបានរៀបរាប់ខាងលើនេះ មានសិទ្ធិធ្វើការដាស់តឿនឱ្យអច្ច័យលាភីទទួលស្គាល់ ឬ បោះបង់អច្ច័យទាន

[44] សមិទ្ធផលរបស់JICA "ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១" ឆ្នាំ ២០១៥ "អច្ច័យទាន", ទំព័រ.៧៩

ដោយកំណត់ពេលសមរម្យ។ ហើយប្រសិនបើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈណាមួយចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទានក្នុងអំឡុងពេលដែលបានកំណត់ក្នុងការដាស់តឿនទេនោះ គឺនឹងត្រូវបានចាត់ទុកថា បានទទួលស្គាល់អច្ច័យទាននោះ។ បន្ថែមពីនេះទៅទៀត សិទ្ធិផ្តល់ឱ្យអច្ច័យលាភីក្នុងករណី**ឧបាទេសកម្ម**លើវត្ថុនានាក៏នឹងត្រូវបានយកមកអនុវត្តផងដែរ នៅពេលដែលមានបញ្ហាកើតឡើងនៃវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទានជាដើម ជាមួយនឹងតតិយជនដទៃទៀត ដូចជាការធ្វើឱ្យខូចខាតនៃវត្ថុដោយតតិយជន នោះអច្ច័យលាភី មានសិទ្ធិក្នុងការទាមទារសំណងពីការខូចខាតនោះដូចដែលមានចែងក្នុងក្រមរដ្ឋប្បវេណី[45] ។

រីឯ**ប្រទានកម្មដោយមូលហេតុមរណភាព**វិញ គឺជាកិច្ចសន្យាដែលធ្វើឡើងដោយមតកជននៅមុនពេលស្លាប់ ដែលវាជាប្រទានកម្មដែលមរណភាពរបស់មតកជនមកធ្វើជាល័ក្ខខ័ណ្ឌក្នុងការបង្កើតអានុភាព ហេតុនេះ ប្រទានកម្មប្រភេទនេះ គឺមានអានុភាពនៅពេលដែលមតកជនបានទទួលមរណភាព។ ប្រទានកម្មដោយមូលហេតុមរណភាព គឺ មានភាពស្រដៀងគ្នាទៅនឹងអច្ច័យទានដែរ ដោយចំណុចនោះគឺការមិនមានការផ្លាស់ប្តូរស្ថានភាពទ្រព្យសម្បត្តិក្នុងអំឡុងពេលដែលមតកជននៅរស់ឡើយ។ ហេតុនេះហើយទើបមានការយកបញ្ញត្តិនៃអច្ច័យទានត្រង់បញ្ញត្តិស្តីពីអានុភាពនៃអច្ច័យទាន ត្រូវបានអនុវត្តដូចគ្នាជាមួយនឹងប្រទានកម្មនេះដែរ។ ថ្វីត្បិតតែប្រទានកម្មនេះមានភាពស្រដៀងគ្នាទៅនឹងអច្ច័យទាន និង បញ្ញត្តិស្តីពីអានុភាពនៃអច្ច័យទានត្រូវបានយកមកអនុវត្តសម្រាប់ប្រទានកម្មនេះក៏ពិតមែន ក៏ប៉ុន្តែដោយប្រទានកម្មដោយមូលហេតុមរណភាព គឺជាកិច្ចសន្យា ដូចនេះការយល់ព្រមទទួលស្គាល់ ឬ ការបោះបង់អច្ច័យទាននានា គឺ មិនអាចយកមកអនុវត្តសម្រាប់ប្រទានកម្មនេះឡើយ[46] ។

### ខ. បញ្ហាមតកសាសន៍ និងប្រទានកម្មដោយមូលហេតុមរណភាពដែលមានខ្លឹមសារផ្ទុយគ្នា

ប្រទានកម្មដោយមូលហេតុមរណភាពនេះ និង មតកសាសន៍នេះអាចនឹងមានបញ្ហានៅពេលដែលមតកសាសន៍ និង ប្រទានកម្មនេះមានភាពផ្ទុយគ្នាជាដើម ដោយសារកាលណាដែលអត្ថន័យនានា ឬ ខ្លឹមសារនៃមតកសាសន៍ប៉ះពាល់ ឬ មានឥទ្ធិពលដល់ប្រទានកម្មដោយមូលហេតុមរណភាពជាដើម ហើយនៅពេលនោះការពិភាក្សាលើបញ្ហាអានុភាពរវាង មតកសាសន៍ និង ប្រទានកម្មដោយមូលហេតុមរណភាពក៏នឹងកើតមានឡើងផងដែរ។ ដូចនេះ ប្រសិនបើមានបញ្ហានេះកើតឡើង នឹងមានចំណោទសួរថា តើគួរតែផ្តល់**អានុភាពដល់មតកសាសន៍លើប្រទានកម្មដោយមូលហេតុមរណភាព ឬ ផ្តល់អានុភាពប្រទានកម្មដោយមូលហេតុមរណភាពលើមតកសាសន៍**។ លើសពីនេះទៅទៀត ដោយសារមិនមានមាត្រាណាមួយនៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា

[45] ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧, មាត្រា ១២០៩

[46] ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧, មាត្រា ៥៧៧

បានកំណត់អំពីការលុបចោលនូវប្រទានកម្មដោយមូលហេតុមរណភាពទេ **តើប្រទានកម្មដោយមូលហេតុមរណភាពអាចធ្វើការលុបចោលបានដែរ** ឬ ទេ ហើយកាលណាមានបញ្ហាជុំវិញនូវការលុបចោលនេះកើតឡើងនឹងត្រូវអនុវត្តយ៉ាងដូចម្តេច?

នៅឯប្រទេសជប៉ុន គេអាចនិយាយបានថាកាលណាដែលមតកសាសន៍ និង ប្រទានកម្មដោយមូលហេតុមរណភាពមានភាពផ្ទុយគ្នា រវាងអានុភាពនៃលិខិតទាំងពីរ គេក៏បានលើកឡើងនូវការពិភាក្សានៃការលុបចោលនៃប្រទានកម្មដោយមូលហេតុមរណភាពផងដែរដោយយោងតាមការសិក្សាពីសាលក្រម សាលដីកានៃប្រទេសជប៉ុន គេបានពិភាក្សានិង ធ្វើការលើកឡើងផ្តោតទៅលើបញ្ហាពាក់ព័ន្ធនឹងការលុបចោលនូវប្រទានកម្មដោយមូលហេតុមរណភាព ដែលការពិភាក្សានោះមានដូចខាងក្រោម[47]៖

យោងតាមក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុនមាត្រា ១០២២ និង ១០២៣ ដែលចែងអំពីការលុបចោលមតកសាសន៍ គឺគេសន្មតថាមាត្រានេះក៏អាចយកមកប្រើប្រាស់សម្រាប់ការលុបចោលនូវប្រទានកម្មដោយមូលហេតុមរណភាពដែរ។ ហេតុនេះការលុបចោលប្រទានកម្មដោយមូលហេតុមរណភាពអាចធ្វើឡើងបានគ្រប់ពេល និង អាចលុបចោលទាំងស្រុង ឬ ដោយផ្នែក ដូចការលុបចោលមតកសាសន៍ដែរ។ ម៉្យាងវិញទៀតដោយសារតែមានការគោរពនូវឆន្ទៈចុងក្រោយរបស់មតកជន ហេតុនេះប្រសិនបើទោះជាប្រទានកម្មដោយមូលហេតុមរណភាព ឬ អច្ច័យទាននានា គឺមតកជនអាចលុបចោល ឬ ចាត់ចែងបាន។

ប៉ុន្តែទោះជាយ៉ាងណាក្តី ក្នុងករណីចំពោះប្រទានកម្មដោយមូលហេតុមរណភាពជាក់លាក់ណាមួយដោយពិចារណាទៅលើចេតនា ឬ គោលបំណង និង ផលប្រយោជន៍នៃអ្នកទទួលប្រទានកម្មនោះវិញ ប្រសិនបើគោរពទៅតាមការយល់ឃើញខាងលើវាហាក់បីដូចជាមិនយុត្តិធម៌សម្រាប់ភាគីអ្នកទទួលប្រទានកម្មនោះ។ ហេតុនេះជាជាងគោរពតាមឆន្ទៈចុងក្រោយរបស់មតកជន គួរតែពិចារណាអំពីកិច្ចសន្យាប្រទានកម្មវិញទើបជាការសាកសម។ ចំពោះការពិចារណា និង ផ្តល់តម្លៃទៅលើកិច្ចសន្យានៃការធ្វើប្រទានកម្មវិញ នោះមតកជននៅមុនពេលទទួលមរណភាពគឺមិនអាចធ្វើការលុបចោលនូវប្រទានកម្មដោយមូលហេតុមរណភាពដោយសេរីបានទេ។ ហេតុនេះតើក្នុងករណីនេះតើកិច្ចសន្យាប្រទានកម្មនេះអាចលុបចោលបាន ឬ យ៉ាងណា (មាត្រា ៥៥០ នៃក្រមរដ្ឋប្បវេណីជប៉ុន ការលុបចោលកិច្ចសន្យាប្រទានកម្ម) គឺត្រូវពិនិត្យមើលលើលក្ខណៈរបស់ប្រទានកម្មនោះ។

ចំពោះប្រទានកម្មដោយមូលហេតុមរណភាពភ្ជាប់បន្ទុកវិញ គឺប្រសិនបើកាលណាដែលបន្ទុកនោះត្រូវបានអនុវត្តសម្រាប់មតកជនតាំងពីមុនពេលដែលខ្លួនទទួលមរណភាព ដោយបានអនុវត្តបន្ទុកទាំងអស់ ឬ មួយ

[47] ស៊ិអូមិ យ៉ូស៊ីអូ *ការពន្យល់លម្អិត ច្បាប់សន្តតិកម្ម* (កូប៊ឹងដូ , បោះពុម្ពឆ្នាំ ២០១៨) ទំព័រ.៤២៥, 潮見佳男『詳解　相続法』（弘文堂、2018 年）

ផ្នែកក្តី ប្រសិនបើពិចារណាដោយគិតពីឆន្ទៈចុងក្រោយរបស់មតកជនជាធំ ហើយលះបង់នូវផលប្រយោជន៍នៃអ្នកដែលត្រូវទទួលប្រទានកម្មវិញនោះ វាហាក់បីដូចជាមិនសមហេតុផល។ ហេតុនេះហើយ ប្រសិនបើគ្មានស្ថានភាព ឬ មូលហេតុចាំបាច់ណាមួយដែលបង្ហាញថាត្រូវតែលុបចោលនូវកិច្ចសន្យាប្រទានកម្មនោះទេ នោះគឺមតកជនមិនអាចធ្វើការលុបចោលនូវប្រទានកម្មដោយមូលហេតុមរណភាពដោយសេរីបានទេ។

ផ្ទុយទៅវិញចំពោះកិច្ចសន្យាប្រទានកម្មប្រភេទនេះដែលគ្មានភ្ជាប់បន្ទុកវិញ គឺត្រូវបានសន្និដ្ឋានថាអាចអនុវត្តតាមមាត្រា ១០២២ និង ៥៥០ នូវការលុបចោលនូវប្រទានកម្មនេះបាន។ ចំណែកឯប្រទានដោយមូលហេតុមរណភាពមានភ្ជាប់បន្ទុកតែបន្ទុកនោះត្រូវអនុវត្តតាមក្រោយ វាអាចនឹងកើតឡើងដែរ ឬ ទេ ហើយប្រសិនបើបញ្ហាកើតឡើងក្នុងករណីនេះវិញ តើនឹងត្រូវពិចារណាបែបណាគឺ មិនមានការលើកឡើងនៅឡើយ។ ក៏ប៉ុន្តែ ដោយសារតែបន្ទុកទាំងនោះមិនទាន់បានអនុវត្តនៅឡើយ នោះប្រសិនបើពិចារណាទៅលើផលប្រយោជន៍របស់អ្នកទទួលប្រទានកម្មវិញ យើងអាចនិយាយបានថាបើទោះបីជាមតកជនបានលុបចោលនូវប្រទានកម្មនេះក៏ដោយ ក៏ហាក់ដូចជាមិនទាន់មាននូវការបាត់បង់ប្រយោជន៍អ្វីដែរ។ ដូចនេះបើក្នុងករណីនេះ ប្រសិនបើយល់ឃើញថាមតកជនអាចធ្វើការលុបចោលបានគ្រប់ពេល តើការសន្និដ្ឋាននេះសាកសមដែរ ឬ យ៉ាងណា។

សរុបមកវិញ យើងអាចសន្និដ្ឋានបានថា កាលណាមានបញ្ហារវាងអានុភាពនៃមតកសាសន៍ និង ប្រទានកម្មដោយមូលហេតុមរណភាពកើតមានឡើង នោះគឺត្រូវពិនិត្យទៅលើផ្នែកការលុបចោលប្រទានកម្មដោយមូលហេតុមរណភាពគឺអាចធ្វើឡើងបានដែរ ឬ ទេ។ ហើយដោយយោងតាមការបកស្រាយខាងលើ គឺបានបង្ហាញថាដោយការគោរពលើឆន្ទៈរបស់មតកជននោះ ការលុបចោលប្រទានកម្មនេះគឺ អាចធ្វើឡើងដោយមតកជនបានគ្រប់ពេលក្នុងកំឡុងពេលដែលខ្លួននៅរស់បាន លើកលែងតែក្នុងករណីដែលប្រទានកម្មដោយមូលហេតុមរណភាពនោះជា ប្រទានកម្មដោយមូលហេតុមរណភាពមានភ្ជាប់បន្ទុក ហើយបន្ទុកនោះនឹងត្រូវបានអនុវត្តមុន ទើបមតកជនមិនអាចលុបចោលប្រទានកម្មនោះបានឡើយ។

### កថាខណ្ឌទី២ បញ្ហានៃការបែងចែកមត៌កខុសពីខ្លឹមសារមតកសាសន៍

មុននឹងធ្វើការបង្ហាញអំពីបញ្ហានៃការបែងចែកមត៌កខុសពីខ្លឹមសារមតកសាសន៍ (ខ. បញ្ហានៃការបែងចែកមត៌កខុសពីខ្លឹមសារមតកសាសន៍) យើងនឹងធ្វើការសិក្សាអំពីមូលដ្ឋាននៃការបែងចែកមត៌ក (ក. មូលដ្ឋាននៃការបែងចែកមត៌ក) ជាមុនសិន។

#### ក. មូលដ្ឋាននៃការបែងចែកមត៌ក

កាលណាដែលជនដែលបានទទួលសន្តតិកម្មជាសហសន្តតិជន ឬ ករណីដែលមានការបោះបង់សន្តតិកម្មនានា ការរក្សាទុក និងគ្រប់គ្រងមត៌កនោះគឺពិតជាមានសារៈសំខាន់ ដោយហេតុនេះនៅក្នុងករណី

ដែលមានសហសន្តតិជន សន្តតិជនដែលកាន់កាប់មត៌កនៅពេលដែលមតកជនទទួលមរណភាព គឺត្រូវរក្សាទុក និងគ្រប់គ្រងមត៌កនោះឱ្យមានស្ថានភាពដដែលរហូតដល់ពេលធ្វើការបែងចែកមត៌ក។ រីឯចំពោះមត៌កដែលមិនត្រូវបានកាន់កាប់ដោយសន្តតិជនណាម្នាក់ទេ នោះនៅពេលដែលមតកជនបានទទួលមរណភាពមត៌កនឹងត្រូវរក្សា និងគ្រប់គ្រងដោយសហសន្តតិជនជាមួយគ្នា។

ផ្ទុយទៅវិញ ប្រសិនបើក្នុងករណីដែលមានមតកសាសន៍ ហើយមតកសាសន៍មានការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍វិញនោះ អ្នកប្រតិបត្តិមតកសាសន៍នោះគឺជាអ្នកដែលមានសិទ្ធិ និង ករណីយកិច្ចក្នុងការគ្រប់គ្រង និង រក្សាមត៌កនោះ (មាត្រា ១២៦២ និង មាត្រា ១២៦៣) [48]។ ដូចនេះឋានៈនៃអ្នកប្រតិបត្តិមតកសាសន៍ គឺត្រូវធ្វើសកម្មភាព នៅក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍ចំពោះមត៌កដែលខ្លួនត្រូវប្រតិបត្តិ ហើយសកម្មភាពដែលអ្នកប្រតិបត្តិមតកសាសន៍បានធ្វើជាមុខនាទី ត្រូវមានអានុភាពផ្ទាល់ ចំពោះសន្តតិជន។ ដោយក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍ គឺមានន័យថានៅពេលដែលមានវត្តមានរបស់អ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនពុំអាចចាត់ចែងមត៌ក ឬ ធ្វើសកម្មភាពណាមួយរារាំងដល់អ្នកប្រតិបត្តិមតកសាសន៍នោះឡើយ។ កាលណាដែលមានការចាត់ចែងណាមួយរារាំងដល់ការប្រតិបត្តិមតកសាសន៍នោះ គឺការចាត់ចែងនោះពុំមានអានុភាពឡើយ។

ចំពោះមូលដ្ឋាននៃការបែងចែកមត៌កវិញ ជាគោលការណ៍ ការបែងចែកមត៌ក គឺត្រូវធ្វើឡើងតាមរយៈការពិភាក្សារវាងសហសន្តតិជន ដោយករណីដែលសន្តតិជនមានច្រើននាក់ នោះមត៌កអាចនឹងត្រូវស្ថិតក្នុងកម្មសិទ្ធិអវិភាគដែរ។ ហេតុនេះដើម្បីធ្វើការបែងចែកមត៌កនេះ គឺចាំបាច់មានការព្រមព្រៀងពីសហសន្តតិជនទាំងអស់។ ប្រសិនបើក្នុងករណីដែលមានអ្នកប្រតិបត្តិមតកសាសន៍ ការពិភាក្សាបែងចែកនេះ ត្រូវតែមិនមានភាពរារាំងដល់អ្នកប្រតិបត្តិមតកសាសន៍ឡើយ។ ប៉ុន្តែក្នុងករណីដែលការពិភាក្សានោះមិនទទួលបាននូវលទ្ធផលល្អទេនោះ តុលាការនឹងធ្វើការបែងចែកមត៌កនោះ[49] ។

នៅពេលពិភាក្សាការបែងចែកមត៌ក សហសន្តតិជនត្រូវគិតពិចារណាលើចំណុចមួយចំនួនដូចជា ប្រភេទ និង លក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលមាននៅក្នុងមត៌ក ឬ អាយុ មុខរបរ ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត ស្ថានភាពជីវភាព របស់សហសន្តតិជននីមួយៗ និង ស្ថានភាពផ្សេងទៀត។ និងប្រសិនបើក្នុងករណីដែលការបែងចែកមត៌កដែលជាវត្ថុកម្មសិទ្ធិអវិភាគ ហើយការបែងចែកនោះអាចបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃនៃវត្ថុនោះ សហសន្តតិជនក៏អាចព្រមព្រៀងគ្នាដោយឱ្យសន្តតិជនណាម្នាក់ទទួលមត៌កនោះតែឯង ហើយ

[48] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ គន្ថីទី៨ ~ទី៩ ឆ្នាំ ២០១០, ទំព័រ.១២៣, ១២៤

[49] ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧, មាត្រា ១២៦៦ ថ្មី និង មាត្រា ១២៧០

ជននោះបង់ប្រាក់សម្រួលទៅឱ្យសហសន្តតិជនផ្សេងទៀតបាន [50] ។ ទោះជាយ៉ាងណាក្តី ក្នុងករណីដែលសហព័ទ្ធជាម្នាក់ក្នុងចំណោមសហសន្តតិជននោះដែរ ហើយបើមានទ្រព្យសម្បត្តិដែលទទួលបានជាកម្មសិទ្ធិអវិភាគជាមួយនឹងមតកជន ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ នៅក្នុងការបែងចែកមត៌ក សហព័ទ្ធនេះមានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគដែលទាក់ទងនឹងទ្រព្យសម្បត្តិនោះ រហូតដល់គ្រប់ចំនួននូវចំណែកមត៌ករបស់ខ្លួន [51] ។

**ខ. បញ្ហានៃការបែងចែកខុសពីខ្លឹមសារមតកសាសន៍**

ជាធម្មតា នៅពេលដែលសន្តតិកម្មចាប់ផ្តើម ដើម្បីឱ្យការកំណត់នៅក្នុងមតកសាសន៍របស់មតកជនអាចសម្រេចបានដោយរលូន នោះវត្តមានរបស់អ្នកប្រតិបត្តិមតកសាសន៍នឹងកាន់តែមានសារៈសំខាន់ខ្លាំងឡើង ពីព្រោះដូចដែលបានបង្ហាញរួចមកហើយ ថាអ្នកប្រតិបត្តិមតកសាសន៍គឺជាអ្នកដែលគ្រប់គ្រងមត៌ក និងធ្វើសកម្មភាពចាំបាច់ដើម្បីប្រតិបត្តិមតកសាសន៍នោះ។

ក៏ប៉ុន្តែ ទោះបីជាដូចបានរៀបរាប់ខាងលើនេះក្តី បញ្ហាដែលទាក់ទងនឹងការប្រតិបត្តិមតកសាសន៍នេះ គឺក៏នៅតែកើតមាន។ បញ្ហានោះគឺ នៅក្នុងករណីដែលសហសន្តតិជន និង អច្ច័យលាភីទាំងអស់បានព្រមព្រៀងគ្នាធ្វើការបែងចែកនូវទ្រព្យសម្បត្តិនោះ ដោយមិនអនុលោមតាមការកំណត់នៅក្នុងមតកសាសន៍ឡើយ ក៏ប៉ុន្តែអ្នកប្រតិបត្តិមតកសាសន៍នោះមិនយល់ស្របតាមការព្រមព្រៀងរបស់សហសន្តតិជននិងអច្ច័យលាភីទាំងអស់នោះទេ ដូច្នេះ បញ្ហាគឺ នៅក្នុងស្ថានភាពបែបនេះ តើត្រូវពិចារណាយ៉ាងដូចម្តេចដែរ។

ពាក់ព័ន្ធនឹងចំណុចខាងលើនេះ ដោយសារតែការនៅក្នុងប្រទេសកម្ពុជាពុំមានការពិភាក្សាណាមួយដែលត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងចំណុចនេះឡើយ ហេតុដូច្នេះ ការពិភាក្សានៅឯប្រទេសជប៉ុននឹងត្រូវយកមកបង្ហាញដូចខាងក្រោម។

ក្នុងការវិនិច្ឆ័យដោយអ្នកច្បាប់នៅប្រទេសជប៉ុនអំពីករណីនៃបញ្ហាខាងលើនេះ ឃើញថា មានគំនិតយល់ឃើញពីរដែលផ្ទុយគ្នា[52]។ ក្នុងនោះ គំនិតទី១ បានលើកឡើងថា " ការបែងចែកមត៌កដែលខុសពីខ្លឹមសារនៃមតកសាសន៍ ដោយពុំមានការយល់ព្រមពីអ្នកប្រតិបត្តិមតកសាសន៍នោះ គឺមោឃៈ" ដោយហេតុថា អ្នកប្រតិបត្តិមតកសាសន៍ត្រូវតែខិតខំបំពេញមុខងាររបស់ខ្លួនដើម្បីសម្រេចឱ្យបានលទ្ធផលនូវខ្លឹមសារដែលត្រូវ

---

[50] ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧, មាត្រា ១២៦៧

[51] ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧មាត្រា ១២៦៨

[52] ម៉ូឈិខាវ៉ាក់ ម៉ាសាអុ *ការស្រាវជ្រាវពាក់ព័ន្ធនឹងបញ្ហាមួយចំនួននៃមតកសាសន៍ដោយលិខិតឯកជននៅក្នុងច្បាប់សន្តតិកម្មជប៉ុន* ទំព័រ. ៤១,៤២។ 餅川正雄「日本の相続法における自筆証書遺言の諸問題に関する研究」41－42 頁。（http://harp.lib.hiroshima-u.ac.jp/hue/detail/1245020200407161020）

បានកំណត់នៅក្នុងមតកសាសន៍របស់មតកជន ហើយនៅពេលណាដែលមានឧបសគ្គរាំងនូវការសម្រេចឱ្យបានជាលទ្ធផលនូវខ្លឹមសាររបស់មតកសាសន៍នេះ អ្នកប្រតិបត្តិមតកសាសន៍នោះមានតួនាទីត្រូវកំចាត់នូវឧបសគ្គដែលរារាំងកិច្ចការនេះចោល។

ចំណែកឯ គំនិតទី ២ វិញ បានចាត់ទុកថា នោះគឺជាការធ្វើបែបនោះគឺជាការដែលសហសន្តិជន និងអច្ច័យលាភីទាំងអស់បានព្រមព្រៀងគ្នាធ្វើការផ្លាស់ប្តូរនូវសិទ្ធិដែលពួកគេទទួលបានតាមរយៈមតកសាសន៍តាមក្រោយ ដូច្នេះ ទោះបីជាមិនមានការយល់ព្រមពីអ្នកប្រតិបត្តិមតកសាសន៍ក៏ដោយ ក៏ការបែងចែងទ្រព្យសម្បត្តិដែលខុសពីខ្លឹមសារនៃមតកសាសន៍របស់មតកជននោះ មានសុពលភាពដែរ។

ក្នុងចំណោមគំនិតទាំងពីរដែលបានរៀបរាប់ខាងលើនេះ ឃើញថា គំនិតទី១ មានភាពសមហេតុផលជាង ដោយហេតុថា វាបានធ្វើឱ្យឆន្ទៈចុងក្រោយរបស់មតកជនត្រូវបានបំពេញ ដែលវាជាការត្រឹមត្រូវបំផុត ពីព្រោះថា គោលគំនិតនៃការធ្វើមតកសាសន៍គឺ ដើម្បីឱ្យមតកជនបានបង្ហាញឆន្ទៈចុងក្រោយរបស់ខ្លួនក្នុងការចាត់ចែងទ្រព្យសម្បត្តិដែលខ្លួនជាម្ចាស់ ហើយខ្លួនបានរំពឹងកាលដែលនៅរស់ថាការកំណត់របស់ខ្លួននៅក្នុងមតកសាសន៍ប្រាកដជានឹងបានសម្រេច។ ចំណែកឯការដែលសហសន្តតិជន និងអច្ច័យលាភី មានបំណងចង់ផ្លាស់ប្តូរសិទ្ធិដែលទទួលបាននោះយ៉ាងណានោះ គួរតែធ្វើវាបន្ទាប់ពីធ្វើការបែងចែកតាមរយៈមតកសាសន៍រួចរាល់សិន។ បើពុំដូច្នេះទេ វាហាក់បីដូចជាការខិតខំប្រឹងប្រែងធ្វើមតកសាសន៍ដើម្បីបន្សល់ទុកនេះ គ្មានន័យអ្វីសោះឡើយ។

ជាទូទៅតម្លៃនៃកម្មវត្ថុសន្តតិកម្ម គឺត្រូវបានបម្លែងជាប្រាក់តាមការសន្មត សម្រាប់ភាពងាយស្រួលក្នុងការបែងចែកមត៌ក ហេតុនេះ ជាទូទៅតុលាការកំណត់ថាតម្លៃកម្មវត្ថុនោះនៅពេលដែលសន្តតិកម្មបានចាប់ផ្តើម។ ចំពោះការវាយតម្លៃនៃទ្រព្យនីមួយៗ គឺធ្វើឡើងដោយមានការព្រមព្រៀងរបស់សន្តតិជន បើមិនមានការឯកភាពគ្នាទេ ភាគីអាចដាក់ពាក្យសុំទៅតុលាការ ហើយតុលាការនឹងធ្វើការជ្រើសរើសអ្នកជំនាញក្នុងការវាយតម្លៃ ដោយការវាយតម្លៃនេះ គឺតាមរយៈការស្ទាបស្ទង់អំពីតម្លៃទីផ្សារ ដោយប្រមូលតម្លៃប៉ាន់ស្មានពីអ្នកជំនាញនៃប្រភេទទ្រព្យទាំងនោះ[53]។

[53] JICA, មេធាវី អ៊ីវ ប៉ូលី "ការបែងចែកមត៌ក" ១៥ មករា ២០១៨, ទំព័រ.២១

# សេចក្តីសន្និដ្ឋាន

ដូចដែលបានធ្វើការបកស្រាយនៅក្នុងផ្នែកសេចក្តីផ្តើម ដោយសារការសិក្សាពីវិធានគតិយុត្តនៃក្រមរដ្ឋប្បវេណីរបស់កម្ពុជា និង បរិបទសង្គមនាពេលបច្ចុប្បន្នទាក់ទងនឹងសន្តតិកម្មតាមមតកសាសន៍នៅមានកម្រិត និង មិនទាន់មានភាពសម្បូរបែបនៅឡើយ ដែលវាពិតជាមានភាពចាំបាច់ណាស់សម្រាប់ការសិក្សាស្រាវជ្រាវលើប្រធានបទពាក់ព័ន្ធនឹងសន្តតិកម្មតាមមតកសាសន៍ ហេតុនេះហើយទើបយើងខ្ញុំលើកយកប្រធានបទនេះឡើង។

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និង បកស្រាយនូវប្រធានបទ "ការពិចារណាលើបញ្ហាសន្តតិកម្មតាមមតកសាសន៍នៅកម្ពុជា" នេះរួច ឃើញថាចំណុចដែលគួរឱ្យកត់សម្គាល់នោះគឺ ទោះបីជាក្រមរដ្ឋប្បវេណីរបស់កម្ពុជាត្រូវបានតាក់តែងឡើងដោយមិនយកលំនាំតាមក្រមរដ្ឋប្បវេណីជប៉ុនទាំងស្រុងក៏ពិតមែន ក៏ប៉ុន្តែទាក់ទងនឹងសន្តតិកម្មតាមមតកសាសន៍នេះ មានបទប្បញ្ញត្តិដែលមានលក្ខណៈស្រដៀងនឹងបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនមួយចំនួនដែរ ដែលវាអាចជាគម្រូយ និងជាប្រយោជន៍សម្រាប់អ្នកច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយកធ្វើជាគំរូឬធ្វើការយោងទៅលើបទប្បញ្ញត្តិទាំងនោះ។

ម៉្យាងវិញទៀត តាមការបកស្រាយ ឃើញថាសន្តតិកម្មតាមមតកសាសន៍នៅក្នុងប្រទេសកម្ពុជាមានបញ្ហានៅក្នុង ២ ទិដ្ឋភាពសំខាន់ៗគឺ បញ្ហានៅក្នុងទិដ្ឋភាពនៃការបង្កើតមតកសាសន៍ និង បញ្ហានៅក្នុងទិដ្ឋភាពនៃការប្រតិបត្តិមតកសាសន៍។ ក្នុងនោះ នៅក្នុងទិដ្ឋភាពទី១ ដែលជាទិដ្ឋភាពនៃការបង្កើតមតកសាសន៍ មានបញ្ហាចំនួន ៦ ត្រូវបានលើកឡើង។ ចំណែកឯនៅក្នុងទិដ្ឋភាពនៃការប្រតិបត្តិមតកសាសន៍វិញ មានបញ្ហាចំនួន ៣ ត្រូវបានលើកឡើង។

ទន្ទឹមនឹងការលើកយកនូវបញ្ហាទាំងអស់ខាងលើនេះ ការយល់ឃើញរបស់អ្នកច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងប្រទេសជប៉ុនក៏ត្រូវបានលើកយកមកបង្ហាញផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ បន្ទាប់ពីស្រាវជ្រាវ និងបង្ហាញនូវទស្សនៈការយល់ឃើញទាំងនោះរួចមក យើងខ្ញុំជាស្មេរ និងជាអ្នកសិក្សាក៏បានបញ្ចេញទស្សនៈរបស់ខ្លួនផងដែរចំពោះបញ្ហាទាំងនោះ។

សរុបសេចក្តីមក ការសិក្សាពីរបបសន្តតិកម្ម ជាពិសេសសន្តតិកម្មតាមមតកសាសន៍ពិតជាមានសារៈសំខាន់ណាស់ ព្រោះវាមិនត្រឹមតែអាចជួយកាត់បន្ថយនូវជម្លោះដែលអាចកើតមានឡើងនៃការបែងចែកមត៌ករវាងសន្តតិជននោះទេ ប៉ុន្តែវាក៏ជាមធ្យោបាយមួយចូលរួមចំណែកក្នុងការជម្រុញឱ្យការយកចិត្តទុកដាក់ និងការយល់ដឹងបន្ថែមពីបញ្ហានេះឱ្យកាន់តែរីកចម្រើនទៅផងដែរ។

# អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាពីទ្រឹស្តី ក៏ដូចជាធ្វើការសិក្សាស្រាវជ្រាវ និងធ្វើការពិចារណាអំពីបញ្ហាច្បាប់ដែលកើតមានទាក់ទងនឹងសន្តតិកម្មតាមមតកសាសន៍នៅក្នុងនីតិរបស់កម្ពុជា នៅក្នុងអត្ថបទសារណានេះរួចមក ឃើញថា បទប្បញ្ញត្តិដែលបញ្ញត្តអំពីសន្តតិកម្មតាមមតកសាសន៍នេះ មានចំណុចល្អ ក៏ដូចជាចំណុចខ្វះខាតដែលត្រូវកែលម្អផងដែរ។

ចំពោះចំណុចល្អដែលបទប្បញ្ញត្តិអំពីសន្តតិកម្មតាមមតកសាសន៍នៅក្នុងក្រមនីតិរដ្ឋប្បវេណីកម្ពុជា មានលក្ខណៈទំនើប ជឿនលឿន ដែលវាបានឆ្លុះបង្ហាញឱ្យឃើញបានតាមរយៈការដែលបទប្បញ្ញត្តិភាគច្រើនមានលក្ខណៈស្រដៀងទៅនឹងបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន ពីព្រោះក្រមរដ្ឋប្បវេណីកម្ពុជាត្រូវបានតាក់តែងឡើងដោយទទួលបាននូវជំនួយខាងផ្នែកគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការពីប្រទេសជប៉ុន។ លើសពីនេះទៅទៀត ថ្វីត្បិតតែ ក្រមរដ្ឋប្បវេណីទទួលបានជំនួយខាងផ្នែកបច្ចេកទេសពីបរទេសក៏ពិតមែន ក៏ប៉ុន្តែ បទប្បញ្ញត្តិទាំងនោះសុទ្ធតែត្រូវបានតាក់តែងឡើងដោយនីតិនិពន្ធបានធ្វើការពិចារណាទៅលើបទប្បញ្ញត្តិទាំងឡាយនៃក្រមរដ្ឋប្បវេណីចាស់ឆ្នាំ ១៩៦៧ របស់កម្ពុជាផងដែរ ដែលជាហេតុធ្វើឱ្យក្រមរដ្ឋប្បវេណីកម្ពុជា គឺជាក្រមច្បាប់ដែលសក្តិសមនឹងជីវភាពសង្គម និងវប្បធម៌ខ្មែរ ដែលជាលក្ខណៈពិសេសសម្រាប់បង្ហាញថាវាជាក្រមរដ្ឋប្បវេណីកម្ពុជា។

ចំណែកឯចំណុចខ្វះខាតនៃបទប្បញ្ញត្តិអំពីសន្តតិកម្មតាមមតកសាសន៍នៃក្រមរដ្ឋប្បវេណីកម្ពុជាវិញគឺ បទប្បញ្ញត្តិមួយចំនួនមានលក្ខណៈមិនច្បាស់លាស់ ទូទៅពេក និងចំណុចខ្លះទៀតមិនមានបញ្ញត្តិគ្រប់គ្រាន់នោះទេ ដែលធ្វើឱ្យពិបាកក្នុងការស្វែងយល់ ការអនុវត្ត និងការបកស្រាយផងដែរ។ លើសពីនេះទៅទៀត ដោយសារតែភាពមិនច្បាស់លាស់នេះហើយ ទើបធ្វើឱ្យកើតមានបញ្ហាមួយចំនួនពាក់ព័ន្ធនឹងសន្តតិកម្មតាមមតកសាសន៍ ដូចដែលបានលើកយកមកបង្ហាញ និងធ្វើការពិចារណានៅក្នុងអត្ថបទសារណានេះ ដែលនឹងត្រូវបានយកមកសង្ខេបដូចខាងក្រោម។

ចំពោះបញ្ហាទី១ គឺបញ្ហាអំពីការពិនិត្យទៅលើអត្ថិភាព និងនត្ថិភាពនៃសមត្ថភាពខាងឆន្ទៈរបស់មតកជនដែលត្រូវពិចារណាទៅលើធាតុសំខាន់ៗ៣ គឺ ទិដ្ឋភាពវេជ្ជសាស្ត្រខាងផ្នែកសតិ ភាពស្មុគស្មាញនៃខ្លឹមសារមតកសាសន៍ និងទំនាក់ទំនងរវាងមតកជន និងសន្តតិជន អច្ច័យលាភីជាដើម។

ចំពោះបញ្ហាទី ២ គឺ បញ្ហាអំពីស្តង់ដារនៃការវិនិច្ឆ័យគុណភាពនៃឆន្ទៈ និងសណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អ ។ ពោលគឺពាក់ព័ន្ធនឹងការបង្ហាញឆន្ទៈដោយការធ្វើអច្ច័យទានឱ្យទៅអច្ច័យលាភីដែលជាជនមានទំនាក់ទំនងក្រៅអាពាហ៍ពិពាហ៍ជាមួយមតកជននៅពេលរស់នោះ ដោយធ្វើការពិចារណាលើ ២ ចំណុច

សំខាន់ៗគឺ គោលបំណងនៃអច្ច័យទាន និង ឥទ្ធិពលនៃអច្ច័យទាននោះដើម្បីសម្រេចពីមោឃភាពនៃអច្ច័យទាននោះ។

ចំពោះបញ្ហាទី ៣ គឺ គឺជាបញ្ហាដែលពាក់ព័ន្ធនឹងសុពលភាពនៃខ្លឹមសារនៃមតកសាសន៍ដែលគ្មានកាលបរិច្ឆេទនៃមតកសាសន៍មានពីរចំណុច។ ការបកស្រាយថា "ខ្លឹមសារនៃមតកសាសន៍ទាំងមូលមិនត្រូវបានចាត់ទុកថាជាមោឃៈនោះទេ នៅពេលដែលមតកសាសន៍ពីរ ដែលមានកាលបរិច្ឆេទនោះផ្ទុយគ្នាដោយផ្នែក" អំពីចំណុចទី ១ នៃ បញ្ហានេះ និង ការបកស្រាយថា "មតកសាសន៍ទាំងពីរនេះមិនផ្ទុយគ្នាទេ នៅពេលមតកសាសន៍មិនមានកាលបរិច្ឆេទចាត់ចែងទ្រព្យសម្បត្តិ ប៉ុន្តែមតកសាសន៍ដែលមានកាលបរិច្ឆេទស្ងៀមស្ងាត់" អំពីចំណុចទី ២ នៃបញ្ហាទី៣ ខាងលើនេះ គឺជាការសមហេតុផលជាងគេ។

ចំពោះបញ្ហាទី៤ គឺបញ្ហាទាក់ទងនឹងការអនុវត្តជាក់ស្តែង ដែលនៅក្នុងនោះ ការធ្វើមតកសាសន៍ត្រូវតែគោរពតាមល័ក្ខខ័ណ្ឌសុពលភាពនៃមតកសាសន៍ បើពុំដូច្នោះទេ នឹងគ្មានសុពលភាពទេ ទោះបីជាមេឃុំជាអ្នកបោះត្រា ឬ មេធាវីជាអ្នករៀបចំក៏ដោយ។

ចំពោះបញ្ហាទី៥ គឺ បញ្ហាវិសាលភាពនៃអច្ច័យលាភី គឺ នីតិបុគ្គលក៏ត្រូវបានទទួលស្គាល់ថាជាប្រធាននៃសិទ្ធិ និងករណីយកិច្ច ហើយដោយឈរលើគោលការណ៍ "ភាពដាច់ខាតនៃកម្មសិទ្ធិឯកជន" ដែលកម្មសិទ្ធិករអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យរបស់ខ្លួនបានដោយសេរី និងការបញ្ញត្តដោយច្បាប់ពិសេស ព្រមទាំងធ្វើការសិក្សាពីប្រព័ន្ធច្បាប់នៃប្រទេសជប៉ុន ដែលបានអនុញ្ញាតដល់នីតិបុគ្គលអាចទទួលអច្ច័យទាននេះផងដែរនោះ ឃើញថា ក្រមរដ្ឋប្បវេណីខ្មែរក៏ពុំមានហេតុផលមិនណាមួយដែលមិនអាចទទួលស្គាល់ នីតិបុគ្គលឱ្យទទួលអច្ច័យទានបាននោះដែរ។

ចំពោះបញ្ហាទី៦ គឺបញ្ហានៃភាពមិនច្បាស់លាស់នៃខ្លឹមសារមតកសាសន៍។ កាលដែលមានបញ្ហានេះកើតមានឡើង នោះវានឹងធ្វើឱ្យមានការលំបាកក្នុងការបកស្រាយនូវខ្លឹមសារទាំងនោះ ដោយយោងទៅលើគោលការណ៍ការគោរពឆន្ទៈចុងក្រោយរបស់មតកជននោះគឺ ចៀសវាងក្នុងការបកស្រាយឱ្យមតកសាសន៍ត្រូវបាត់បង់អានុភាពតាមដែលអាចធ្វើបាន។

ចំពោះបញ្ហាទី៧ គឺបញ្ហានៃការបញ្ជាក់ពីអត្ថិភាពនៃមតកសាសន៍ចុងក្រោយ។ កាលដែលមានបញ្ហានេះកើតឡើង គឺ មានការប្រើប្រាស់ប្រព័ន្ធ ២ ដែលប្រព័ន្ធនោះគឺសម្រាប់ត្រួតពិនិត្យ ក៏ដូចជាស្រាវជ្រាវក្នុងការរកឱ្យឃើញថាកាលមតកជននៅរស់ បានបន្សល់នូវមតកសាសន៍ដែរ ឬ ទេ។ តាមរយៈការប្រើប្រាស់ប្រព័ន្ធទាំង ២ នេះក្រៅពីការស្រាវជ្រាវនេះ គេក៏អាចដឹងដែរថាតើមតកសាសន៍នោះជាលិខិតចុងក្រោយដែរ ឬ យ៉ាងណា។ ដោយប្រព័ន្ធទាំង ២ នោះ គឺប្រព័ន្ធស្វែងរកមតកសាសន៍ ដែលត្រូវបានប្រើប្រាស់សម្រាប់មតកសាសន៍ជាលិខិត

យថាភូត និង ប្រព័ន្ធរក្សាទុក ឬ តម្កល់មតកសាសន៍ ដែលត្រូវបានប្រើប្រាស់សម្រាប់មតកសាសន៍ជាលិខិតឯកជន។

ចំពោះបញ្ហាទី៨ គឺបញ្ហាមតកសាសន៍ និង ប្រទានកម្មដោយមូលហេតុមរណភាពដែលមានខ្លឹមសារផ្ទុយគ្នា។ ដើម្បីអាចដោះស្រាយបញ្ហានេះគឺមានការពិភាក្សាលើការលុបចោលនៃប្រទានកម្មដោយមូលហេតុមរណភាពថាតើមតកជនអាចលុបចោលប្រទានកម្មនេះបាន ឬ ទេ។ ជាចុងក្រោយគឺការលុបចោលប្រទានកម្មប្រភេទនេះគឺ អាចធ្វើឡើងដោយមតកជនបានគ្រប់ពេលក្នុងកំឡុងពេលដែលខ្លួននៅរស់នៅឡើយ លើកលែងតែក្នុងករណីដែលប្រទានកម្មដោយមូលហេតុមរណភាពនោះជា ប្រទានកម្មដោយមូលហេតុមរណភាពមានភ្ជាប់បន្ទុក ហើយបន្ទុកនោះត្រូវអនុវត្តមុន ទើបមតកជនមិនអាចលុបចោលប្រទានកម្មនោះបានឡើយ។

ជាចុងក្រោយបញ្ហាទី៩ គឺជាបញ្ហានៃការបែងចែកមត៌កខុសពីខ្លឹមសារមតកសាសន៍។ ក្នុងការវិនិច្ឆ័យដោយអ្នកច្បាប់នៅប្រទេសជប៉ុនអំពីករណីនៃបញ្ហាខាងលើនេះ មានគំនិតយល់ឃើញពីរដែលផ្ទុយគ្នា។ ក៏ប៉ុន្តែក្នុងចំណោមគំនិតទាំងពីរនោះស្មេរយល់ឃើញថា គំនិតទី១ មានភាពសមហេតុផលជាង។ គំនិតនេះលើកឡើងថា ការបែងចែក មត៌កដែលខុសពីខ្លឹមសារមតកសាសន៍ដោយពុំមានការយល់ព្រមពីអ្នកប្រតិបត្តិមតកសាសន៍គឺ ត្រូវចាត់ទុកជាមោឃៈ។ វាសមហេតុផលជាងគំនិតមួយទៀត ដោយហេតុថា វាបានធ្វើឱ្យឆន្ទៈចុងក្រោយរបស់មតកជនត្រូវបានបំពេញ ដែលវាជាការត្រឹមត្រូវបំផុតពីព្រោះថា គោលគំនិតនៃការធ្វើមតកសាសន៍គឺ ដើម្បីឱ្យមតកជនបានបង្ហាញឆន្ទៈចុងក្រោយរបស់ខ្លួនក្នុងការចាត់ចែងទ្រព្យសម្បត្តិដែលខ្លួនជាម្ចាស់ ហើយខ្លួនបានរំពឹងកាលដែលនៅរស់ថាការកំណត់របស់ខ្លួននៅក្នុងមតកសាសន៍ប្រាកដជានឹងបានសម្រេច។ ចំណែកការដែលសហសន្តតិជន និងអច្ច័យលាភី មានបំណងចង់ផ្លាស់ប្តូរសិទ្ធិដែលទទួលបាននោះយ៉ាងណានោះ គួរតែធ្វើវាបន្ទាប់ពីធ្វើការបែងចែកតាមរយៈមតកសាសន៍រួចរាល់សិន។ បើពុំដូច្នេះទេ វាហាក់បីដូចជាការខិតខំប្រឹងប្រែងធ្វើមតកសាសន៍ដើម្បីបន្សល់ទុកនេះ គ្មានន័យអ្វីសោះឡើយ។

# ឯកសារពិគ្រោះ

- **ឯកសារយោងជាភាសាខ្មែរ**
  - ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧
  - សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ២៖ គន្លីទី ៤
  - សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦៖ គន្លីទី ៨-៩
  - សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ៦ ឆ្នាំ២០១២
  - ច្បាប់ស្តីពីការប្រើប្រាស់ ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ
  - សមិទ្ធផលរបស់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ "ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី មេរៀន ភាគ១" បោះពុម្ពលើកទី១ ខែធ្នូ ឆ្នាំ២០១៥
  - សមិទ្ធផលរបស់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ "ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី មេរៀន ភាគ៣" បោះពុម្ពលើកទី១ ខែធ្នូ ឆ្នាំ២០១៥
  - JICA "ក្រមរដ្ឋប្បវេណី ភាគ៦" ឆ្នាំ ២០១២
  - សន្ទានុក្រមពាក្យថ្មីរៀបរៀងដោយលោក ទូច គីមស្រ៊ាង សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ ឆ្នាំ ២០១៤
- **ឯកសារយោងជាភាសាជប៉ុន**
  - ក្រមរដ្ឋប្បវេណីជប៉ុន
  - ណូមឺរ៉ា តូយ៉ូហ៊ីរ៉ូ *សេចក្តីផ្តើមនីតិរដ្ឋប្បវេណី* (យូហ៊ិកាគុអារឹម៉ា, បោះពុម្ពលើកទី៨, ឆ្នាំ២០១៩)
    野村豊弘『民事法入門』（有斐閣アルマ、第 8 版、2019 年）
  - ស៊ីអូមិ យ៉ូស៊ីអូ *ការពន្យល់លម្អិត ច្បាប់សន្តតិកម្ម* (កូប៊ឹងដូ , បោះពុម្ពឆ្នាំ ២០១៨)
    潮見佳男『詳解　相続法』（弘文堂、2018 年）
  - អូមឺរ៉ា អាត់ស៊ូស៊ី *មូលដ្ឋាននីតិរដ្ឋប្បវេណី・គន្លឹសន្តតិកម្ម* (យូហ៊ិកាគុ, ឆ្នាំ២០១៧)
    大村敦志『基本民法・相続編』（有斐閣、2017 年）
  - ម៉ូឈិខាវ៉ាក់ ម៉ាសាអុ *ការស្រាវជ្រាវពាក់ព័ន្ធនឹងបញ្ហាមួយចំនួននៃមតកសាសន៍ដោយលិខិតឯកជននៅក្នុងច្បាប់សន្តតិកម្មជប៉ុន* ទំព័រ. ៤១,៤២។ 餅川正雄「日本の相続法における自筆証書遺言の諸問題に関する研究」41－42 頁。（http://harp.lib.hiroshima-u.ac.jp/hue/detail/12450202004071610 20）

- **គេហទំព័រ និង តំណភ្ជាប់**
  - https://www.korei-support.net/article/igon-nouryoku
  - http://www.ppnp.com.kh/wpcontent/uploads/2016/09/PPNP_Newsletter_September-2016_Will-and-the-importance-of-the-authenticated-act%E2%80%8B.pdf
  - https://www.jica.go.jp/project/english/cambodia/025/materials/c8h0vm0000c54sbn-att/code_04_04.pdf
  - https://www.jica.go.jp/project/english/cambodia/025/materials/c8h0vm0000c54sbn-att/code_08_02.pdf
  - https://www.asahi.com/ads/sozoku_vs/column/will/04/
  - https://www.souzoku-mado.jp/27.11.5
  - https://souzoku.asahi.com/article/14108467
  - https://www.i-sozoku.com/navi/00109/
  - https://koshigaya-souzoku.info/1848.html
  - https://gentosha-go.com/articles/-/31560
  - https://www.sapporo-yuigon.jp/15052140701090
  - http://orangelaw.jp/pdf/benkyokai/2018/08/180629_benkyokai.pdf
  - https://www.facebook.com/socialandlaw/posts/1911916925620279/
  - https://www.jstage.jst.go.jp/article/takahogaku/38/0/38_185/_pdf/-char/ja
  - https://green-osaka.com/online/effectiveness-of-will
  - https://www.cgu.ac.jp/albums/abm.php?f=abm00000140.pdf&n=%E3%80%8C相続させる%E3%80%8D遺言について.pdf
  - https://vs-group.jp/sozokuzei/supportcenter/oshiete/27/

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ១៦៧
ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០០២

<u>សាលដីកា</u>
លេខៈ ២៧៩
ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០០៣

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៣ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម .......... ជាប្រធាន
២-លោក .......... ជាចៅក្រម
៣-លោក .............. ជាចៅក្រម
៤-លោក .............. ជាចៅក្រម
៥-លោក .............. ជាចៅក្រម

<u>ក្រឡាបញ្ជី</u>
-លោក ....................

<u>តំណាងមហាអយ្យការ</u>
-លោក ............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ៧៧ (ឃ) ចុះថ្ងៃទី២៦ ខែវិច្ឆកា ឆ្នាំ២០០១ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៤៩ ចុះថ្ងៃទី០៩ខែឧសភា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ៈ

-រវាងដើមចោទឈ្មោះ១- ថជ(ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៦៨ឆ្នាំ ជាតិខ្មែរ

២- ថធ(ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ របរកស៊ីធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិព្រៃចក ឃុំគោគគង់ខាងលិច ស្រុកកញ្ជ្រោច ខេត្តព្រៃវែង ។ (ផ្ទេរសិទ្ធិឱ្យថ ជ )។

-និងចុងចម្លើយឈ្មោះ ថធ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៧ឆ្នាំ ជាតិខ្មែរ របរកស៊ីលក់ដូរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៦២Eoz ផ្លូវ១៥៤ ក្រុមទី២៤ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌ ដូនពេញ ក្រុងភ្នំពេញ ។

- មេធាវីលោក កចរ

<u>*កម្មវត្ថុបណ្តឹង*</u> ប្តឹងទាមទារដីកេរ្តិ៍មរតក

បានឃើញបណ្តឹងសាទុក្ខលេខ ២២ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០២ របស់ឈ្មោះ ថធ ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៧៧"ឃ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៦៧ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០២ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៦ខែតុលា ឆ្នាំ២០០០ របស់ដើមចោទបានប្តឹងទាមទារចែកដីមួយ កន្លែង និង ដីស្រែស្ថិតនៅភូមិព្រៃចក ឃុំគោគគង់ខាងលិច ស្រុកកញ្ជោច ខេត្តព្រៃវែង ជាទ្រព្យ របស់ម្តាយឈ្មោះ ខ ណ ដែលបានបន្សល់ទុកដីពីរកន្លែងនេះ ក្រោយពីគាត់ស្លាប់ទៅ ពុំទាន់បាន ចែក ឬលក់ឱ្យទៅកូនណាទេ ដោយសុំចែកជា៦ចំណែកស្មើគ្នា ដោយមានឈ្មោះថជមួយចំណែក ដែរ ។ កន្លងមកឈ្មោះថជ មិនព្រមចែក គឺរំលោភយកតែម្នាក់ឯង ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១២ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ របស់តុលាការ ខេត្តព្រៃវែងដែលមានខ្លឹមសារនៃសេចក្តីសម្រេច ដូចតទៅៈ

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះថង ជ ឈ្មោះថ ដ ឈ្មោះថ ណ និង ឈ្មោះ ថ គ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០០ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិ ច្បាប់ លើកលែងតែការប្តឹងរបស់ឈ្មោះថ ផ ត្រូវបដិសេធចោលជាអសារបង់តាមមាត្រា១៧២ នៃច្បាប់ភូមិបាលដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១០០ក្រ ចុះថ្ងៃទី១៣ខែតុលា ឆ្នាំ១៩៩២។

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០០របស់ដើមចោទឈ្មោះ ថ ណ និងឈ្មោះ ថ គ ឲ្យទៅឈ្មោះ ថ ជ និង ឈ្មោះថ ដ តែបដិសេធមិនទទួល ស្គាល់ការប្រគល់សិទ្ធិរបស់ឈ្មោះថ ផ ។

៣-បដិសេធលិខិតពាក្យបណ្តឹមតេក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៦ ចោលជាអសារបង់ចាប់ពីពេលនេះទៅ

៤-ទទួលស្គាល់តាមច្បាប់ដីភូមិចាស់តាមគំនូសប្លង់ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០០និងដីផលិតកម្មកសិកម្មតាមគំនូសប្លង់ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០០ តាមលិខិតសំណើលេខ ១២៧-២០០០ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០០ ជាទ្រព្យរបស់ខ្មោចលោកយាយ ខ ណ ចាប់ពីពេលនេះទៅ ។

៥-បដិសេធពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩០ដូចគ្នា ចំនួន២ច្បាប់ របស់ចុងចម្លើយ ឈ្មោះដ ធ ចោលជាអសារបង់ចាប់ពីពេលនេះតទៅ ។

៦-បង្គាប់ឲ្យបែងចែកទ្រព្យរបស់ខ្មោច ខ ណ មានដីភូមិចាស់តាមទំហំនៅក្នុងគំនូសប្លង់ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០០ និងដីផលិតកម្មកសិកម្មតាមទំហំនៅក្នុងគំនូសប្លង់ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០០ទៅអោយឈ្មោះ ថ ជ ឈ្មោះថ ដ ឈ្មោះថ គ ឈ្មោះថ ណ និង ឈ្មោះថជ ជា៥ចំណែកស្មើគ្នានៅពេលសាលក្រមចូលជាស្ថាពរ ។

៧-បង្គាប់ឲ្យចុងចម្លើយឈ្មោះថជ បង់ប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តីនិងពហ្នឹងចំនួន១.៨០០រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះចំនួ ៥.០០០រៀល បូករួម៧.០០០រៀល ។ ប្រាក់នេះបានកាត់យកពីប្រាក់៧.០០០រៀល ដែលដើមចោទ បានបង់ទុករួចហើយ កាលបើហួសការប្តឹងឧទ្ធរណ៍បង្គាប់ឲ្យ

ឈ្មោះថជ សងប្រាក់ចំនួន៧.០០០៛ ទៅដើមចោទវិញ។ និងឲ្យចុងចម្លើយ បង់ពន្ធសមាមាត្រលើតំលៃដីមួយភាគរយដែលត្រូវប្រគល់ ឲ្យទៅដើមចោទទាំងអស់ ។ ប្រាក់នេះបង់ចូលថវិការដ្ឋ៨០ភាគរយ និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០ភាគរយ ។

៨-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខកូតាគីទាំងសងខាងសម្រេច បើកផ្លូវឧទ្ធរណ៍រយៈពេល៦០ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រមនេះទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៣ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ របស់ឈ្មោះ ថជ ប្តឹងសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១២ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ របស់តុលាការខេត្ត ព្រៃវែង ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៦២"យ" ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅៈ

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះថជ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ទុកជា ត្រឹមត្រូវតាមទម្រង់ ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១២ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ របស់ តុលាការខេត្តព្រៃវែង ទុកជាបានការតទៅ ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀលដែលដើមបណ្តឹង ឧទ្ធរណ៍បានបង់ទុករួច គឺពន្ធចុះបញ្ជីក្តី ពន្ធហ្នឹង២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ចំណាយក្នុងកិច្ចប្រគល់ដីកាកោន ៥.០០០រៀល និងចំណាយលើអាជ្ញាធរតុលាការ៥.០០០រៀលសរុប ១៣០០០៛

៤-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខចុងបណ្តឹងឧទ្ធរណ៍ កំបាំងមុខដើមបណ្តឹងឧទ្ធរណ៍ បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ៦៥ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ របស់ឈ្មោះ ថជ ប្តឹងទាស់នឹងសាលដីកាលេខ ៦២ "យ" ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧៧"យ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅៈ

១-ទទួលបណ្តឹងទាស់របស់ឈ្មោះថជ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ទុកជា ត្រឹមត្រូវតាមចំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-ដំកល់សាលដីកាកំបាំងមុខលេខ៦២-យ- ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០១ របស់ សាលាឧទ្ធរណ៍ ទុកជាបានការ ។

៣-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងទាស់បើកផ្លូវសាទុក្ខក្នុងកំណត់

ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២២ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០២ របស់ឈ្មោះ ថឹង ធិនប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៧៧"យ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០២ របស់ឈ្មោះថធ ។

បានឃើញសារណាតប ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០២ របស់ឈ្មោះថង ជ ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា: សូមក្រុមប្រឹក្សាជំនុំជំរះសំរេច តាមច្បាប់ ។

បានស្តាប់ចម្លើយរបស់លោកថធ ( ជាម្ចាស់បណ្តឹងសាទុក្ខ )អាយុ៤៧ឆ្នាំ នៅពេលជំនុំជំរះ

ថា: បានជាខ្លួនប្តឹងសាទុក្ខពីសាលដីការបស់សាលាឧទ្ធរណ៍ មកពីសាលាឧទ្ធរណ៍កាត់ក្តីមិនយុត្តិធម៌ ។

នៅឆ្នាំ១៩៧៩ រដ្ឋបានបែងចែករបបតាមគ្រួសាររៀងៗខ្លួន ខ្លួនរស់នៅជាមួយឪពុកហើយកន្លងមកបងៗបានរុកគួនយកផ្ទះលក់អស់ម្តងហើយ ។ ខ្លួនបានយកម្តាយមកនៅជាមួយ រហូតដល់ស្លាប់ក៏បងៗមិនវិលមកជួយធ្វើបុណ្យដែរ។ ឆ្នាំ១៩៩០រដ្ឋបានចេញលិខិតកាន់កាប់ដីធ្លីមកឱ្យខ្លួន ។ ខ្លួនសុំធ្វើសំណូមពរសុំកាន់កាប់ដីធ្លីដែលខ្លួនធ្លាប់កាន់កាប់តាំងពីឆ្នាំ១៩៧៩មក គាត់មកបង្ខាំងដីខ្លួន៣ឆ្នាំចោលឥតបានធ្វើអ្វីទេ។ ខ្លួនដឹងក្តីពេលណាគឺខ្លួនរស់នៅជាមួយឪពុកម្តាយរហូត ព្រោះខ្លួនជាកូនពៅ។

ឪពុកខ្លួនបានប្រគល់ផ្ទះឱ្យមកខ្លួន តែបងៗរុកគួនលក់ចែកគ្នាអស់ និង ដោយខ្លាចកូន១ឈ្មោះគ្នាម្តាយខ្លួនក៏បានធ្វើបណ្តាំមរតកចែកមកឱ្យខ្លួន ។ ឆ្នាំ១៩៧៩ ក្រោយរបបប៉ុលពត បងៗមិនមកនៅជាមួយទេ គាត់នដោយឡែក ។

បានស្តាប់ចម្លើយរបស់ឈ្មោះថិង ជាង នៅពេលជំនុំជំរះនថា ខ្លួនគឺបងគេបង្អស់ គឺមិនបំបាត់កេរ្តិ៍ទេ ខ្លួនជបងនិយាយថាត្រូវតែចែកគ្នា ព្រោះកេរ្តិ៍នេះ មិនមែនឪពុកម្តាយខ្លួនទុកតែចែកឱ្យថង ធ ទេ ។ ខ្លួនសុំចែកតែដីស្រែ និងភូមិចាស់ប៉ុណ្ណោះ កេរ្តិ៍ដែលចែកហើយខ្លួនមិននិយាយទេ។ ស្រាប់តែគេយកដីនេះប្រគល់ឲ្យជន្លងគេ គ្រាន់តែខ្លួនបេះផ្លែឈើហូបបន្តិចបន្តួចជន្លងគេដេរខ្លួន និងដឹកក្របីកាត់ក៏មិនបានដែរ ។ មេឃុំត្រូវគេសួរនៅសាលាឧទ្ធរណ៍ ថា បណ្តាំមរតក ផ្តិតមេដៃនឹងចង្កៀងប្រេងកាត ។ ចំពោះបញ្ហាដី គឺស្រុកខ្លួនគេមិនវាស់ចែកគ្នាទេ គឺ ដីកេរ្តិ៍អ្នកណាអ្នកហ្នឹងទទួលម្ចាស់ដីយករៀងៗខ្លួន ម្តាយខ្លួនជួលដីនេះឱ្យគេធ្វើស្រែ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកកចរជាមេធាវីការពារចុងចម្លើយ នាពេលសវនាការថា: ដីនេះជាដីកេរ្តិ៍មរតកពីសង្គមចាស់ ថ ធ និង ម្តាយរស់នៅជាមួយគ្នាលើដីនេះតែម្តង ហើយ ថធ ក៏មានកូនដែរ ហេតុអ្វីបានជាយកដីយាយ ណ និង ថធ មកចែកគ្នា ។ ចំណែកបងៗសុទ្ធតែមានដីដែលរដ្ឋបានចែកឱ្យហើយ ។ ឆ្នាំ១៩៩០ ថធ បានដាក់ពាក្យសុំកាន់កាប់ដីហើយមេឃុំ ខ ហ បានទទួលស្គាល់ ពេលនោះក៏គ្មានអ្នកណាប្តឹងដែរ ដល់ឆ្នាំ២០០០ ទើបប្តឹង ។

សូមឯកឧត្តមប្រធានមេត្តាពិនិត្យពិចារណា និង កាត់ក្តីឱ្យ ថធ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និង សេចក្តីសន្និដ្ឋានមេធាវីការពារចុងចម្លើយ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២២ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០២ របស់ឈ្មោះថជ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះនបានតាមមាត្រា១៤នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍បែងចែកដីទំនាស់ជា៥ចំណែកស្មើគ្នានោះ ដោយ សំអាងហេតុថាជាមរតករបស់សពយាយ ខ ណ នោះពុំមានលក្ខណៈត្រឹមត្រូវឡើយ ព្រោះថា ពុំទាន់មានភស្តុតាងណាបញ្ជាក់ច្បាស់លាស់ថា ដីទំនាស់នោះជាកម្មសិទ្ធិផ្តាច់មុខរបស់សពលោកយាយ - ខ ណ តែម្នាក់ឯងនោះទេ ។

+ក្រោយឆ្នាំ១៩៧៩ លោកយាយ ខ ណ នឹង កូនឈ្មោះថជ បានចូលមក កាន់កាប់ដីទំនាស់រហូតដល់សព្វថ្ងៃ ហើយឈ្មោះថជ មានពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លីពីរកន្លែងចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩០ ទៀតផង ។

-យល់ឃើញថា សាលដីកាលេខ៧៧"ឃ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ដែលបានសម្រេច សេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទម្រង់ និងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី ចំពោះមុខគូភាគី

១- ទទួលបណ្តឹងសាទុក្ខលេខ២២ ចុះថ្ងៃទី១៥ ខែមករាឆ្នាំ២០០០ របស់ឈ្មោះថជ ទុកជាត្រឹមត្រូវទាំងទម្រង់ ទាំងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៧៧"ឃ" ចុះថ្ងៃទី២៦ ខែវិច្ឆិកាឆ្នាំ២០០១របស់ សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១៦៧ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០២របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះនជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលឈ្មោះថ ជ បានបង់នៅតុលាការកំពូលចំនួន១៩០០០៛ គឺ

– ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០០៛ សម្រាប់ ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ ។

ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងរដ្ឋប្បវេណី

លេខៈ ១២៤

ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៤ **នាមនាមប្រជារាស្ត្រខ្មែរ**

<u>សាលដីកា</u> **តុលាការកំពូល**

លេខ : ២៥៤ បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤

ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

២-លោក ជាចៅក្រម

៣-លោក ជាចៅក្រម

៤-លោក ជាចៅក្រម

៥-លោក ជាចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

លោក

តំណាងមហាអយ្យការ

លោក ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៤៨២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះថ **ឥ ចា** (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ ៣២ ក្រុមទី១១៧ មណ្ឌល៨ ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះជ ហ "រ" ម្តាយឈ្មោះស គ ហ "រ" ប្តីឈ្មោះ ទ ថ ។

មានមេធាវីលោក ស ច ឱ ជាតំណាង ។

ចុងចម្លើយឈ្មោះ **ខ ឃ** (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៧៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះលេខ ៣២ ក្រុមទី១១៧ មណ្ឌល៨ ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

ផ្ទេរសិទ្ធិឱ្យលោក ទ ស ថ ។

មានមេធាវីលោក ផ ពស ។

**ចម្បងចលឡើង** : ប្តឹងសុំចំណែកលើបណ្តាំមរតករបស់លោក ទ ថ .

**បណ្តឹងតប** : ប្តឹងសុំបដិសេធលិខិតចែកមរតក ចុះថ្ងៃទី១១-១០-២០០១ .

បានឃើញបណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៤ របស់លោក ស ច ឱ ជាមេធាវីតំណាងឱ្យឈ្មោះជ គ ហ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ" ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១២៤ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមបណ្តឹងចុះថ្ងៃទី១៣-១២-២០០១ ដើមចោទ អ្នកស្រី ជ គ ហ ថា : ខ្លួនសុំចំណែកលើបណ្តាំមរតក របស់សពលោកតា ទ ថ ចុះថ្ងៃទី១១-១០-២០០១ ដែលបានប្រគល់ឱ្យខ្លួនជាប្រពន្ធ និងជាអ្នកបំរើ មើលថែលោកតា ទ ថ និងបានមើលថែជំងឺលោកតា ទ ថ តាំងពីឆ្នាំ១៩៩៨ បានរស់នៅជាមួយគ្នារហូតមក ។ ក្នុងការបំរើលោកតា ទ ថ សព្វសារពើនេះ គាត់តែងនិយាយថា អាណិតស្រលាញ់ខ្លួនណាស់ បើគាត់ស្លាប់ទៅ មិនឱ្យខ្លួនលំបាកទេ តែខ្លួនមិនចាប់អារម្មណ៍ និងសំដីនេះឡើយ ។ នៅថ្ងៃទី១៥-១០-២០០១ លោកតា ទ ថ បានប្រគល់ស្រោមសុំបុត្រ១មកឱ្យខ្លួន ដោយប្រាប់ថា នេះជាកេរ្តិ៍បន្តិចបន្តួច សំរាប់ឱ្យខ្លួនចិញ្ចឹមជីវិតបានដោយខ្លួនឯង នៅពេលអត់ពីគាត់ទៅ ដល់ថ្ងៃបន្ទាប់លោកតា ទ ថ មានជំងឺធ្ងន់ ខ្លួនក៏បញ្ជូនទៅមន្ទីរពេទ្យកាល់ម៉ែត្រ ដល់ថ្ងៃ២៥-១១-២០០១ វេលាម៉ោង ៩:០០ព្រឹក តា ទ ថ ទទួលមរណៈ-ភាព ខ្លួនរៀបចំធ្វើបុណ្យតាមប្រពៃណីដោយមានញាតិមិត្ត បងប្អូនជួយជ្រោមជ្រែង ។

នៅថ្ងៃទី១១-១២-២០០១ ចៅសង្កាត់ស្រះចក បានអញ្ជើញលោកស្រី ព យ ដែលជាប្រពន្ធមុន បានបួសនៅវត្តតាំងពី១០ឆ្នាំមកហើយ និងកូនដើមរបស់តា ទ ថ ចំនួន០៣នាក់មកស្តាប់នូវសេចក្តីមរតក ពួកគាត់យល់ព្រមតាមសេចក្តីនេះដោយទទួលស្គាល់ថា ពិតជាអក្សររបស់លោកតា ទ ថ មែន ដូចមានកំណត់ហេតុរបស់ចៅសង្កាត់ស្រះចកស្រាប់ ដោយខ្លួនជួបការលំបាក ខ្វះថវិកា ខ្លួនសុំឱ្យតុលាការសំរេចតាមបណ្តាំ ចុះថ្ងៃទី១១-១០-២០០១ របស់លោកតា ទ ថ ។

តាមបណ្តឹងតបចុះថ្ងៃទី០៨-០២-២០០២ លោក ទេព ស៊ុនថា តំណាងឱ្យលោកយាយ ព យ (ប្រពន្ធសព) ថា ខ្លួន និងបង១៦នាក់ទៀត មានឈ្មោះ ទ ណក, ទ ណល ,

ទ មន. ទ វេ៉. ទ វេ៉ា. ទ វង ដែលត្រូវជាកូនបង្កើតរបស់សពលោកតា ទ ថ និងជាទាយាទ សូមប្ដឹងបដិសេធលិខិតចែកមរតក ចុះថ្ងៃទី១១-១០-២០០១ ដែលភាគីដើមចោទប្ដឹងទាមទារ ដោយហេតុថា លិខិតនេះ បានធ្វើឱ្យខូចខាតសិទ្ធិជាទាយាទក្នុងការទទួលមរតក និងធ្វើឱ្យបាត់នូវចំណែករបស់ពួកខ្លួន ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៨"ក" ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងសុំ និងចម្លើយប្ដឹងសុំរបស់លោកយាយ ព យ និងលោក ទ ស ថ ជាតំណាងទាយាទនៃសពលោក ទ ថ ដែលមានលោកមេធាវីផាត់ពៅ-សាង ថណាយក្ដីផង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្ដឹង និងចម្លើយតវ៉ារបស់អ្នកស្រីជ គ ហ ផ្ទេរសិទ្ធិឱ្យអ្នកស្រី ជិ សផ មានមេធាវី ស ច ឌ និងក ស រ ថណាយក្ដីផង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយខុសនឹងគតិច្បាប់ ។

៣-ទុកជាមោឃៈនូវលិខិតបណ្ដាំចែកមរតក ចុះថ្ងៃទី១១-១០-២០០១ របស់សពលោក ទ ថ តាមគោលការណ៍ច្បាប់ ។

៤-បង្គាប់ឱ្យអ្នកស្រី ជិ គ ហ ចែកផ្ទះលេខ ៣៣AE1 .ស្ថិតនៅផ្លូវលេខ ៣៣៦ ភូមិ១ សង្កាត់ផ្សារដើមគរ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ពាក់កណ្ដាលឱ្យមកទាយាទនៃសពលោក ទ ថ មានលោក ទ ស ថ ជាតំណាង មានមេធាវីផ ព ស ថណាយក្ដីផង ។ បើចែកមិនដាច់ស្រេចឱ្យលក់ឡាយឡុងយកប្រាក់ចែកជាពីរភាគស្មើ(មាត្រា ១៦៨ និងតទៅនៃច្បាប់ភូមិបាលថ្មីឆ្នាំ២០០១ ) ។

៥-បង្គាប់ឱ្យឈ្មោះនាងជិ ន អ និង លោក ល សរ និងគ្រួសារព្រមទាំងអ្នកដទៃទៀត ចុះចេញពីផ្ទះលេខ៣៣AE1 ភូមិ១ សង្កាត់ផ្សារដើមគរ ។

៦-ទុកជាមោឃៈនូវលិខិតលក់ដី ផ្ទេរកម្មសិទ្ធិចុះថ្ងៃទី១២-៤-២០០១ នូវដីទំហំ ៤៧៥០ម៉ែ តំលៃ ២៨៥០$ និងលិខិតលក់ដីផ្ទេរកម្មសិទ្ធិចុះថ្ងៃទី១៨-១០-២០០១ ទំហំ ៧៨៨៥ម៉ែ តំលៃ ៤.៧៣១$ ដែលស្ថិតនៅភូមិជ្រោយក្រពៅ២ ឃុំរកាអារ ស្រុកកងមាស ខេត្តកំពង់ចាមពីឈ្មោះអ្នកស្រី ជិ គ ហ ឱ្យទៅឈ្មោះទ ច រ និងប្រពន្ធ ជិ សផ (មាត្រា១៦៨ និង ១៧១ នៃច្បាប់ភូមិបាលថ្មី និងមាត្រា ៣៥ នៃច្បាប់កិច្ចសន្យាលេខ ៣៨) ។

៧-បង្គាប់ឱ្យអ្នកស្រី ជិ គ ហ ផ្ទេរសិទ្ធិឱ្យអ្នកស្រី ជិ សផ មានមេធាវី ស ច ឌ និងក ស រ ថណាយក្ដីផង ចែកដីទំហំ ៤៧៥០ម៉ែ តម្លៃ ២.៨៥០$ ដែល

ទិញពីអ្នកស្រីឈ គ ស តាមលិខិតលក់ដីផ្ទេរកម្មសិទ្ធិកាន់កាប់ចុះថ្ងៃទី១៤-៤-២០០១ ពាក់កណ្ដាលឱ្យទៅទាយាទ នៃសពលោក ទ ថ និងដីទំហំ ៧៨៨៥ ម² ដែលទិញពីឈ្មោះឈ វ ប្រពន្ធឈ្មោះវ ស តំលៃ ៤.៧៣១$ ដែលទិញតាមលិខិតលក់ដីផ្ទេរសិទ្ធិកាន់កាប់ចុះថ្ងៃទី១២-៤-២០០១ ស្ថិតនៅភូមិជ្រោយក្របៅ២ ឃុំរការអារ ស្រុកកងមាស ខេត្តកំពង់ចាម ពាក់កណ្ដាលឱ្យទៅទាយាទនៃសពលោក ទ ថ ។ បើចែកគ្នា មិនដាច់ស្រេចឱ្យលក់ឡាយឡុងយកប្រាក់ចែកគ្នាស្មើ ចាប់ពីពេលដែលសាលក្រមនេះ ស្ថាពរ (មាត្រា១៦៨-១៧១ នៃច្បាប់ភូមិបាលថ្មី) ។

៨-ឱ្យអ្នកស្រី ជិ គ ហ បង់ប្រាក់ប្រដាប់ក្ដី ២១.០០០៛ ដែលបានកាត់យកពីប្រាក់ប្រដាប់ក្ដីរបស់ទាយាទនៃសពលោក ទ ថ ក្នុងសំណុំរឿងលេខ ១៥៣៣ ចុះថ្ងៃទី១៩-១២-២០០១ និងសំណុំរឿងលេខ ១២២ ចុះថ្ងៃទី២៣-០១-២០០២ ចំនួន ១៤.០០០៛ និងសំណុំរឿងលេខ ១៥២៥/១៨-១២-២០០១ ចំនួន ៧.០០០៛ របស់អ្នកស្រីជិ គ ហ ដាក់ថវិការដ្ឋ និងចំណាយផ្សេងៗរួចហើយ និងឱ្យអ្នកស្រី ជិ គ ហ មានអ្នកស្រីជិ សផ ជាតំណាងបង់ពន្ធសមាមាត្រ១% នៃតម្លៃនៃរឿងក្ដីនេះ តែត្រូវឱ្យអ្នកឈ្នះក្ដីបង់ជាមុន ហើយតម្រូវឱ្យអ្នកស្រី ជិ គ ហ សងប្រាក់ប្រដាប់ក្ដីចំនួន ១៤.០០០៛ និងប្រាក់ពន្ធសមាមាត្រនេះទៅទាយាទនៃសពលោកទេព ថូ វិញ ។

៩-សាលក្រមនេះ សម្រេចសេចក្ដី និងប្រកាសជាសាធារណៈ ចំពោះមុខជ - សផ មេធាវី ស ច ឌ លោក ទ ស ថា មេធាវីផ ព ស បើកផ្លូវប្ដឹងឧទ្ធរណ៍កំណត់ ០២ខែ គិតពីថ្ងៃសម្រេចសេចក្ដី ។

បានឃើញបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១១ខែមិថុនា ឆ្នាំ២០០៣ របស់លោក ស ច ឌ តំណាងឱ្យអ្នកស្រី ជិ គ ហ មិនសុខចិត្តនឹងសាលក្រមលេខ១៨"ក" ចុះថ្ងៃទី១២-៥-២០០៣ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១២៩"ឈ" ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១១-៦-២០០៣ របស់លោកមេធាវី ស ច ឌ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៨"ក" ចុះថ្ងៃទី១២-៥-២០០៣ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ ដែលឈ្មោះ ព យ បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្វ៊ឹង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០រៀល ។

កាលបើផុតកំណត់ប្ដឹងសាទុក្ខ បង្គាប់ឱ្យឈ្មោះជិន គឹមហោ សងប្រាក់ ១៣.០០០រនេះ ឱ្យទៅឈ្មោះ ព យ វិញ ។

៤-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៦-៨-២០០៣ ចំពោះមុខតំណាងចុងចម្លើយ និងមេធាវីចុងចម្លើយ កំបាំងមុខដើមចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥-៩-២០០៣ កំបាំងមុខគូក្ដី បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់លេខ ១១៥ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៣ របស់លោក ស ច ខ មេធាវីចំណាយក្ដីឱ្យដើមចោទ ប្ដឹងទាស់នឹងសាលដីការដ្ឋប្បវេណីលេខ១២៩"ឈ" ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ"ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងទាស់ ចុះថ្ងៃទី៣០-៩-២០០៣ របស់លោកមេធាវី ស ច ខ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ១២៩"ឈ"ចុះថ្ងៃទី០៥-៩-២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣-សាលដីកានេះ ជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី២៨-១១-២០០៣ ចំពោះមុខមេធាវីតំណាងគូក្ដី និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥-១២-២០០៣ ចំពោះមុខមេធាវីតំណាងចុងចម្លើយ កំបាំងមុខមេធាវីតំណាងដើមចោទ តែចាត់ទុកជាចំពោះមុខ បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៤ របស់លោក ស ច ខ ជាមេធាវីតំណាងឱ្យឈ្មោះជ គ ហ ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសារណារការពារចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះជ គ ហ

បានឃើញសារណាតបចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះ ព យ ។

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ"ចុះថ្ងៃទី០៥-១២-២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ និងគតិច្បាប់ហើយ ។ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់ក្រឡាបញ្ជីអានសារណារបស់អ្នកស្រី ជិន គីមហោ នៅពេលសវនាការ ។

បានស្តាប់ចម្លើយរបស់លោក ទ ស ថ តំណាងឱ្យអ្នកស្រី ព យ ជាចុងបណ្តឹងសាទុក្ខ នៅពេលសវនាការថា : ចំពោះបណ្តាំមរតក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ ចំពោះខ្លួន និងក្រុមគ្រួសារ ខ្លួនគិតថា មិនត្រឹមត្រូវទេ ហើយក្រុមគ្រួសារទាំងមូលមិនមានអ្នកណាម្នាក់បានដឹងទាល់តែសោះ ។ ចំពោះខ្លួន អ្នកស្រីជ គ ហ មិនមែនជាប្រពន្ធរបស់ឪពុកខ្លួនទេ អ្នកស្រី ជ គ ហ គាត់ទទួលប្រាក់ខែពីឪពុករបស់ខ្លួន ព្រោះថាជាកាតព្វកិច្ច ដូចជា ការបោកគក់អាចម៍នោម គឺជាភារកិច្ចរបស់អ្នកស្រីជ គ ហ ព្រោះអ្នកស្រីជ គ ហ ជាអ្នកបំរើរបស់ឪពុកខ្លួន។ ម្យ៉ាងទៀត អ្នកស្រី ជ គ ហ គាត់បានទទួលចំណែកពាក់កណ្តាលហើយ នៅមានដីជាច្រើនកន្លែងទៀតដែលក្រុមគ្រួសារខ្លួនមិនទាន់បានរកឃើញ ។ ខ្លួនសូមតំកល់សាលដីកាសាលាឧទ្ធរណ៍ទាំងមូល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកសោម ច័ន្ទឌីណា ជាមេធាវីការពារ និងតំណាងឱ្យអ្នកស្រីជ គ ហ ជាម្ចាស់បណ្តឹងសាទុក្ខ បានធ្វើសេចក្តីសន្និដ្ឋានថា :បើពិនិត្យលើបណ្តាំមរតកមួយច្បាប់ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ គឺជាសំណេរអក្សរផ្ទាល់ដៃរបស់ឈ្មោះ ទ ថ ដែលជាម្ចាស់ទ្រព្យដោយបានសរសេរដោយផ្ទាល់ដៃ ក្នុងលិខិតបណ្តាំនេះ បានសរសេរយ៉ាងច្បាស់លាស់អំពីឈ្មោះរបស់ម្ចាស់ទ្រព្យ ហើយបានបញ្ជាក់ពីគោលបំណងដែលម្ចាស់បណ្តាំចង់ប្រគល់អោយ ។ លោកតា ទ ថ បានធ្វើការបែងចែកជាពីរចំណែកយ៉ាងច្បាស់លាស់ គឺទី១ លោកយាយ ព យ ទី២ គឺកូនក្តីខ្លួន តាមការបែងចែកលោកតា ទ ថ បានបញ្ជាក់ពីទីកន្លែង និងប្រវែងច្បាស់លាស់ ទី៣ ទៀតលិខិតបណ្តាំនេះ បានចុះថ្ងៃ ខែ ឆ្នាំ និងបានចុះហត្ថលេខា និងមានស្នាមមេដៃបញ្ជាក់យ៉ាងច្បាស់លាស់ ។ លិខិតបណ្តាំនេះ បានដាក់ក្នុងស្រោមត្រឹមត្រូវហើយ លោកតា ទ ថ បានប្រគល់ឱ្យចៅសង្កាត់ឈ្មោះ ឆ ធរ ដោយបានចុះលេខរដ្ឋបាលយ៉ាងត្រឹមត្រូវ ។ បើសិនជាពិនិត្យលើអត្ថបទច្បាប់វិញ បណ្តាំមរតក គឺជាសន្តតិកម្ម ដែលជាការផ្ទេរនូវបេតិកភ័ណ្ឌនៃបុគ្គលដែលស្លាប់ឱ្យជនម្នាក់ ឬច្រើននាក់ ដែលរស់នៅ ហៅថា សន្តតិជន ។ ការផ្ទេរនេះ គឺធ្វើទៅតាមឆន្ទៈរបស់ម្ចាស់ទ្រព្យ ។ ខ្លួនសំណូមពរ សូមឯកឧត្តមប្រធានតុលាការកំពូល លោកចៅក្រមមេត្តាផ្តល់ភាពយុត្តិធម៌ដល់កូនក្តីខ្លួន ដោយបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះសារជាថ្មីឡើងវិញ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកផ ា ស ជាមេធាវីការពារឱ្យចុងចំលើយ បានធ្វើសេចក្តីសន្និដ្ឋានថា : ខ្លួនសូមជំរាបថា អ្នកស្រីជ គ ហ មិនមែនជាប្រពន្ធរបស់សពលោកតា ទ ថ ទេ គឺជាអ្នកបំរើក្នុងមួយខែ ១០០ដុល្លារអាមេរិក អ្នកស្រីជ គ ហ គាត់បំរើតបស្នងទៅលោកតា ទ ថ វិញ ព្រោះអ្នកស្រីជ គ ហ ទទួលប្រាក់ ១០០ដុល្លារអាមេរិក ក្នុងឋានៈអ្នកស្រីជ គ ហ បំរើមនុស្សចាស់ ។ ជុំវិញបណ្តាំមរតកសរសេរនៅថ្ងៃទី១១ ខែតុលា ឆ្នាំ ២០០១ លោកតា ទ ថ មានសតិអារម្មណ៍មិនហ្នឹងនរ ។ តាមគតិច្បាប់ការបែងចែកមរតកសាស្ត្រសន្តតិជនជំបូងគេបង្អស់គឺកូន កូនមិនបានទទួលបែរជាអ្នកស្រីជ គ ហ បានទទួលពាក់កណ្តាលទៅវិញ គាត់មិនបែងចែកឱ្យទៅទាយាទ គឺជាមោឃភាពរបស់បណ្តាំមរតក។បណ្តាំមរតកសរសេរនៅក្នុងសតិវិលវល់ ។ ចំណែកផ្ទះលេខ៣៣AE, មានស្នាមមេដៃរបស់លោកតា ទ ថ និងជីពីរកន្លែងទៀត ក៏ដាក់ឈ្មោះលោកតា ទ ថ ទៀត បើលោកតា ទ ថ មិនចេញប្រាក់ទេហេតុអ្វីបានដាក់ឈ្មោះលោកតា ទ ថ ។ ខ្លួនសូមសំណូមពរក្រុមប្រឹក្សាជំនុំជំរះ មេត្តាតម្កល់សាលដីកាសាលាឧទ្ធរណ៍លេខ១៧៦"ឈ"ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណាដើមចោទ ចម្លើយតំណាងចុងចម្លើយ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី.
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០០៤ របស់លោកមេធាវី ស ច ឱ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា : ការដែលមេធាវីដើមចោទ លើកឡើងនៅពេលសវនាការនេះថា មរតកសាសន៍ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ ធ្វើឡើងតាមគន្លងច្បាប់ជាលិខិតបណ្តាំ ធ្វើក្រោយគេ ហើយជាប្រភេទលិខិតបណ្តាំឯកជន សរសេរដោយដៃម្ចាស់ទ្រព្យផ្ទាល់ដែលគប្បីមានអានុភាពតាមផ្លូវច្បាប់ ហើយថា បើទោះបីជាអ្នកស្រីជ គ ហ មិនមែនជាសហព័ទ្ធរបស់សពលោកតា ទ ថ ក៏អ្នកស្រីអាចទទួលអច្ច័យទានបានដែរ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា បច្ចុប្បន្នយើងពុំទាន់មានច្បាប់ស្តីពីមរតកទេ ហើយតាមលិខិត ចុះថ្ងៃទី១៤-០២-២០០១ របស់សព បាន

បញ្ជាក់ច្បាស់ថា បានប្រគល់ផ្ទះចែកកូន៧នាក់ ដោយមានតម្លៃតបស្នងផង ។ ម្យ៉ាងទៀត បណ្តាំចុះថ្ងៃទី១១-១០-២០០១ ធ្វើឡើងពេលដែលលោកតា ខ ថ មានជំងឺធ្ងន់ ហើយខ្លឹមសារនៃលិខិតបណ្តាំចុះថ្ងៃទី១១-១០-២០០១នេះ ពុំបានចែងថា ឱ្យលប់ចោលនូវបណ្តាំមុនៗទេ ។

- យល់ឃើញថា តុលាការក្រុងភ្នំពេញ ក៏ដូចជាសាលាឧទ្ធរណ៍ដែរ ពុំបានទទួលស្គាល់អ្នកស្រីជ គ ហ ជាសហព័ទ្ធស្របច្បាប់របស់សពលោកតា ខ ថ ឡើយ តែបែរជាទទួលស្គាល់ផ្ទះលេខ ៣៣ AE1 ស្ថិតនៅផ្សារដើមគរ និងដីនៅស្រុកកងមាស ខេត្តកំពង់ចាម ដោយសំអាងលើលិខិតផ្ទេរសិទ្ធិមានឈ្មោះអ្នកស្រី ជ គ ហ និងសពលោកតា ខ ថ ជាទ្រព្យរួមនោះ គឺជាការភ័ន្តច្រឡំ ពីព្រោះថា បុគ្គលពីរនាក់ដែលមិនមែនជាសហព័ទ្ធនឹងគ្នា មានសិទ្ធិលើវត្ថុតែមួយ មិនអាចមានន័យថា ជាទ្រព្យរួមឡើយ ។

- យល់ឃើញថា ដើមចោទ បានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះ កំបាំងមុខចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៧៦"ឈ"ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ លើកលែងតែចំណុចទី៤.៥.៦.៧ នៃសាលក្រមរបស់តុលាការក្រុងភ្នំពេញ ដែលសាលាឧទ្ធរណ៍តម្កល់ទុកជាបានការ ត្រូវទុកជាមោឃៈ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខតំណាងមុខចម្លើយ**

**កំបាំងមុខដើមចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ០៣ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៤ របស់លោកមេធាវី ស ច ឱ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ខ្លះ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែចំណុចទី៤.៥.៦. និងទី៧ នៃសាលក្រមរបស់តុលាការក្រុងភ្នំពេញ ដែលត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១២៤ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៤ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ត្រង់ចំណុចទី៤.៥.៦ និងទី៧ នៃសាលក្រមរបស់តុលាការក្រុងភ្នំពេញ ។

៤-បែអូសប្រាក់ប្រដាប់ក្តីដែលអ្នកស្រី ព យ បានបង់នៅតុលាការកំពូល ចំនួន

១៩.០០០រៀល គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រ សរុប ១៩.០០០រៀល

៥-សាលដីកានេះជំនុំជំរះនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និង ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៤ ។